ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ការចងចាំនៅប្រទេសភូមា

◆ កំណត់ហេតុរបស់ ប៉ូច យួនលី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦៣ ខែកក្កដា ឆ្នាំ២០១៣

ស្វែងរកការពិត

លេខ១៦៣ ខែកក្កដា ឆ្នាំ២០១៣

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ការបង្ខំចាំនៅប្រទេសភូមា ....................................................... ១

**ផ្នែកឯកសារ**

◆ កំណត់ហេតុរបស់ ប៉ូច យូនលី ....................................................... ៣

◆ ប៉ូច យូនលី ជានរណា? ....................................................... ៩

◆ ញឹក វ៉េងហ៊ួ ទាហាន លន់ នល់ មកពីអាមេរិក ....................................................... ១០

◆ ប្រធានចិញ្ចឹមសត្វសហករណ៍ស៊ីងមានជ័យក្បត់ ....................................................... ១២

◆ បញ្ជីឈ្មោះ និងរូបថតអ្នកទោសមន្ទីរស-២១ ....................................................... ១៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ទើបដឹងថាពុកស្លាប់នៅទួលស្លែង ....................................................... ១៦

◆ ជីវិតក្រោមរបបខ្មែរក្រហម ....................................................... ១៨

◆ ការឈឺចាប់ដែលមិនអាចបំភ្លេចបាន ....................................................... ១៩

◆ ច័ន្ទ ស្រីមុំ ៖ ស្ថានភាពនៅទួលស្លែងមើលទៅ ....................................................... ២១

◆ បូជនីយដ្ឋាន និង ការបង្ខំ ៖ អណ្ដូងស្រមោល ....................................................... ២៤

**ផ្នែកច្បាប់**

◆ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ....................................................... ២៦

◆ ខៀវ សំផន នឹងនៅតែបន្តឃុំខ្លួន ....................................................... ៣១

**វេទិកាពិភាក្សាសាធារណៈ**

◆ អគ្គជំនុំជម្រះសាលាដំបូងពិចារណាលើការ ....................................................... ៣៦

◆ ខ្មែរក្រហម និងណាហ្ស៊ីមិនអាចប្រៀបធៀបគ្នា ....................................................... ៤០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទណ្ឌិតដៃល្មៅ ....................................................... ៤៦

◆ តើខ្ញុំមាននៅសេសសល់សាច់ញាតិឬទេ? ....................................................... ៥៤

◆ ម្ដាយខ្ញុំនៅក្នុងរបបខ្មែរក្រហម ....................................................... ៥៧



កំណត់ហេតុរបស់ ប៉ូច យូនលី ដែលផ្ដល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** លន់ដាលីន, បាបារ៉ា ហ្វឺរ៉ាណូ, អាស្លី ស្កិតហ្វី, សៃម៉ុន ក្រូស៊ើ, ចច រ៉ាយត៍, លីម ជ័យទ័ត្ត, រ៉េនឌល ឌីហ្វាល់កូ, អាន ហាញឌល, ឆាយ ស៊ូឆាត្រ, អ៊ុន សុដាវី, ឆាយ ដាវីន, សុខ វីរៈ, គីម ឡេង **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ ៖** នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ ៖** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការចងចាំនៅប្រទេសភូមា

អំពើគៀបសង្កត់ ជិះជាន់ ការដាក់កំហិតការនិយាយស្តី និងការបំភិតបំភ័យធ្វើឡើងដោយរដ្ឋអំណាច ទាមទារឲ្យមានការឆ្លើយតបដោយជាក់លាក់មួយ ។ ប៉ុន្តែទន្ទឹមគ្នានឹងចំណាត់ការដ៏ជាក់លាក់និងការប្តេជ្ញាមិនងាករេឆ្ពោះទៅរកបុព្វហេតុនីមួយៗដែលជាទូទៅត្រូវបានលើកឡើងថាជាកត្តាដ៏ចាំបាច់នៃយុទ្ធនាការក្នុងការកែលម្អបញ្ហានៅក្នុងប្រទេសភូមានោះ ក៏យើងត្រូវតែប្រយ័ត្នប្រយែងដោយមិនត្រូវមើលរំលងកត្តាសំខាន់នៃយុទ្ធសាស្ត្រការទូតឡើយ ។

ខណៈពេលដែលអ្នកប្រហែលជាទន្ទឹងរកចាំមើលការថ្លែងសុន្ទរកថា ដែលនឹងអាចទាញចំណាប់អារម្មណ៍អ្នកនោះ គោលដៅរបស់ខ្ញុំមិនមែនត្រូវជំរុញលើកចិត្ត ឬបំពាក់បំប៉នអ្នកឲ្យកាន់តែហ៊ានប្រថុយប្រថាននិងកាន់តែប្រើចំណាត់ការក្តៅនោះឡើយ ។ ផ្ទុយទៅវិញ ខ្ញុំចង់ប្រជែងជាមួយអ្នកក្នុងការដោះស្រាយទិដ្ឋភាពសំខាន់ស្មើគ្នាស្តីពីយុទ្ធនាការស្វែងរកសិទ្ធិមនុស្សរបស់អ្នកដែលជាសិល្បៈ ឬវិទ្យាសាស្ត្រនៃយុទ្ធសាស្ត្រការទូត ។ យុទ្ធសាស្ត្រការទូតគឺជាផ្នែកដ៏សំខាន់នៃយុទ្ធនាការរបស់អ្នកពីព្រោះវានឹងបើកចំហនូវឱកាសដែលគ្មានឬក៏មិនត្រូវបានមើលឃើញ ។ យុទ្ធសាស្ត្រការទូតនឹងអនុញ្ញាតឲ្យអ្នកទទួលបានឥទ្ធិពលក្នុងយុទ្ធនាការនយោបាយ ហើយវានឹងធានានូវនិរន្តរភាពរយៈពេលវែងតាមរយៈសមត្ថភាពរបស់អ្នកក្នុងការឆ្លើយតបទៅនឹងបរិយាកាសដែលមិនធ្លាប់ផ្លាស់ប្តូរនៅក្នុងប្រទេសភូមា ។

ប៉ុន្តែ តើអ្វីគឺជាយុទ្ធសាស្ត្រការទូត? យុទ្ធសាស្ត្រការទូតបរិយាយអំពីវិធីសាស្ត្រផ្សេងៗនៃការទំនាក់ទំនង និងការដោះស្រាយជាមួយនឹងតួអង្គនយោបាយ ដោយគ្មានការសម្របសម្រួលគោលដៅយុទ្ធសាស្ត្រ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រវត្តិ



វត្តស្វេដាហ្គុននៅទីក្រុងរ៉ង់ហ្គូនប្រទេសភូមា

យូរលង់ក្នុងការប្រើប្រាស់យុទ្ធសាស្ត្រការទូតដើម្បីជះឥទ្ធិពល ដល់តួអង្គនយោបាយនៅក្នុងប្រទេសកម្ពុជា ។ ទន្ទឹមពេលដែល មជ្ឈមណ្ឌលឯកសារកម្ពុជាប្តេជ្ញារក្សាឲ្យបាននូវការគោរពសិទ្ធិ មនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ វាក៏ជាបញ្ហាស្រួចស្រាវ មួយដែរដែលត្រូវគិតគូរថាតើការប្តេជ្ញាចិត្តនេះត្រូវបញ្ជាក់ប្រាប់ តួអង្គពាក់ព័ន្ធនយោបាយដោយរបៀបណា ។ មជ្ឈមណ្ឌលឯកសារ កម្ពុជាមានជំនឿថា សង្គមស៊ីវិលនៅតែអាចធ្វើការជាមួយរដ្ឋាភិបាល និងក្រុមមានអំណាច ទ្រព្យសម្បត្តិ ដោយមិនចាំបាច់សម្របសម្រួលនូវគោលការណ៍ស្នូល ដើម្បីកេងចំណេញនូវឱកាសក្នុង ការធ្វើឲ្យប្រសើរឡើងដល់គោលដៅយុទ្ធសាស្ត្ររបស់អ្នកណាម្នាក់ នោះឡើយ ។ ក្រោមយុទ្ធសាស្ត្រនេះ សង្គមស៊ីវិលអាចប្រឆាំងនឹង រដ្ឋាភិបាលដែលធ្វើការរំលោភបំពានដល់គោលដៅយុទ្ធសាស្ត្រនេះ ប៉ុន្តែខ្លួនបានខិតខំប្រឹងប្រែងស្វែងរកសកម្មភាពដែលរដ្ឋាភិបាល និងក្រុមប្រឆាំងអាចមានអត្ថប្រយោជន៍ទាំងសងខាង ។ ក្រៅពី ការគ្រប់គ្រងទំនាក់ទំនងជាមួយនឹងតួអង្គពាក់ព័ន្ធនយោបាយ យុទ្ធសាស្ត្រការទូតនេះតម្រូវឲ្យមានយុទ្ធសាស្ត្រទំនាក់ទំនងផ្សេងៗ ទៀត ។ យុទ្ធសាស្ត្រទំនាក់ទំនងផ្សេងៗសំដៅទៅរកការប្រើប្រាស់ យុទ្ធសាស្ត្រ និងផ្នែកពាក់ព័ន្ធដើម្បីជះឥទ្ធិពលដល់សេចក្តីថ្លែងការណ៍ ថ្នាក់ជាតិ និងចុងក្រោយទទួលបានឥទ្ធិពលក្នុងសកម្មភាពយុទ្ធសាស្ត្រ ។ បទពិសោធន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុង សង្គមដែលងើបចេញពីជម្លោះបង្ហាញអំពីតម្លៃនៃការដោះស្រាយ ការប្រឈមលើទិដ្ឋភាពជាច្រើន ។ ឧទាហរណ៍ មុនពេលបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មជ្ឈមណ្ឌលឯកសារ កម្ពុជាបានរៀបចំសកម្មភាពជាច្រើនតាមរយៈបណ្តាញសារព័ត៌មាន ស្ថាប័ននានា និងមនោវិជ្ជានយោបាយដើម្បីជះឥទ្ធិពលដល់ការ បង្កើតតុលាការ ។ សព្វថ្ងៃ មជ្ឈមណ្ឌលឯកសារកម្ពុជាបន្តប្រើប្រាស់វិទ្យុ សារព័ត៌មាន ទស្សនាវដ្តី សៀវភៅ ខ្សែភាពយន្ត វាទិកាអប់រំសាធារណៈ និងការផ្តួចផ្តើមគំនិតអប់រំដើម្បីជះឥទ្ធិពលដល់ឲ្យមានការ និយាយជាសាធារណៈថ្នាក់ជាតិទាំងមូល ។ ទន្ទឹម ពេលដែលអង្គភាពមួយត្រូវតែប្រយ័ត្នប្រយែង ដោយមិនត្រូវលះបង់គុណភាពកម្មវិធីអប់រំដើម្បី យកតែបរិមាណនោះ អង្គភាពនោះគួរតែស្វែងរក ទិដ្ឋភាពថ្មីនិងផ្នែកពាក់ព័ន្ធថ្មីដើម្បីសម្រេចបាន គោលដៅយុទ្ធសាស្ត្រនេះ ។


វត្តស្វេដាហ្គូន ដែលមានកំពស់៩៩ម៉ែត្រ នៅទីក្រុងរ៉ង់ហ្គូន ប្រទេសភូមា

ជាសរុប មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបាន ជំរុញទឹកចិត្តតាមរយៈភាពជោគជ័យនិងការប្តេជ្ញាចិត្តរបស់សកម្មជនសិទ្ធិមនុស្សក្នុងប្រទេសភូមា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងជួយ និងផ្តល់ យោបល់ដល់អង្គការសិទ្ធិមនុស្សនៅក្នុងប្រទេសភូមា ពេលដែលអង្គការទាំងនោះបានវិវត្តទៅមុខក្នុង គោលដៅយុទ្ធសាស្ត្ររបស់ខ្លួន ។ មជ្ឈមណ្ឌលឯកសារ កម្ពុជាទន្ទឹងរង់ចាំឱកាសសម្រាប់ការសហប្រតិបត្តិការ ជាមួយប្រទេសភូមានាពេលអនាគត ។

**ឆាំង យុ**

# កំណត់ហេតុរបស់ ប៉ូច យួនលី

## *ភូមិដំណាវជ្រែង ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៦*
## *មក សានីទី និង ស៊ីវ៉ានា ជាទីនឹករឭក និងជាទីស្រឡាញ់*



សាស្ត្រាចារ្យ ប៉ូច យួនលី

ប៉ា ម៉ាក់ និងគ្រួសារ បានចាកចេញពីកំពង់ឆ្នាំង នៅថ្ងៃទី២០ ខែមេសា ឆ្នាំ ១៩៧៥ ម៉ោង១០យប់ តាមបញ្ជារបស់កងទ័ពបដិវត្តន៍ ។ ក្នុងពេលនោះ ម៉ាក់ឯងទើបនឹងងើបពីឈឺជាទម្ងន់បានចំនួនបីថ្ងៃ ។ ម្ដាយឯងមានជំងឺគ្រុនក្ដៅជាខ្លាំងអស់រយៈពេលមួយខែ គឺពីថ្ងៃទី១១/៣/ ដល់ថ្ងៃទី ១៥/៤/៧៥ ។ វេជ្ជបណ្ឌិតពីរនាក់ត្រូវមកព្យាបាលអស់ប្រាក់ចំនួនប្រាំម៉ឺនរៀល(៥០.០០០៛) ។ អ្នកដែលមករួមដំណើរជាមួយគឺ ៈ

- ◆ លឹម លាវ
- ◆ សរ សមឆោម
- ◆ លាង
- ◆ លាវ គីមហេង និងគ្រួសារ
- ◆ លាវ យូម៉េង

ប៉ា ម៉ាក់ បានយកគ្រឿងសម្លៀកបំពាក់ គ្រឿងបរិភោគ និងថ្នាំកែរោគ ព្រមទាំងសម្ភារខ្លះទៀត សម្រាប់ទ្រទ្រង់ជីវិតបានមួយចំនួនតូច ។ ចំណែក នាង អៀង និង នាយឡេង នឹងគ្រួសារវាត្រូវបែកចេញពីប៉ាម៉ាក់ ដោយទៅនៅឆ្ងាយពីគ្នា ។

ការចេញពីផ្ទះនេះ ប៉ាម៉ាក់ ដឹកនាំអីវ៉ាន់ដោយទោចក្រយានពីរ ដោយ សម ឆោម ជួយជ្រោមជ្រែងពេញបន្ទុកផង ។ ប៉ាម៉ាក់ចេញមកស្ងាក់ស្ទើរក្នុងចិត្តណាស់ ព្រោះថាពេលសង្រ្គាមក៏ត្រូវរងគ្រោះថ្នាក់ ពេលសន្តិភាព ត្រូវរងគ្រោះថ្នាក់ទៀត ដូចជាមិនសមស្របតាមដំណើរជីវិតដែលប៉ាម៉ាក់ធ្លាប់មានមកចំនួនជាងហាសិបឆ្នាំប្លាយកន្លងមកហើយនេះ ។

អ្នកចេញពីក្រុង និងភូមិជិតខាងទាំងឡាយ បានធ្វើដំណើរជាពីរផ្នែក គឺមួយផ្នែកមកតាមផ្លូវព្រៃខ្មែរ កាត់ទៅរមាស មួយផ្នែកទៀតមកតាមផ្លូវភូមិទ្រក ឆ្ពោះទៅរមាសដែរ ។ អ្នកធ្វើរដើងទាំងឡាយមានច្រើនណាស់ មិនដែលជួបប្រទះ គឺណែនណាន់តាន់តាប់ពេញផ្លូវទាំងអស់ ដែលប្រកបដោយទោចក្រយាន រថយន្តតូច ធំ ម៉ូតូរ៉ឺម៉ក រទេះគោ ។ គ្រួសារយើងបានធ្វើដំណើរតាមផ្លូវស្រួលអស់ចំនួន៧០គ.ម គឺកាត់ភូមិទ្រក ក្រាំងទ្រមុំ ទីប្រជុំជនរមាស ខ្ទង់ពពកអូជីប្រង ដំរីស រកាទង ក្នុងរយៈពេលប្រាំបីថ្ងៃ ។ តមក ត្រូវធ្វើដំណើរកាត់តាមព្រៃភ្នំ ក្រំថ្ម គ្មានមនុស្ស គ្មានភូមិ ឮសូរតែសំឡេងសត្វ ស្នូរខ្យល់បក់ស្លឹកឈើ គួរអាណិតខ្លួនណាស់ ។ ដើរមកនោះភ័យផង អរផង ព្រួយផង អារម្មណ៍រវើរវាយជាទីបំផុត ។ ដំណើរកាត់ព្រៃភ្នំនេះ អស់ពេលបីថ្ងៃពីរយប់ ដោយកាត់តាម អូរឈើទាល រលុងភ្នំជីរាយ ភូមិព្រៃវៀរ មានចំនួនផ្លូវប្រវែង ១០០គ.ម ។ មកដល់រលុង មានជនមួយក្រុម ឆែកឆេរ រឹបយក អីវ៉ាន់ពីអ្នកដំណើរ ។ គ្រួសារយើងត្រូវគេយកម៉ាស៊ីនថតមួយ ។ អ្នកដទៃត្រូវយកសម្លៀកបំពាក់ ឱសថ ។ល ។

១) ហេតុអ្វីបានជា ម៉ាក់ប៉ា ធ្វើដំណើរកាត់ព្រៃភ្នំបែបនេះ គឺយោបល់ពីរ ៈ

◆ ឃើញចៅក្រសួងទាំងអស់ក្នុងខេត្ត ចាប់តាំងពីភូឈួយ ខេត្ត ពេទ្យ គេធ្វើដំណើរតាមរថយន្តមកមុនជាហូរហែ កាត់តាមផ្លូវទាំងអស់នេះ ។

◆ គេនិយាយថា ការចាកចេញពីទីក្រុងនេះ គឺមកជួបអង្គការបដិវត្តន៍នៅក្នុងក្រុងថ្មីមួយ នៅក្នុងព្រៃ គេនឹងចែកដីថ្មីឲ្យប្រកបការងាររៀងរហូតទៅ ដោយមានមគ្គុទ្ទេសក៍មួយរូបចាំចង្អុលផ្លូវប្រាប់ឲ្យធ្វើដំណើរ ។ ការធ្វើដំណើរយ៉ាងវែង វេទនា លំបាកលំបិនយ៉ាងក្រៃលែង ដោយមានបីកូនបណ្ដើររហង់ក្នុងព្រៃ គួរឲ្យខ្លោចផ្សាណាស់ ។ ក្នុងការធ្វើដំណើរនេះ មានតែក្រុមលោកចំរើន (បាល័ដ្ឋខេត្ត) ទេ

ដែលអាចដឹកអីវ៉ាន់ ដឹកកូន តាមរថយន្តតូចម៉ាកឡង់រ៉ូវែរ មកបាន ដល់ផ្លូវស្រួលវិញ ។ ឯរថយន្តតូច ធំ ម៉ូតូ ត្រូវអស់សាំង បែកកង់ ជាប់ផ្លូវមកមិនរួច ទុកចោលហូរហែតាមដងផ្លូវដែលដើរកាត់ គួរឲ្យស្តាយ និងគួរអាណោចអាធ័មក្រៃលែង ។

ប៉ាម៉ាក់ គ្រួសារយើង នឹងរួមដំណើរជាមួយ គឺថែមមិត្ត ជ្រួន, អ៊ុង ជន មានគ្នាប្រហែល២០នាក់ ទាំងចាស់ទាំងក្មេងដើរកាត់តាមព្រៃភ្នំនេះ ។ដំណើរចេញពីក្រុងមកអស់រយៈពេល១១ថ្ងៃ ១១យប់ ដោយវេទនា ខ្លោចផ្សាខ្លាំងណាស់ ព្រោះអត់អាហារ ឈឺ អាកាសក្តៅណាស់ ធ្វើដំណើរកាត់ខ្សាច់ កាត់ព្រៃ កាត់ភ្នំ កាត់អូរ តាមផ្លូវលំមានថ្មរកេតរកូត ។ មកដល់ជ្រៃវៀរ ទើបក្រុមលោក ចំរើន, ជិវ មូវ, ថាំង សាង មកទាន់ រួចរួមដំណើរមកដល់ភូមិដំណាក់អំពិល រួចបន្តសមកដល់ភូមិជំទាវជ្រែង តែម្តង នៅថ្ងៃទី១ ខែឧសភា ១៩៧៥ ម៉ោង៩ព្រឹក ។

២) ហេតុអ្វីបានជាមករស់នៅក្នុងភូមិជំទាវជ្រែង ឃុំក្រាំងល្វា ស្រុកកំពង់ត្រឡាចលើ ស្រុក១២ ខេត្តកំពង់ឆ្នាំង?

កាលចេញពីភូមិដំណាក់អំពិលមកនៅថ្ងៃទី១/៥/៧៥ នោះ គឺធ្វើដំណើរតាមផ្លូវធំមួយដែលលាតសន្ធឹងពីសាលាលេខ៥ ទៅដល់ខេត្តកំពង់ស្ពឺ ។ មកដល់ចុងភូមិជំទាវជ្រែង ប្រហែលម៉ោង៩ សំណាក់នៅទីងសាលាឆទានមួយសង់នៅមាត់ទំនប់ទឹកប្រកបដោយអាងទឹកធំ ។ គ្រួសារយើងដាំបាយបរិភោគនៅទីនោះ ដើម្បីចាំស្តាប់ការណ៍ផ្សេងៗ ។ ម៉ោងប្រហែល១៨រសៀល ក៏មានអ្នកភូមិម្នាក់មកហៅគ្រួសារយើង និងអ្នករួមដំណើរឲ្យចូលទៅសំណាក់នៅក្នុងភូមិ ។ នៅថ្ងៃនោះមានអ្នកដំណើរនៅសំណាក់ភូមិនោះច្រើនណាស់ ។ មនុស្សកុះករសុំបើកអង្ករ ។ ប៉ាម៉ាក់ ឃើញគេផ្តុំមនុស្ស១០គ្រួសារៗ ហើយជូនដំណើរទៅទិសខាងលិច ដែលជាដងព្រៃភ្នំជិរាយ ។ ពេលយប់សំណាក់នៅក្នុងភូមិនោះ ប៉ាម៉ាក់ ឮសូរតែការខ្សឹបគ្នាពីរឿងគេសម្លាប់មនុស្សទាំងហ្វូងៗ ។ ប៉ាម៉ាក់ព្រួយណាស់ រកពេលចេញដំណើរទៅទៀតពុំបាន ព្រោះខ្លាចគេសម្លាប់ ។ ទៅមុខទៀត គេនិយាយថាកងទ័ពកាចៗណាស់ ។ ហើយមានគេសម្លាប់អ្នកដំណើរយ៉ាងឃោរឃៅ ។ ដូច្នេះ គ្រួសារយើង និងអ្នករួមដំណើរទាំងឡាយសម្រេចនៅក្នុងភូមិនោះ ។ ដំបូង ដេកនៅក្រោមផ្ទះគេអស់រយៈបីយប់បីថ្ងៃ ក្រោយមកទើបគេហៅឲ្យទៅនៅលើផ្ទះ ។

៣) តើគ្រួសារយើងរស់នៅដូចម្តេច?

អង្គការបានឲ្យគ្រួសារយើងនៅផ្ទះមួយធ្វើអំពីឈើប្រក់ក្បឿងបីខ្នង ធំទូលាយជាមួយនឹងគ្រួសារដទៃទៀតចំនួនប្រាំមួយគ្រួសារ មានគ្នាទាំងអស់៤០នាក់ ។ ការសំណាក់មានភាពចង្អៀតចង្អល់ណាស់ ហើយខ្វះអនាម័យទៀតផង ។ នៅបានជាងបីខែ ទើបផ្លាស់មកនៅផ្ទះមួយទៀតតែម្នាក់ឯង ហើយនៅរហូតពេញមួយឆ្នាំ ។

នៅថ្ងៃទី ៩/៥/៧៥ អង្គការបានរៀបចំឲ្យអ្នកភៀសខ្លួន



ប៉ូច យួនលី ប្រពន្ធ និងកូនបីនាក់

ទាំងអស់នៅក្នុងភូមិ ចូលទៅក្នុងកងធ្វើការទាំងអស់ គ្រួសារយើងបានចូលក្នុងកងទីមួយ ។ មានតែពីរកងទេ ។ ប្រធានភូមិតែងតែប្រជុំនិយាយពន្យល់ណែនាំឲ្យយល់នូវគំនិតបដិវត្តន៍ និងមនោគមវិជ្ជាកុម្មុយនីស្ត ។ គ្រួសារយើងទៅរួមធ្វើការដោយកាយ ជាមួយនឹងអ្នកភូមិតែរាល់ថ្ងៃ ។ ក្រោយមកបានធ្វើការទាំងថ្ងៃ ទាំងយប់ គឺពី១០ម៉ោងទៅ១៣ម៉ោង ក្នុង២៤ម៉ោង ។ ការងារគឺ កាប់ចម្ការ គាស់គល់ឈើ ជីកប្រឡាយ លើកផ្លូវ លើកទំនប់ ដាំដំណាំផ្សេងៗ ធ្វើស្រែ លើកភ្លឺស្រែ ។ល ។

សុរស្មី ត្រូវអង្គការចាត់ឲ្យទៅចូលកងយុវជនប្រកស្ទួចរហូតពេញមួយឆ្នាំ ឈឺយ៉ាងទម្ងន់ ។ ប៉ាទៅលើកទំនប់ដា អន្លង់ជ្រៃ ចំនួន ១០ថ្ងៃ ។ សុវិចិត្រ ធ្វើការដកស្ទូងនៅក្នុងភូមិ និងឆ្ងាយពីភូមិចំនួន១០ ឬ ២០ថ្ងៃ ។ សុនិមិត្រ, វឌ្ឍនាការ, វិសិដ្ឋនារី និងម៉ាក់ធ្វើការនៅភូមិទាំងអស់គ្នា ។ នៅខែកក្កដា ១៩៧៥ វិសិដ្ឋ ឈឺជាទម្ងន់ចំនួនមួយខែ ។ សុនិមិត្រ ខិលខូច លួចមាន់ និងដំឡូងគេ ខូចឈ្មោះយ៉ាងខ្លាំងដល់គ្រួសារយើង ។ នៅថ្ងៃទី ២៨/៦/៧៥ ប៉ាត្រូវឈឺយ៉ាងខ្លាំងរហូតចំនួនបួនខែ ។ សមឆោម ត្រូវធ្លាក់ពីដើមត្នោតស្លាប់នៅថ្ងៃទី២៩/៦/៧៥ ម៉ោង១១ថ្ងៃត្រង់ ។

សម្លៀកបំពាក់ទាំងឡាយត្រូវអង្គការឲ្យជ្រលក់ឲ្យខ្មៅទាំងអស់សម្រាប់ធ្វើការសម្លៀកបំពាក់ សុរស្មី និង សុនិមិត្រ ព្រមទាំងរបស់ សុវិចិត្រ ត្រូវបាត់អស់មួយស្បោងធំ ព្រោះផ្ញើនឹងគ្នាឯងឲ្យគេយកមកឲ្យផង ព្រោះធ្វើដំណើរផ្លូវជាមួយគ្នា ។ ដូច្នេះ ប្អូនទាំងបីនាក់ត្រូវការខោអាវយ៉ាងខ្លាំង ។ នៅពេលប៉ាឈឺ ខោអាវប៉ាត្រូវដោះដូរយ៉ាងច្រើន ដើម្បីយកមាន់ អង្ករ ស្ករ អំបិល ដំឡូង មកដូរនឹងឱសថខ្លះ និងទុកអាស្រ័យខ្លះ សំពត់អាវម៉ាក់ និងប្អូន តូចៗត្រូវដូរខ្លះដែរ ដើម្បីក្រពះដែលខ្វះខាតស្បៀងអាហារ ។

ចំណែកអីវ៉ាន់ សមឆោម នៅលើដៃប៉ា តែតិចតួចណាស់ ព្រោះ សមឆោម គ្មានអ្វីធំដុំទេ ។ ឆោម ត្រូវជំពាក់ប៉ា ៥០.០០០៛ ទាំងខ្ទីចាយ និងទាំងថ្លៃបាយ ។

ឱសថដែលបានយកមកពីកំពង់ឆ្នាំងបានតិចតួចណាស់ គ្រាន់តែមើលថែទាំស្រីសិដ្ឋអស់ទៅហើយ ។ ប៉ាត្រូវឈឺថ្លើម



ប៉ូច យួនលី ប្រពន្ធ កូន ព្រមទាំងសាច់ញាតិថតនៅព្រលានយន្តហោះពោធិ៍ចិនតុង ក្នុងឆ្នាំ១៩៦១ មុនពេលចាកចេញទៅទស្សនកិច្ចសហរដ្ឋអាមេរិក

ក្រពះ គ្មានឱសថទេ ដេកចាំជាតែឯកឯងសែនវេទនា ។ មានថ្នាំតិចតួចលេបមិនគ្រប់ចំនួន ប៉ាចាប់ឈឺតាំងតែពីខែមិថុនា ១៩៧៥ រហូតមកចុះស្គាំងស្គម ទ្រុនទ្រាំ ចុះខ្សោយកម្លាំងខ្លាំងណាស់ ព្រោះតែកាលណាចុកពោះហើយ មិនឃ្លានបាយទេដូច្នេះត្រូវអត់បាយបីបួនប្រាំថ្ងៃ ។ ខែតុលា ១៩៧៥ និងខែកុម្ភៈ ១៩៧៦ ចាប់ឈឺយ៉ាំងញឹកញាប់ ។ រូបកាយចេះតែទ្រុឌទ្រោមទៅៗ គ្មានស្រាកស្រាន្ត ម៉ាក់ឯង និងប្អូនៗ ព្រួយជាខ្លាំងនឹងអាការរោគរបស់ប៉ា ព្រោះដើរមិនបានឆ្ងាយ ចុះឡើងផ្ទះមិនរួច ។ ចំណែក សុរស្មី ត្រូវស្គាំងស្គមយ៉ាងខ្លាំង មេកងបាននាំមកដេកពេទ្យឃុំ នៅក្នុងខែមីនា ១៩៧៦ រហូតថ្ងៃនេះមិនទាន់ចេញទេ ។ ជំងឺវាគឺគ្រុនចាញ់ បាក់កម្លាំង និងថ្លើម ។ សុនិមិត្រ ដេកពេទ្យញឹកញាប់ដែរ ព្រោះវាឈឺក្រពះ និងព្រូនធ្វើទុក្ខវា ។ វានៅតែខិលខូចរហូត ឥតព្រមកែប្រែឡើយ ។ នៅពេលលើកប្រព័ន្ធភ្លឺស្រែ វាលួចស្ករ ត្រី ស្បែកជើងគេ គេវាយធ្វើបាបយ៉ាងខ្លាំង រហូតធ្លាក់ឈាម ដេកពេទ្យរហូត ។ វិសិដ្ឋ ត្រូវទៅធ្វើប្រព័ន្ធភ្លឺស្រែដែរក្នុងខែកុម្ភៈ ១៩៧៦ ត្រូវឈឺជាទម្ងន់ដេកពេទ្យទៀត ។ ម៉ែច្រើនចុកពោះពីរដងមួយឆ្នាំ និងឈឺភ្នែកយ៉ាងខ្លាំងចំនួនពីរដង ។ វឌ្ឍនាការ ឃ្វាលគោយ៉ាងសកម្ម គ្មានឈប់ឈរអ៊ីទេ ឈឺដំបៅភ្នែក ចុកពោះមួលក៏មិនឈប់ឈរដែរ ។ ប្អូននេះចេះរកត្រី ខ្យង ក្តាម ត្រាំ ជ័រ ផ្សិត ។ល ។ យកមកផ្តល់ឲ្យប៉ា និងគ្រួសារដែលដេកឈឺនៅផ្ទះ ។ នាយការ ត្រូវបានចូលរៀននៅខែមករា ១៩៧៦ រហូតមក ។ រៀនព្រឹករសៀលឃ្វាលគោ ។ ម៉ែត្រូវធ្វើការធូនៗដែរគឺកាប់គាស់គល់ឈើ ស្រោចដំណាំ ទៅធ្វើប្រព័ន្ធភ្លឺស្រែ ដឹកប្រឡាយ ដកស្ទូង ច្រូតកាត់ ក៏បានធ្វើញឹកញាប់ដែរ ។ នៅខែកក្កដា ១៩៧៦ ទើបគេហៅឲ្យចូលអង្គភាពធ្វើអង្ករប្រចាំភូមិ ។ ម៉ែធ្វើការណាស់ ត្រឹមត្រូវណាស់ក្នុងការងារសកម្មណាស់ មិនដែលធ្វេសប្រហែសទេ ។ សុវិចិត្រ ក៏មានសកម្មភាពដូចម៉ែដែរ តែច្រើននៅឆ្ងាយពីគ្រួសារ ។ គេស្រលាញ់រាប់អានថាសឹងគ្រប់គ្នា ។

ចាប់តាំងពីខែឧសភា ដល់ថ្ងៃទី២៥/១២/៧៥ ត្រូវអាស្រ័យបាយជាឯកជន ។ គេចែកអង្កររាល់ថ្ងៃ ។ ដំបូងគេឲ្យ៨កំប៉ុងចុះថយមក៧កំប៉ុង រហូតដល់គ្នា៨នាក់ អង្ករតែ៤កំប៉ុងកន្លះក្នុងមួយថ្ងៃ ក្នុងខែកញ្ញា តុលា ធ្នូ ១៩៧៥ ។ ដូច្នេះការលំបាកចេះតែធ្ងន់ធ្ងរឡើងជារាល់ថ្ងៃ មកពីស៊ីបបររាវពេក ។ ណាមួយ ប៉ាឈឺផងណាមួយធ្វើការហត់នឿយ ត្រូវការបាយឆ្អែត ឬបបរឆ្អែត ដូច្នេះគ្រួសារយើងត្រូវហេវអស់កម្លាំងជាលំដាប់ ។ នៅថ្ងៃទី២៧/ ១១/ ៧៥ អ៊ំស្រេង ឯង និង នាងអៀង បានមករកប៉ា ដល់ភូមិនៅម៉ោង៨យប់ ។ គេមិនឲ្យសំណាក់នៅជាមួយគ្រួសារយើងទេ ។ គេឲ្យដេកផ្ទះដោយឡែក ។ គេឲ្យជួបគ្នានៅផ្ទះមេកង គេមិនឲ្យជួបគ្នានៅផ្ទះរបស់ខ្លួនឡើយ ។ ប៉ាខ្លាចផ្សារក្រៃលែង ប៉ារកពាក្យពេចន៍អ៊ីនិយាយច្រើនជាមួយនឹង នាងអៀង ឬអ៊ំឯងទេ ប៉ាចេះតែយំៗគ្មានឈប់ឈរ ។ ប៉ាចេះតែឲ្យអ៊ំឯង និង នាងអៀង ជួយរកមធ្យោបាយឲ្យបានប៉ា ម៉ាក់ និងគ្រួសារទៅនៅភ្នំដិល ឬបារាយណ៍ ។ អ៊ំឯងត្រឡប់ទៅផ្ទះវិញនៅព្រឹកឡើងម៉ោង១១ នាថ្ងៃទី២៨/១១/ ៧៥ អ៊ំបានទុកឲ្យប៉ានូវ អង្ករ១៦កំប៉ុង ត្រីឆ្អើរ៤ចង្កាក់ ពងទា២០ ប្រហុកខ្លះ អំបិលខ្លះ ថ្នាំជក់៨ខាំ ស្លា២ខាំ ។ ថ្នាំ ស្លា នេះហើយម៉ាក់បានដូរជា អំបិល ស្ករ យកមកបំពេញការខ្វះខាតនៅពេលនោះ ។ អង្គការភូមិគេមានចែកជំឡូងខ្លះដែរ ស្ករខ្លះ អំបិលខ្លះ ត្រីខ្លះ សាច់គោក្របីខ្លះ និងបន្លែ តែយូរៗម្តង ហើយតិចតួចពេក ។ ប៉ា


ប៉ូច យូនលី ថតជាមួយគ្រូបង្រៀននៅខេត្តកំពង់ចាម ខែមករា ឆ្នាំ១៩៧២

ម៉ាក់វេទនាក្នុងចិត្ត និងរូបកាយខ្លាំងណាស់ ។ ដូច្នេះការដូរដោះសម្លៀកបំពាក់ចេះតែមានរាល់ថ្ងៃដើម្បីក្រពះគ្រួសារ ។ ជួនកាលប៉ាម៉ាក់ លៃអង្ករខ្លះទុកលាយ ដើមល្ហុង និងដំឡូង ធ្វើជាបាយឲ្យប្អូនៗ ស៊ីម្តងម្កាល គឺក្នុងមួយសប្តាហ៍ចំនួនម្តង ឬពីរដង ។ ឯសម្ល ត្រូវស្ល ដាក់ទឹកបីលីត្រកន្លះ ដែលមានបន្លែ នគោង ទំពាំង ត្រកួន ប្រាប់ គឺស្លម្តងសម្រាប់មួយថ្ងៃ ។ ដូច្នេះប្អូនតូចៗមិនសូវឈឺទេ មានសាច់ឈាមគួរសម ។ នាយការ និងនាងសិដ្ឋ ត្រូវរកត្រីរាល់ថ្ងៃ ដោយអូសមុងបានកូនត្រីចង្វា យកមកធ្វើជាត្រីកប់ ត្រីប្រៃ ។ល ។ ប៉ាចេះអាស្រ័យអស់ហើយតាំងពីកង្កែប ជៀស តឹកកែ ខ្ញុំ ឆ្លា ពស់ ។ល ។ ការរៀបចំអាហារអស់នេះច្រើនតែប៉ា និង នាងសិដ្ឋ ព្រោះឈឺនៅផ្ទះ ។ នៅពេលបាយ ប៉ាដួសចែកទាំងបបរ បាយ សម្ល ត្រីអាំង បើមាន ឲ្យប្អូនៗស៊ីឲ្យបានហើយស្រេច ទើបប៉ាហ៊ានស៊ីជាក្រោយ ។ ជួនកាលប៉ាអត់ ជួនម៉ាក់អត់ ។ ស៊ីតែបន្តិចបន្តួចទុកឲ្យប្អូនតូចៗស៊ីឆ្អែតចុះ ។

នៅពេលប៉ាឈឺធ្ងន់ម្តងៗ វិបុល ប្អូនពៅឯងចេះមកដេកឱបប៉ា ហើយនិយាយសាសងសព្វគ្រប់ ។ កាលបើ ប៉ាបិទភ្នែក ដេកសម្ងំយកកម្លាំង វាហៅប៉ា ហើយចាប់បើកភ្នែក កុំឲ្យប៉ាបិទភ្នែក ។ ប៉ាមិននិយាយនឹងវា វាហែកមាត់ប៉ាឲ្យនិយាយទៅ កុំនៅស្ងៀម ។ ប៉ានៅស្ងៀមដោយហេវពេក វាលីជើង លីដៃ វាកុំឲ្យប៉ាស្ងួតស្ងឹងអី ។ ប៉ាអាណិតប្អូននេះណាស់ ដោយវាស្រែកហៅប៉ាមិនសូវលស់ពេលទេ ។ ជួនកាល ជំងឺប៉ាធ្វើឲ្យកូនចៅយំទាំងអស់គ្នាក៏មាន ធ្វើឲ្យភ័យក៏មាន ។ ស្រីសិដ្ឋ ខិតខំណាស់ រកត្រីសាច់ជាមួយ នាយការ មកបំពេញឲ្យប៉ាគ្មានលស់ពេល ។

នាចុងក្រោយលិខិតប៉ានេះ កូនទាំងពីរត្រូវចាំថា ការស្លាប់របស់ប៉ា ប៉ាឥតញាប់ញ័រទេ តែប៉ាចង់ជួបមុខ យាយ តា អ៊ំស្រេង ឯង និងកូនឯងទាំងពីរនាក់ ព្រមទាំងចៅៗ ។ ប៉ាស្លាប់ទៅចុះ ប៉ាមិនចេះរស់នៅក្នុងផ្ទះងងឹត គ្មានចង្កៀង ក្នុងភពងងឹតគ្មានដំណឹងអ្វីទាំងអស់ ដោយគេដកហូតយកតាំងពីម៉ាស៊ីនថត នាឡិកា វិទ្យុ កង់ ម៉ូតូ ឆ្នាំងបាយ ចានស្លាបព្រា កែវទឹក ។ល ។ ប៉ាស្លាប់ទៅចុះ ប៉ាពេញចិត្តនឹងជីវិតប៉ាហើយ កាលប៉ារស់នៅ ប៉ាបានឃើញភពថ្មីៗច្រើន



កំណត់ហេតុរបស់ ប៉ូច យួនលី សរសេរនៅភូមិជំទាវជ្រែងចាប់ពីថ្ងៃទី៩ ខែកុម្ភៈ រហូតដល់ថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៦ ជាថ្ងៃដែលគាត់ត្រូវខ្មែរក្រហមចាប់ខ្លួន

ដោយមានពន្លឺគ្រប់គ្រាន់សម្រាប់ជីវិតប៉ា សម្រាប់ជីវភាពកូននៅក្រោយ បន្តជីវិតឲ្យថ្ងៃថ្នូរចុះ ឲ្យមានមនោរម្យស្ថាន មានផាសុខភាពបរិបូណ៌ មានភាពសុខដុមរមនាចុះ កូនទាំងពីរ កូនទាំងអស់កុំភ្លេចថ្នាក់ថ្នមម៉ាក់ឲ្យសោះ បើម៉ាក់រស់នៅក្បែរឯង ។ ម៉ាក់ឯងនេះ ជាម្តាយប្រសើរថ្លៃថ្លា ជាម្តាយប្រកបដោយព្រហ្មវិហារធម៌រកទីបំផុតគ្មាន មានចរិយា មានចិត្តថ្លើមល្អណាស់ ប្រពៃណាស់ រកគ្មានទេក្នុងជីវិតរបស់ប៉ា ។ ម៉ាក់ល្អណាស់ចំពោះប៉ា ចំពោះកូនទាំងអស់ ។ ម៉ាក់ឯងយំក្នុងបេះដូង យំក្នុងខួរក្បាល យំក្នុងសតិអារម្មណ៌ យំក្នុងមនោសញ្ចេតនារាល់ថ្ងៃ ។ គិតគូរអាណិតកូន រាល់ទិវារាត្រីគ្មានស្រាកស្រាន្ត ។ នឹកណាស់ ធ្វើការណាស់ឃាត់មិនស្តាប់ទេ ។ ប៉ាបេះតែខ្លាចម៉ាក់ឯងឈឺមួយទៀត ព្រោះឈឺគ្មានឱសថសោះ គ្មានទាល់តែសោះ រកឯណាក៏មិនបាន ។ ប៉ាឈឺ ម៉ាក់យកបន្ដោងពីរ ទៅដូរនឹងគេបានឱសថ១៨គ្រាប់ យកមកឲ្យប៉ាលេបបានមួយពេល តែឈឺវាបេះតែឈឺគ្មានឈប់ ព្រោះឱសថតិចជាងជំងឺ ។

សានីទី! ស៊ីវ៉ានា ! កូនសម្លាញ់! ម៉ែឯងជាស្ត្រីប្រកបដោយធម៌ ល្អគ្រប់បែប ទាំងផ្លូវចិត្ត ទាំងផ្លូវសម្ភារ ។ ក្នុងមួយជីវិតរបស់ម៉ែឯង គឺចិត្តថ្លើមជាប់នៅនឹងកូនគ្រប់រូប ។ គង់តែ សុនិមិត្រ និងស៊ីវ៉ានា ខិលខូចយ៉ាងណា ម៉ែឯងនៅតែអាណិតកូន ស្រលាញ់កូន ។ រស្មី បែកប្រាំពីរខែ ម៉ែយំគ្មានស្រាក នៅជិតតែទៅមិនដល់ ។ ក្នុងចិត្តខ្លោចផ្សារកទីបំផុតគ្មាន ។ ប៉ាម៉ាក់ឈឺចិត្តណាស់នឹងការព្រាត់ប្រាសនិរាស បាត់បង់គ្រួសារទាំងហ្វូងដូចនេះ បើប៉ាស្លាប់មុនម៉ាក់ឯង ប្អូនៗនឹងបានសុខស្រួលគួរសម ដោយម៉ាក់មានចិត្តនឹងន៎បេះថែទាំប្អូនៗ ទៅតាមចិត្តថ្លើមជាម្តាយ ជាស្ត្រីមេផ្ទះ បេះរួតរះរកអាហារចិញ្ចឹមបានស្រួលជាងប៉ា ។ បើម៉ាក់ស្លាប់មុនប៉ា ប្អូនៗនឹងលំបាកបន្តិចហើយ ព្រោះប៉ាមិនសូវរួតរះរកអាហារឲ្យបានពេញលេញទេនាបច្ចុប្បន្ននេះ ។ បើប៉ាម៉ាក់ស្លាប់ទាំងអស់គ្នានៅស្រុកគេនេះ ខ្លោចប៉ាម៉ាក់ស្លាប់ដូចខ្លោចឆ្កែ ខ្លោចឆ្មា គេមិនទាំងឲ្យកូនហែឪពុកម្តាយទៅកប់ផង ហើយមិនទាំងឲ្យស្គាល់ផ្នូរសពអ្នកមានគុណទាំងពីរនេះផង ។ វេទនាក្នុងចិត្តណាស់កូន ។ ប្អូនបែកខ្ញែកគ្នា ឯងលែងស្គាល់ប្អូនតូចៗហើយ ប្អូនៗរស់នៅសែនគោកយ៉ាកលំបាកលំបិនរកទីបំផុតគ្មាន ។ គេស្តីដេរមិនសូវលស់ពេលទេ ។ គេចោទប្រកាន់គ្រប់បែបយ៉ាង មិនដឹងវាសនា អនាគតយ៉ាងណាទេកូន!

សានីទី ! ស៊ីវ៉ានា!

ប៉ាស្លាប់ចុះ ប៉ាពេញចិត្តនឹងស្លាប់ហើយ តែប៉ាចង់ស្លាប់នៅរួមជាមួយនឹងកុងឯង និងយាយឯង និងក្រុមញាតិនៅភ្នំដិល តែធ្វើម៉េចប៉ាអភ័ព្វ បើត្រូវស្លាប់ចោលឆ្អឹងនៅស្រុកគេហើយ ក៏ស្រេចលើវាសនា និងតាមយថាកម្មរបស់ប៉ាចុះ ។ ប៉ានឹកកូនស្រឡាញ់កូន ប៉ាចង់នៅក្បែរ និងជួយទូន្មានណែនាំឲ្យកូនបានប្រកបជាមនុស្សមានសីលធម៌ និងចរិយាធម៌ឲ្យសមរម្យទៅតាមកាលៈទេសៈនៅក្នុងពិភពវិទ្យាសាស្ត្រ និងបច្ចេកទេសវិទ្យាកំពុងលូតលាស់យ៉ាងមហស្ចារ្យនាបច្ចុប្បន្ននេះ និងទៅអនាគត ។ ប៉ាចង់កសាងអនាគតឲ្យចៅៗទៀត ក្រែងចៅណាមួយរបស់ប៉ា មានប្រាជ្ញាជាងប៉ា និងជាងកូនឯងទាំងអស់គ្នា ។ ប៉ាចង់បានចៅដែលសតិប្រាជ្ញាលើសប៉ាណាស់ ។

*ប៉ាលាកូន ចៅ ស្លាប់ដោយរីករាយ !*

*សរសេរចប់នៅថ្ងៃទី២៩/៧/៧៦ នៅភូមិដំនាវជ្រែង*

*ហត្ថលេខា*

*ប៉ុច យូនលី*

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# ប៉ូច យ្ហួនលី ជានរណា?

ប៉ូច យ្ហួនលី កើតក្នុងឆ្នាំ១៩២៤ នៅភូមិភ្នំដិល ឃុំតាំងក្រាំង ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ ឪពុកនាម ប៉ូច គីមហ៊ុ ម្ដាយនាម ទុយ សំ ជាកសិករ ។ ក្នុងឆ្នាំ១៩៣៣ ឪពុកម្ដាយរបស់ ប៉ូច យ្ហួនលី បានផ្លាស់ទីលំនៅទៅរស់នៅទីប្រជុំជនស្រុកបារាយណ៍ ខេត្តកំពង់ធំវិញដោយប្រកបរបបរកស៊ីលក់ដូរបន្ដិចបន្តួច ។ ប៉ូច យ្ហួនលី មានបងប្អូនប្រុសពីរនាក់ និងស្រីម្នាក់ ហើយគាត់ជាកូនទីពីរ ។ បងប្រុសរបស់គាត់ឈ្មោះ ប៉ូច លីស្រេង និងប្អូនស្រីម្នាក់ទៀតឈ្មោះ ប៉ូច គីមលាង ។ ប៉ូច យ្ហួនលី មានប្រពន្ធឈ្មោះ សោម សេងអៀត មានស្រុកកំណើតនៅសង្កាត់បារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ និងមានកូនទាំងអស់ដប់នាក់ គឺ ទី១) ប៉ូច សានីទី ទី២) ប៉ូច ស៊ីវ៉ានា ទី៣) ប៉ូច សុរិយា ទី៤) ប៉ូច សុនីមិត្រ ទី៥) ប៉ូច សុរស្មី ទី៦) ប៉ូច សុវិចិត្រ ទី៧) ប៉ូច វិសិដ្ឋនារី ទី៨) ប៉ូច វឌ្ឍនាការ ទី៩) ប៉ូច សុចិន្ដាមុនី និងទី១០) ប៉ូច វិបុលជាតិ ។

ប៉ូច យ្ហួនលី បានចូលរៀននៅសាលាបឋមសិក្សាបារាយណ៍ ក្រោយមកពេលមានអាយុ២១ឆ្នាំបានទៅបន្តការសិក្សានៅភ្នំពេញ ដោយបានចូលរៀននៅសាលាឈ្នួលវិទ្យាស្ថានខ្មែរ និងសាលាបំពេញវិជ្ជាគរុកោសល្យ ។ នាពេលមហាវិស្សមកាល គាត់បានចូលរៀនខាងគ្រូបង្ហាត់កីឡា និងអប់រំកាយនៅវិទ្យាល័យស៊ីសុវត្ថិ ។

ក្រោយបញ្ចប់ការសិក្សា ប៉ូច យ្ហួនលី ក្លាយជាអធិការបឋមសិក្សា និងបានបម្រើការងារជាច្រើនផ្នែកខាងការអប់រំនៅសាលានានាក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម ព្រមទាំងតំបន់ផ្សេងៗ និងនៅក្រសួងអប់រំទៀតផង ។

ចាប់ពីខែមីនា ដល់ខែឧសភា ឆ្នាំ១៩៥៧ ប៉ូច យ្ហួនលី បានបំពេញទស្សនកិច្ចនៅប្រទេសហ្វីលីពីនជាមួយបុគ្គលិករបស់ក្រសួងអប់រំជាច្រើននាក់ទៀត ។ ក្នុងឆ្នាំ១៩៦១ ប៉ូច យ្ហួនលី បានធ្វើទស្សនកិច្ចនៅសហរដ្ឋអាមេរិក និងបានទស្សនាក្រសួងអប់រំរបស់សហរដ្ឋអាមេរិកផង ។ នៅក្នុងកំណត់ហេតុរបស់គាត់ ប៉ូច យ្ហួនលី បានរៀបរាប់យ៉ាងលម្អិតអំពីដំណើរទស្សនកិច្ចនៅកន្លែងនីមួយៗក្នុងប្រទេសហ្វីលីពីន និងសហរដ្ឋអាមេរិក និងតំបន់ផ្សេងទៀត ។

កំណត់ហេតុរបស់ ប៉ូច យ្ហួនលី បានសរសេរជាពីរផ្នែក ។ ផ្នែកទីមួយគឺជាកំណត់ហេតុដែលសរសេររៀបរាប់ពីប្រវត្តិផ្ទាល់ខ្លួនគ្រួសារ និងការងាររបស់គាត់ចាប់ពីដើមរៀងមក រហូតដល់ចុងឆ្នាំ១៩៧៥ ។

ក្នុងកំណត់ហេតុទីមួយនេះ ប៉ូច យ្ហួនលី ចាប់ផ្ដើមសរសេរនៅថ្ងៃទី២៨ ខែតុលា និងបញ្ចប់នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ក្នុងរបបខ្មែរក្រហម ។

កំណត់ហេតុទីពីរគឺជាសំបុត្រដែល ប៉ូច យ្ហួនលី ផ្ញើជូនទៅកូនរបស់គាត់ពីរនាក់គឺ សានីទី និង ស៊ីវ៉ានា ដែលសមាជិកគ្រួសារទាំងអស់បែកបាក់គ្នាដោយសារការជម្លៀសរបស់ខ្មែរក្រហម ។ នៅក្នុងកំណត់ហេតុទីពីរនេះ ប៉ូច យ្ហួនលី បានសរសេររៀបរាប់អំពីដំណើរជីវិតនិងអ្វីដែលគាត់កំពុងតែទទួលរងអំឡុងពេលដែលកម្មាភិបាលខ្មែរក្រហមកំពុងតែបង្ខំគាត់និងសមាជិកគ្រួសាររបស់គាត់ឲ្យធ្វើការយ៉ាងទម្ងន់ ។ ប៉ូច យ្ហួនលី បានសរសេរកំណត់ហេតុនេះរហូតដល់ថ្ងៃដែលគាត់ត្រូវបានខ្មែរក្រហមបញ្ជូនទៅដាក់មន្ទីរឃុំឃាំងក្រោយពេលដែលកម្មាភិបាលខ្មែរក្រហមរកឃើញថាគាត់គឺជាអតីតអធិការបឋមសិក្សានិងជាបុគ្គលិកក្រសួងអប់រំ ។

ប៉ូច យ្ហួនលី បានបញ្ចប់កំណត់ហេតុរបស់គាត់នៅព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៦ ហើយនៅវេលាម៉ោងប្រមាណបួនកន្លះរសៀលថ្ងៃនោះ គាត់ត្រូវបានខ្មែរក្រហមប្រាប់ឲ្យទៅលើកដើមត្នោតដែលរលំសង្កត់លើសន្ទូង ប៉ុន្ដែតាមពិត ខ្មែរក្រហមយកគាត់ទៅដាក់នៅមន្ទីរឃុំឃាំងអកប្រាក់ ហើយគាត់បានបាត់ខ្លួនរហូតមកដល់សព្វថ្ងៃ ។

សមាជិកគ្រួសាររបស់ ប៉ូច យ្ហួនលី បានរក្សាទុកកំណត់ហេតុនេះដោយសម្ងាត់មិនឲ្យកម្មាភិបាលខ្មែរក្រហមដឹងឡើយ ។ នាដើមខែមិថុនា ឆ្នាំ២០១៣ កំណត់ហេតុនេះត្រូវបានប្រគល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីរក្សាទុកជាប្រវត្តិសាស្ត្រ ។

**ញាណ សុជាតិ និង សោម ប៊ុនថន**

# ញឹក វ៉េងហួរ ទាហាន លន់ នល់ មកពីអាមេរិក

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព J00៥៩៥***

ញឹក វ៉េងហួរ ជាទាហានពាក់ស័ក្តិ២កាលពីរបប លន់ នល់ និងបានចេញទៅរៀនបន្តនៅសហរដ្ឋអាមេរិក ។ វ៉េងហួរ បានត្រឡប់មកប្រទេសកម្ពុជាវិញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពេលមកដល់មាតុប្រទេសដំបូង វ៉េងហួរ ត្រូវបានកម្មាភិបាលខ្មែរក្រហមដឹកយកទៅដាក់នៅសាលាបច្ចេកទេសខ្មែរ-សូវៀត និងក្រោយមកបញ្ជូនទៅជំរំលត់ដំនៅតាខ្មៅ និងព្រែកប្រា ។ វ៉េងហួរ បានរត់គេចខ្លួនពីជំរំលត់ដំនោះ តែគាត់ត្រូវចាប់ខ្លួនបានរួចបញ្ជូនមកមន្ទីរស-២១ ។ ខាងក្រោមជាការរៀបរាប់របស់ វ៉េងហួរ នៅក្នុងចម្លើយសារភាពរបស់គាត់នៅមន្ទីរស-២១ និងពីការងារ និងដំណើររត់គេចខ្លួនរបស់គាត់ក្នុងរបបខ្មែរក្រហម ។

ខ្ញុំមានអាយុ២៧ឆ្នាំ ជនជាតិខ្មែរ នៅលីវ កើតនៅសង្កាត់ព្រៃស្នៀត ស្រុកពារាំង ខេត្តព្រៃវែង ។ ខ្ញុំបានចូលរៀននៅអនុវិទ្យាល័យពារាំងពីឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៨ និងបានរៀននៅវិទ្យាល័យព្រះអង្គឌួងពីឆ្នាំ១៩៦៤ដល់ឆ្នាំ១៩៦៨ ។

បន្ទាប់មក ខ្ញុំបានចូលរៀនបន្តនៅវិទ្យាល័យព្រះយុគន្ធរភ្នំពេញ ដោយក្នុងការសិក្សាឆ្នាំ១៩៦៩ ដល់ឆ្នាំ១៩៧០នេះ ខ្ញុំបានស្នាក់នៅជាមួយបេសកជនសាសនានៅជ្រោយចង្វារ ។

នៅឆ្នាំ១៩៧០ ខ្ញុំបានប្រលងជាប់មធ្យមសិក្សាប័ត្រភាគ២ ផ្នែកវិទ្យាសាស្ត្រពិសោធន៍ ហើយបានចូលបម្រើកងទ័ពនាវីខ្មែររបស់ លន់ នល់ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧១ ខ្ញុំចេញពីសាលាទាហាននាវាចរណ៍នៅជ្រោយចង្វារ ដោយមានឋានន្តរស័ក្តិអនុនាវីត្រីយ៍ ។ បន្ទាប់មកទៀត ខ្ញុំចេញទៅធ្វើការជាមួយរដ្ឋការវៀតណាមខាងត្បូង "ធីវគី" និងនាយទាហានអាកាសចរណ៍អាមេរិកក្នុងភារកិច្ចនាំក្បួននាវាតាមទន្លេមេគង្គពីទល់ដែនវៀតណាមខាងត្បូងមកភ្នំពេញរយៈពេលមួយឆ្នាំ ។

នៅឆ្នាំ១៩៧២ ខ្ញុំមកធ្វើការនៅការិយាល័យដឹកជញ្ជូនភ័ស្តុភារ នៅមូលដ្ឋាននាវាចរណ៍ជ្រោយចង្វារវិញ ។ រហូតមកដល់ដើមឆ្នាំ១៩៧៤ ខ្ញុំត្រូវបានមេបញ្ជាការនាវាចរណ៍ចាត់ឲ្យមករៀនភាសាអង់គ្លេសនៅសេនាធិការដ្ឋានកងទ័ពនាវីខ្មែរនៅភ្នំពេញ ។

បន្ទាប់មកពីរៀនចប់ផ្នែកភាសាអង់គ្លេស នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៤ ខ្ញុំបានចេញដំណើរទៅសិក្សាបន្តនៅសហរដ្ឋអាមេរិក ជាមួយមិត្ត១៩នាក់ផ្សេងទៀត ដោយជិះយន្តហោះទៅឈប់នៅទីក្រុងបាងកក ប្រទេសថៃរយៈពេលពីរថ្ងៃ ។ នៅទីនោះមានជនជាតិអាមេរិកាំងម្នាក់មករង់ចាំយើងរួចជាស្រេច បន្ទាប់មកបាននាំខ្ញុំនិងក្រុមរបស់ខ្ញុំទៅបើកលុយសម្រាប់ចាយរយៈពេលពីរថ្ងៃនៅទីនោះ ។

ខ្ញុំបានបន្តដំណើរទៅស្នាក់នៅនិងរៀននៅវិទ្យាស្ថានផ្នែកភាសាអង់គ្លេសរយៈពេលបីខែ នៅរដ្ឋតិចសាស ។ បន្ទាប់ពីរៀនចប់ ខ្ញុំបានចូលរៀននៅសាលានាយទាហាននាវាចរណ៍ផ្នែកបើកបរនៅរដ្ឋរ៉ូដអាយស៍ឡិន រហូតដល់ខែឧសភា ឆ្នាំ១៩៧៥ ទើបបញ្ចប់ការសិក្សា ។

នៅពេលកងទ័ពបដិវត្តន៍កម្ពុជារំដោះបានប្រទេសកម្ពុជាទាំងស្រុង ខ្ញុំបានប្រាប់ទៅអ្នកទទួលខុសត្រូវជនជាតិអាមេរិកថា ខ្ញុំត្រឡប់មកប្រទេសកម្ពុជាវិញ ។ អ្នកទទួលខុសត្រូវនោះបានបញ្ជូនខ្ញុំទៅនៅជំរំជនភៀសខ្លួននៅរដ្ឋកាលីហ្វ័រញ៉ា ។ នៅទីនោះ ខ្ញុំនិងមិត្តភក្តិបីនាក់ទៀតគឺ ដួង ដាញ់ អតីតវរសេនីយ៍ទោខាងកងកាំភ្លើងធំ, អ៊ុង ជុយ អតីតវរសេនីយ៍ត្រីខាងកងកាំភ្លើងធំ និង ស្រី ណាំ អតីតនាយទាហានរេងកងនាវាចរណ៍ផ្នែកមុជទឹក បានជួបជាមួយ ការី ការ៉េត ជាប្រធានអង្គការ អាកាហ្វា (A K F A) រស់នៅរដ្ឋកាលីហ្វ័រញ៉ា និង ស បួន អតីតឧត្តមសេនីយ៍ត្រី ផ្នែកបញ្ជូនសារក្នុងកងទ័ព លន់ នល់ ។

ខ្ញុំត្រឡប់មកដល់ប្រទេសកម្ពុជានៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ ។ ខ្ញុំត្រូវបានអង្គការបដិវត្តន៍ឲ្យទៅរស់នៅក្នុងសាលាបច្ចេកទេសខ្មែរ-សូវៀត នៅភ្នំពេញ ។ នៅទីនោះ ខ្ញុំបានជួប ដួង

ផាញ់, អ៊ុង ជុយ និង ស្រី ណាំ ដែលចូលមកប្រទេសកម្ពុជាតាំងពីខែកុម្ភៈមុនខ្ញុំ ។ ដួង ផាញ់ បានឲ្យខ្ញុំខិតខំប្រឹងប្រែងធ្វើការដោយពេលនោះខ្ញុំមានឯកទេសខាងបើកនាវាក្នុងសមុទ្រ ។

ក្រោយមក អង្គការបដិវត្តន៍បានបញ្ជូនខ្ញុំឲ្យទៅនៅមន្ទីរតាឡី ដោយមានឈ្មោះ ដួង ផាញ់ ទៅជាមួយដែរ ។ នៅទីនោះខ្ញុំបានខិតខំយកចិត្តមិត្តយុទ្ធជនដែលមើលការខុសត្រូវលើខ្ញុំ និងបានធ្វៀតធ្វើការក្រៅម៉ោងដែលអង្គការដាក់ឲ្យធ្វើថែមទៀត ។ ប៉ុន្តែដោយសង្កេតឃើញមានការលំបាកក្នុងការរស់នៅ ខ្ញុំបានរៀបចំគម្រោងរត់គៀសខ្លួនទៅទល់ដែនថៃ ដោយដើរកាត់តាមភ្នំស្រង់ខេត្តកំពង់ស្ពឺ ។ ពេលនោះ ខ្ញុំបានត្រៀមរៀបចំថ្នាំគ្រុនចាញ់ថ្នាំជីវជាតិ ការ៉ាបិត និងពូថៅ មួយចំនួនរួចជាស្រេច ។ ខ្ញុំមិនដែលហ៊ាននិយាយស្តី ឬធ្វើអ្វីដែលជាការសង្ស័យជាមួយមិត្តភក្តិឯទៀតទេពីគម្រោងដែលខ្ញុំប្រុងរត់ចេញ ។ ប៉ុន្តែនៅពេលធ្វើការរៀងរាល់ថ្ងៃខ្ញុំតែងឮមិត្ត ព្រំ សុខា អតីតអនុសេនីយ៍កងទ័ពអាកាសនិយាយរអ៊ូរទាំពីការរស់នៅលំបាកក្នុងសង្គមបដិវត្តន៍ និងគម្រោងគេចខ្លួនដែរ ។

ផែនការរបស់ខ្ញុំនៅទីនោះបានអាក់ខានទៅវិញ ព្រោះរយៈពេលពីរខែក្រោយមក អង្គការបានដឹកខ្ញុំ និង ស៊ឹម ស៊ីឡេណា អតីតអនុសេនីយ៍ត្រីទ័ពជើងអាកាស ព្រមទាំងមិត្តភក្តិសរុបទាំងអស់ ៣០ នាក់ មកនៅព្រែកប្រាវិញ ។ ពេលមកដល់ព្រែកប្រាភ្លាម ខ្ញុំនិង ស៊ឹម ស៊ីឡេណា បានដោយកទន្លេបាសាក់ និងទៅមើលខ្សែទឹកហូរនៅទីនោះដើម្បីបណ្តែតខ្លួនទៅប្រទេសវៀតណាម ។

ក្រោយមក ខ្ញុំ និង ស៊ឹម ស៊ីឡេណា បានសម្រេចធ្វើដំណើរតាមទន្លេមេគង្គវិញ ដោយពេលនោះខ្ញុំស្នើឲ្យ ស៊ឹម ស៊ីឡេណា ឡើងដើមដូងពិនិត្យមើលស្ថានការណ៍ផ្លូវចេញទៅរកទន្លេមេគង្គ ដើម្បីជៀសវាងដើរចូលភូមិអ្នកស្រុក ។

នៅវេលាម៉ោងមួយរំលងអធ្រាតយប់ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ស៊ឹម ស៊ីឡេណា បានមកដាស់ខ្ញុំ រួចយើងធ្វើដំណើរកាត់តាមចម្ការចេក ឆ្ពោះទៅទិសខាងកើតដោយកាត់តាមព្រៃ និងបឹង ។ វេលាម៉ោងបួនទៀបភ្លឺ យើងទាំងពីរនាក់បានមកដល់ផ្លូវជាតិលេខ១ រួចឆ្លងផ្លូវទៅរកទន្លេមេគង្គ ។ ខ្ញុំបានពួនក្នុងព្រៃមួយនៅជិតមាត់ទន្លេ រហូតដល់ពេលជិតភ្លឺទើបដឹងថាកន្លែងនោះជាជ្រោយអំពិល ។ នៅក្នុងថ្ងៃនោះ យើងអត់ហ៊ានចេញពីព្រៃទេ ហើយរហូតដល់ព្រលប់ទើបយើងលបទៅកាប់ដើមចេកបានម្នាក់ពីរដើមមកដោតភ្ជាប់គ្នាធ្វើជាក្បូន ។ នៅវេលាម៉ោងប្រាំបួនយប់ យើងក៏បណ្តែតខ្លួនចេញពីទីនោះ ។ ប៉ុន្តែដោយ ស៊ឹម ស៊ីឡេណា មានសុខភាពមិនស្រួលនៅយប់នោះ ការធ្វើដំណើរក៏អាក់ខានមួយរយៈ ។ យើងមកដល់ដីឥដ្ឋនៅវេលាភ្លឺ ដូច្នេះយើងទាំងពីរនាក់មិនហ៊ានបន្តដំណើរទៅមុខទៀតទេ គឺយើងបានពួនសម្ងំនៅមាត់ច្រាំងទន្លេនោះ ។ ខ្ញុំ និង ស៊ឹម ស៊ីឡេណា បានឡើងលើមាត់ច្រាំងទន្លេនិងបានលួចកាច់ពោតនៅកន្លែងនោះហូបទាំងឆៅ ។

នៅថ្ងៃនោះ ខ្ញុំបានឃើញប្រជាជនមកធ្វើការនៅក្បែរកន្លែងដែលខ្ញុំពួន ទើបខ្ញុំទាំងពីរនាក់សម្រេចចិត្តចេញពីកន្លែងនោះទៅពួននៅលើដើមឈើវិញ ។ នៅម៉ោង៦ និង៣០ នាទីល្ងាច ខ្ញុំនិង ស៊ឹម ស៊ីឡេណា រៀបចំចេញដំណើរទៅមុខទៀត តែត្រូវប្រជាជននៅកន្លែងនោះចាប់ខ្លួនបានតែម្តង ។ **សោម ប៊ុនថន**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី "សំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្មាន" ដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុដូចខាងក្រោមរៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ៖

◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង១ រសៀល និងម៉ោង៧និង៣០ នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ ព្រឹក និងម៉ោង៤រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែនពិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ០៩២ ១៦៨ ៥៤៣ ។

# ប្រធានចិញ្ចឹមសត្វសហករណ៍ស្ទឹងមានជ័យក្បត់អង្គការ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០៧៤០*

ហ៊ាប ស៊ុនហួង ហៅ ភាគ អាយុ៣០ឆ្នាំ មុនអង្គការចាប់ខ្លួន មាននាទីជាប្រធានចិញ្ចឹមសត្វសហករណ៍ស្ទឹងមានជ័យ កើតនៅភូមិព្រែកតាមាក់ ស្រុកព្រែកតាមាក់ ខេត្តកណ្ដាល ។ តាមរយៈឯកសារចម្លើយសារភាពរបស់សាមីខ្លួនមានដប់ប្រាំទំព័រ ដែលត្រូវវាយជាអក្សរលេខឡើងវិញ ភាគ បានរៀបរាប់យ៉ាងលម្អិតពីសកម្មភាពប្រឆាំងនឹងអង្គការជាមួយនឹងខ្មែរបណ្ដាញមួយចំនួនទៀត ។ ការចាប់ខ្លួន ភាគ នេះប្រហែលមកពីការឆ្លើយដាក់ពីអ្នកដទៃទៀត ដែលអង្គការបានចាប់ខ្លួនមុនព្រោះថា នៅក្របមុខនៃចម្លើយសារភាពមានចំណាររបស់ កាំង ហ្កេចអ៊ាវ ហៅ ឌុច ប្រធានមន្ទីរសន្តិសុខស-២១ ដែលវាយតម្លៃ និងសន្និដ្ឋានផ្ញើជូនទៅអង្គការលើដោយមានកាលបរិច្ឆេទចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ខាងក្រោមនេះជាសេចក្ដីសង្ខេបចម្លើយសារភាពរបស់ ហ៊ាប ស៊ុនហួង ហៅ ភាគ អតីតប្រធានចិញ្ចឹមសត្វសហករណ៍ស្ទឹងមានជ័យ ដោយមានឈ្មោះ ចាន់ ជាអ្នកសួរចម្លើយ ៖

នៅឆ្នាំ១៩៦៨ ខ្ញុំរកស៊ីធាក់រ៉ឺម៉កនៅផ្សារកំពង់ចាម ។ ពេលនោះ ខ្ញុំដឹក មេភាព (អង្គការចាប់ហើយ) ទៅវិទ្យាល័យកំពង់ចាមដោយដាក់ខែ ។ មិនយូរប៉ុន្មាន មេភាព បញ្ឆោរខ្ញុំពីរូបសម្រស់ ។ ខ្ញុំក៏លោភតាម ។ មេភាព ចាប់អប់រំជំហានដំបូងពីការរស់នៅស្រួល និងសប្បាយ បើធ្វើប៉ូលិស ឬប៉េអឹម ។ បន្ទាប់មក មេភាព លើកមកអប់រំខ្ញុំថា សង្គមចក្រពត្តិអាមេរិកសប្បាយសម្បូរ រហូតដល់ខ្ញុំយល់ស្របឲ្យតែ មេភាព ឲ្យធ្វើអ្វីក៏ធ្វើដែរ ។

នៅខែមិថុនា ឆ្នាំ១៩៦៨ មេភាព យកខ្ញុំមកឲ្យធ្វើកម្មករដូតឥដ្ឋនៅវិហារកាតូលិកផ្សារតូច ភ្នំពេញ ។ ផ្ទះនៅស្រាប់ ខោអាវគេឲ្យប្រាក់ខែទៀត ខ្ញុំពេញចិត្តណាស់ ។ មេភាព ចុះឡើងសួរខ្ញុំ និងណែនាំបន្ថែមទៀត ដោយលើកយកការសប្បាយរបស់ សូស្ដែន ជាឧទាហរណ៍ ហើយឲ្យរង់ចាំទទួលការងារខាងមុខ ។

ខែធ្នូ ឆ្នាំដដែល មេភាព បាននាំខ្ញុំចូល សេ.អ៊ី.អា នៅវិហារកាតូលិកផ្សារតូច ភ្នំពេញ ។ តាវ៉ែនតា ទទួលស្គាល់ ហើយប្រាប់ខ្ញុំឲ្យនៅធ្វើការនៅវិហារកាតូលិកដដែល ។ ភារកិច្ចរបស់ខ្ញុំ គឺ ៖

- ◆ ប្រមូលកម្លាំងកម្រិតដំបូងឲ្យចូលកាតូលិកសិន ។
- ◆ យកការណ៍ពីកម្មកររោងចក្រនិងរាយការណ៍ឲ្យអ្នកក្ដាប់អំណាច ។

ក្រោយមក មេភាព ដែលជា សេ.អ៊ី.អា បង្កប់ក្នុងជួរបដិវត្តន៍មកនៅភ្នំពេញដែរ ។ ខ្ញុំក៏ជាខ្មែរ សេ.អ៊ី.អា នឹងមេភាព ។ មេនេះបានឲ្យខ្ញុំចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ដូចខ្លួនដែរ ។

ខែមីនា ឆ្នាំ១៩៧១ ខ្ញុំជាប់គុកភ្នំពេញ ។ ខ្ញុំសារភាពខ្លាំង ។ ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៥ ខ្ញុំចេញពីគុកវិញ ។ ខ្ញុំចូលបង្កប់ខ្លួនក្នុងបដិវត្តន៍តាមខ្មែរឈ្មោះ ក្រាញ់ (អង្គការចាប់ហើយ) ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំទៅនៅសហករណ៍ស្ទឹងមានជ័យ ។ ខ្ញុំជួប មេភាព ហើយគាត់បានចាត់តាំងឲ្យ រឿន បច្ចុប្បន្នក្ដាប់រោងឡានសហករណ៍ស្ទឹងមានជ័យចុះក្ដាប់ខ្ញុំ ។ អ្នកទាំងពីរប្រមូលកម្លាំងវាយអ្នកបដិវត្តន៍ត្រឹមត្រូវក្នុងសហករណ៍នោះឲ្យឯកោ ហើយទិសធំគឺបំផ្លាញមាត៌ា៣តោនមួយហិកតារបស់បក្ស ។

កន្លងមក ឆ្នាំ១៩៧៥ក៏ដូចឆ្នាំ១៩៧៦ដែរ អ្នកទាំងពីរធ្វើសកម្មភាពស្ទុងបត់ដើមសន្ទូង មិនបញ្ចូលទឹកទៅចិញ្ចឹមស្រូវ មិនដាក់ជីបណ្ដោយឲ្យកណ្ដុរនិងចាបស៊ីស្រូវដើមនិងស្រូវចេញអស់រាប់សិបហិកតាទើបរាយការណ៍ ហើយទុកកណ្ដាប់ស្រូវក្នុងស្រែឲ្យត្រូវភ្លៀង ហើយដុះអស់រាប់រយថាំង ។

ខែមករា ឆ្នាំ១៩៧៦ មេភាព បានឲ្យខ្ញុំគ្រប់គ្រងឈ្មោះ ខុម បច្ចុប្បន្នពេទ្យសហករណ៍ស្ទឹងមានជ័យ ។ មេភាព ប្រាប់ថា ខុម នេះជាសេ.អ៊ី.អា (ខ្មែររបស់ឈ្មោះ សុក ក្រុង) និង ហុង (អង្គការចាប់ហើយ) ។ មេភាព ប្រាប់ខ្ញុំថាត្រូវបញ្ចូល ខុម ឲ្យធ្វើពេទ្យសហករណ៍ឲ្យបាន ។

តាមការអប់រំរបស់ខ្ញុំនោះ ខុម បានធ្វើសកម្មភាពដូចជា ៖

◆ លាក់ថ្នាំល្អៗ ទុកប្រើប្រាស់ក្នុងចំណោមបក្សពួកខ្លួន ។

◆ ចាក់ថ្នាំមិនល្អឲ្យអ្នកជំងឺដទៃទៀត ហើយភាគច្រើន ច្រើនតែប្រើថ្នាំបុរាណ ដែលកាលនោះខ្សត់ណាស់ មានតែថ្នាំមួយមុខពីរមុខប៉ុណ្ណោះ ។

◆ បំផ្លាញស៊ីរ៉ាំង ម្ជុល និងឆ្នាំងស្ងោរស៊ីរ៉ាំង បង់រុំរបួសអស់ជាច្រើន ។

◆ អ្នកជំងឺដែលឈឺតិចតួច ខុម មិនឲ្យចុះធ្វើពលកម្មនេះ ដើម្បីឲ្យស្ទះកិច្ចដំណើរការបង្កបង្កើនផលរបស់បក្សមួយផ្នែក ។

ខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំបានទទួលផែនការបំផ្លាញមាគ៌ាបង្កបង្កើនផលរបស់បក្សពីឈ្មោះ ខែម ទៀតគឺដឹកដីឲ្យបានតិចតាមលទ្ធភាពដែលអាចធ្វើកើត ។ ពេលនោះ ខ្ញុំបានចាត់តាំងកម្លាំងបីនាក់ដែល ខែម ប្រាប់ថាជាកម្លាំងរបស់គេគឺ ៖

១) យន កូនរបស់ យី

២) រ៉ាន់ កូនរបស់ ខ្មៅ ក្រេម

៣) ថា អតីតនៅស.២០០ បច្ចុប្បន្ននៅវាយថ្មត្រពាំងក្រឡឹង ឲ្យបំផ្លាញដងរែកនិងជាខ្សែរបស់ ថាំង ។

៦ ខែម វិញ បើកគ្រាក់ទ័របុក និងកិនដែកគោលឲ្យខូចមិនសូវលស់ពេលឡើយ ។ ខែសីហា ឆ្នាំ១៩៧៦ ខ្ញុំឡើងជាប្រធានចិញ្ចឹមសត្វក្នុងសហករណ៍ ។ ខ្ញុំបានយកអំណាចនេះទៅសំឡុតមហាជនឲ្យដាក់កន្ទក់តិចៗឲ្យជ្រូកដើម្បីឲ្យជ្រូកស្គមអស់ ។ ខ្ញុំមិនព្រមដាក់អំពូលភ្លើងកម្តៅកូនមាន់-កូនទាតាមសំណូមពរមហាជន ទេទុកឲ្យកូនសត្វទាំងនេះងាប់ទាំងរយៗ ។

ខែមេសា ឆ្នាំ១៩៧៦ ថ្ងៃមួយ ខែម ត្អូញត្អែរប្រាប់ខ្ញុំពីការលំបាកប្រមូលកម្លាំងស្រីៗ ខែម ថាខាងស្រីៗកម្លាំងមានតែពីរនាក់គឺ ខឿន ជាប្រពន្ធរបស់ខ្លួន និង ភា នារីពេទ្យ ជាគូដណ្តឹងរបស់ខ្ញុំដែលខូចសីលធម៌នឹងគ្នា ។ ពីរនាក់នេះមានភារកិច្ចគ្រាន់តែប្រមូលកម្លាំងស្រីៗតែប៉ុណ្ណោះ ។ ក្រោយមក ខែម បានប្រាប់ខ្ញុំពីផែនការធ្វើរដ្ឋប្រហារដើមឆ្នាំ១៩៧៧ ហើយឲ្យប្រមូលកម្លាំងពិសេស ទាហាន គិញ និងនិស្សិតក្នុងសហករណ៍ ។ ក្នុងការប្រមូលកម្លាំង ខ្ញុំបានលើកពាក្យស្លោកថា "សភាពការណ៍ខ្លាំងក្នុងប្រទេស



កម្មាភិបាលខ្មែរក្រហមមើលថែសត្វពពែនៅកសិដ្ឋានមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ប្របូកប្របល់ណាស់» ។ ដូចនេះ យើងត្រូវត្រៀមខ្លួនកាន់អាវុធ ហើយបើមានការអ្វីត្រូវរត់ទៅប្រមូលផ្តុំនៅមន្ទីរសហករណ៍ដើម្បីយកកាំភ្លើង ។ កាលណោះខ្ញុំថាកាំភ្លើងនឹងយកចេញពីឃ្លាំងស-៨ ។

ខែធ្នូ ឆ្នាំ១៩៧៦ ខែម ចុះមកជួបខ្ញុំទៀត ហើយ ខែម ប្រាប់ថា ផ្នែកធ្វើស្រែឈ្មោះ រឿន អ្នកក្តាប់ ផ្នែកធ្វើត្នោតឈ្មោះ ម៉ាន អ្នកក្តាប់ និងផ្នែកដីបំផ្លាញបានច្រើនជាងគេ ។ ជាមួយគ្នានេះ ភិន ក៏បាត់ខ្លួន ដូចនេះ យើងត្រូវផ្អាកសកម្មភាព សេ.អ៊ី.អា មួយរយៈ ។

ខែឧសភា ឆ្នាំ១៩៧៧ ក្រុមខ្ញុំកម្រើកឡើងវិញ ។ ខែម ចុះមកដាក់ផែនការឲ្យខ្ញុំយកទៅអនុវត្ត ។ ខែម ប្រាប់ទៀតថា ឥឡូវ រឿន ចាត់ចែងដំណើរការ សេ.អ៊ី.អា តទៅទៀត ។ ផែនការ រឿន និង ខែម គឺ:

- ◆ ប្រមូលកម្លាំង សេ.អ៊ី.អា ឡើងវិញ ។
- ◆ កម្ទេចថ្នាក់ដឹកនាំអគ្គភាពស-៩ ពេលបិទវគ្គខែធ្នូ ឆ្នាំ១៩៧៧ ដើម្បីក្រុមខ្លួនក្តាប់សហករណ៍ស៊ឹងមានជ័យ ។
- ◆ កម្ទេចជង្រុកស្រូវសហករណ៍នេះ ក្នុងថ្ងៃកម្ទេចថ្នាក់ដឹកនាំស-៩ ដែរ ។

ក្រោយទទួលផែនការនេះហើយ ខ្ញុំចុះទៅប្រាប់ ម៉ាន បច្ចុប្បន្នក្តាប់ខាងធ្វើត្នោតឲ្យប្រមូលកម្លាំងដែលធ្លាប់នៅមន្ទីរ៩០ ។ សូមបញ្ជាក់ថា ម៉ាន នេះត្រូវ ខែម ខ្មៅសនាមឲ្យខ្ញុំក្តាប់តាំងពីខែសីហា ឆ្នាំ១៩៧៦មកម្ល៉េះ ។ បន្ទាប់មក ខ្ញុំចុះទៅប្រមូលកម្លាំងរបស់ខ្លួនក្នុងផ្នែកចិញ្ចឹមសត្វបាន គឺ ប៉ុក, លន និង អុល ។ តាមខ្ញុំនោះ អុល ក៏មានការទាក់ទងជាមួយ ខែម ដែរ ។

ខែសីហា ឆ្នាំ១៩៧៧ ម៉ាន ប្រាប់ខ្ញុំឲ្យដឹងថាកម្លាំងមានពីរនាក់គឺ នារី រឿង បច្ចុប្បន្នក្តាប់កុមារ ។ រឿង មានភារកិច្ចវាយអែបនឹងមិត្ត ខន អនុប្រធានសហករណ៍ស៊ឹងមានជ័យដើម្បីយកការណ៍ឲ្យ ។ ទីពីរ នារី ខន នៅផ្នែកស្រែ ។ ខន នេះត្រូវ រឿន មេខ្សែ សេ.អ៊ី.អា សហករណ៍នេះចាប់ម្តងកាលនៅឡានទឹកជាមួយគ្នា ។

ដល់ពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៧ ហម ផ្នែកភ្ជួរស្រែ រើសបានគ្រាប់បែកជាបន្តបន្ទាប់ចំនួន បីគ្រាប់ គ្រាប់កាំភ្លើងពីរ និងគ្រាប់អំបែងមួយ ហើយយកមករាយការណ៍ឲ្យខ្ញុំ ។ រឿន នេះឲ្យ ប៉ុក យកទៅទុកក្នុងបន្ទប់ដេកទៅ ។ រឿន រាយការណ៍ឲ្យ ខែម ហើយ ខែម ប្រាប់ឲ្យទុកប្រើប្រាស់ក្នុងផែនការខែធ្នូឆ្នាំ១៩៧៧ ។ ពេលនោះ ខែម ប្រាប់ឲ្យខ្ញុំដឹងភារកិច្ចខ្លួន និងបក្សពួកក្នុងផែនការខែធ្នូ ឆ្នាំ១៩៧៧ ដូចនេះ:

- ◆ រឿន ពិនិត្យសភាពការណ៍ក្នុងសាលា ។
- ◆ ខែម និងខ្ញុំពិនិត្យសភាពការណ៍ក្រៅសាលា ។
- ◆ ម៉ាន និង ប៉ុក ឈរចោលគ្រាប់បែកពីក្រោយកន្លែងខ្ទេសនាមចូលក្នុងសាលា រួចទៅគប់គ្រាប់បែក យកភ្លើងដុតជង្រុកស្រូវសហករណ៍ទៀត ។

ខែវិច្ឆិកា ឆ្នាំ១៩៧៧ ម៉ាន បានយកគ្រាប់បែកដងឈើពីរគ្រាប់ពីកំពង់សោមមកឲ្យខ្ញុំតាមរយៈ ប៉ុក ។ ខ្ញុំប្រាប់ ប៉ុក យកទៅទុកនៅក្នុងបង្គន់ដែលជាកន្លែងទុកសម្ភារ ។ ប៉ុក មានភារៈថែគ្រាប់បែកនេះ ។ នៅពេលបុណ្យ បក្សខ្ញុំ ជួបនឹង ម៉ាន ។ ទាំងពីរនាក់និយាយគ្នាពីបញ្ហាគ្រាប់បែក ។ ម៉ាន ថានៅកំពង់សោមសម្បូរណាស់ ដល់ពេលទៅដឹកកម្លាំងកម្មករពីទីនោះមកវិញចាំយកមកទៀត ។

ខ្ញុំបានកត់សម្គាល់ឃើញថាក្នុងរយៈចុងក្រោយនេះ ម៉ាន ជិតស្និទ្ធនឹង ង៉ែត ណាស់ ។ ទៅណាមកណាជាប់គ្នារហូត ។ តាមខ្ញុំក្តាប់បានថា ង៉ែត នេះជាទាហាន លន់ នល់ ក្នុងសង្គមចាស់ផង ។ តែខ្ញុំពុំឃើញ ម៉ាន រាយការណ៍ម៉េចៗសោះ ។ នៅខែឆ្នាំដដែល ដោយពុំទាន់ទទួលគ្រាប់បែកជាថ្មីពី ម៉ាន ទៀត ខ្ញុំក៏ត្រូវអង្គការចាប់ខ្លួនបាន ។

ភាត អាចត្រូវអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ចន្លោះពីថ្ងៃទី១ដល់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ហើយ កាំង ហ្គេចអ៊ាវ ហៅ ឌុច ផ្ញើទៅអង្គការលើនៅថ្ងៃទី៩ ខែវិច្ឆិកា ។

**ធាវ សារៈមុនិន្ទ**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

*អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ីរិ សាវីណា*

**(តចប់)**

| ល.រ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ៩៦២ | សុិម មុិញ | ប្រុស | ២៨១ | ១៥.៦.៧៨ |
| ៩៦៣ | មុត មួន-ថ្នម | ប្រុស | ២៤ | ៤.៧.៧៨ |
| ៩៦៤ | គង់ ឆែម-ស្រុន | ប្រុស | ៣០ | ៤.៧.៧៨ |
| ៩៦៥ | មៀច ប៉ន-វុធ | ប្រុស | ២៩ | ៤.៧.៧៨ |
| ៩៦៦ | ឡឿក ណន | ប្រុស | ២៨ | ៤.៧.៧៨ |
| ៩៦៧ | ខៀវ លីវ | ប្រុស | ២៧ | ៤.៧.៧៨ |
| ៩៦៨ | ប៊ូ ឈី-សាវី | ប្រុស | ២៦ | ៤.៧.៧៨ |
| ៩៦៩ | រដ្ឋ សារ៉េន | ប្រុស | ២៥ | ៤.៧.៧៨ |
| ៩៧០ | អែក អាន-រ៉ុម | ប្រុស | ១០១ | ៥.៦.៧៨ |
| ៩៧១ | តូច ប៉ែម-ស៊ុន | ប្រុស | ១០២ | ៥.៦.៧៨ |
| ៩៧២ | កុយ ឈឿន | ប្រុស | ១០៣ | ៥.៦.៧៨ |
| ៩៧៣ | ប្រាក់ ជឿក | ប្រុស | ១០៦ | ៥.៦.៧៨ |
| ៩៧៤ | នួន ឆែម | ប្រុស | ១០៧ | ៥.៦.៧៨ |
| ៩៧៥ | ហេង ង្គួន | ប្រុស | ១០៨ | ៥.៦.៧៨ |
| ៩៧៦ | សុន ស៊ឹម-វុធ | ប្រុស | ១០៩ | ៥.៦.៧៨ |
| ៩៧៧ | អ៊ូ ជា | ប្រុស | ១១០ | ៥.៦.៧៨ |
| ៩៧៨ | អ៊ឹង ម៉ុល | ប្រុស | ១១១ | ៥.៦.៧៨ |
| ៩៧៩ | ហេង គម | ប្រុស | ១០៥ | ៥.៦.៧៨ |
| ៩៨០ | សោម ស្ដីនេ | ប្រុស | ១០៤ | ៥.៦.៧៨ |
| ៩៨១ | ជា សុិន- ស៊ុន | ប្រុស | ១០០ | ៥.៦.៧៨ |
| ៩៨២ | អូ ភិន | ប្រុស | ២៨៨ | ១៣.៦.៧៨ |
| ៩៨៣ | គង់ សារី | ប្រុស | ៥៤៤ | ២៣.៦.៧៨ |
| ៩៨៤ | ព្រាប ភាន | ប្រុស | ៨០ | ១១.៧.៧៨ |
| ៩៨៥ | គ្រឹង យ៉ុាង ខា | ប្រុស | ២១ | ១៣.១១.៧៨ វៀតណាម? |
| ៩៨៦ | ឡឹម យ៉ុាំងមីយ | ប្រុស | ២៩០ | ១២.៥.៧៨ វៀតណាម |
| ៩៨៧ | លឿង កុងវ៉ាយ | ប្រុស | ២៤១ | ១៤.២.៧៨ វៀតណាម |
| ៩៨៨ | Christopher Delance | ប្រុស | | ជនជាតិអាមេរិក |

# ទើបដឹងថាពុកស្លាប់នៅទួលស្លែង

ឋិតក្នុងសម្លៀកបំពាក់ខោពណ៌ខ្មៅ អាវឆ្នូតស-ខ្មៅប្រកប ដោយទឹកមុខស្រងូតស្រងាត់ ពូល ពន្ទឹក ប្រឹងនិយាយរៀបរាប់អំពីរឿងរ៉ាវរបស់ឪពុករបស់គាត់ នៅក្នុងការិយាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មានស្រុកកំណើតនៅឃុំក្តុល ស្រុកដូនទាវ ខេត្តបាត់ដំបង ពន្ទឹក សព្វថ្ងៃរស់នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងមានបងប្អូនបីនាក់ ក្នុងនោះ ពន្ទឹក ជាកូនពៅ ។ ពន្ទឹក មកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាក្រោយពីគាត់បានអានទស្សនាវដ្តី “ស្វែងរកការពិត” និង បានឃើញចម្លើយសារភាពរបស់ឪពុកគាត់ ដែលជាអ្នកទោសមន្ទីរស-២១ ។ ពន្ទឹក បានបាត់ឪពុកតាំងពីរបបកម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ ហើយអស់រយៈពេលយូរមកហើយ ដែលគាត់ព្រមទាំងម្តាយ និងសាច់ញាតិមិនដឹងថា ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមយកទៅទីណាឡើយ ។



ក្របមុខចម្លើយរបស់ ពូល ទឿន ដែលជាឪពុករបស់ ពន្ទឹក

ប៉ុន្តែក្រោយពេលបានអានទស្សនាវដ្តី “ស្វែងរកការពិត” ទើបគាត់ដឹងថា ឪពុករបស់គាត់បានបាត់បង់ជីវិតនៅទួលស្លែង ។ កាលពីចុងខែមិថុនាកន្លងទៅ ពន្ទឹក បានមកជួបលោក ញាណ សុជាតិ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានប្រគល់ឯកសារចម្លើយសារភាពទាំងស្រុងទៅឲ្យ ពន្ទឹក ។ នៅថ្ងៃទី៤ ខែកក្កដា កន្លងទៅ ពន្ទឹក បានមកកាន់មជ្ឈមណ្ឌលឯកសារម្តងទៀត ហើយបានជួបនឹងខ្ញុំ (ស៊ិន សុធីតា) ហើយបាននិយាយប្រាប់ខ្ញុំទាំងទឹកមុខក្រៀមក្រំថា នៅឆ្នាំ១៩៧០ ឪពុករបស់គាត់ដែលមានឈ្មោះ ពូល ទឿន គឺជាសាស្ត្រាចារ្យមួយរូបនៅខេត្តបាត់ដំបង ដែលមានចំណេះវិជ្ជាខ្ពស់ ។ ដោយសារតែ ពន្ទឹក កាលនោះនៅក្មេង គាត់មិនសូវស្គាល់ឪពុកច្បាស់ទេ ។ ទើបពេលដែលគាត់ធំដឹងក្តីហើយ ទើបគាត់ឮអ្នកស្រុកនិយាយពីឪពុកគាត់ថាជាមនុស្សចេះដឹង មានអាកប្បកិរិយាស្លូតបូតចេះគោរពចាស់ទុំ និងទទួលបានការស្រឡាញ់រាប់អានគ្រប់គ្នាពីសំណាក់អ្នកស្រុកនិងសហការីរបស់គាត់ ។ ពន្ទឹក បាននិយាយថា បងប្អូនរបស់គាត់តែងប្រាប់ថា ឪពុករបស់គាត់តែងណែនាំកូនឲ្យប្រព្រឹត្តល្អ និងខំប្រឹងរៀនជានិច្ច ។

ក្នុងឆ្នាំ១៩៧៥ គ្រួសាររបស់ពន្ទឹក ត្រូវបានខ្មែរក្រហមជម្លៀសទៅនៅសហករណ៍ក្តុល ឃុំ៤ ស្រុកដូនទាវ តំបន់៤ ក្នុងខេត្តបាត់ដំបង ។ ពេលនោះ ពន្ទឹក ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅជាមួយកងកុមារ ឃ្លាតចេញពីឪពុកម្តាយរបស់គាត់ ដោយពេលនោះមានអាយុត្រឹមតែបីឆ្នាំប៉ុណ្ណោះ ។

ពន្ទឹក បានបន្ថែមថា “ខ្ញុំរស់នៅជាមួយលោកឪពុកបានតែរយៈពេលវេលាដ៏ខ្លីប៉ុណ្ណោះក្នុងរបបខ្មែរក្រហម” ។ ក្រោយមកខ្មែរក្រហមក៏ចាប់ឪពុករបស់គាត់ទៅ ដោយគ្មាននរណាដឹងថាយកទៅទីណាឡើយ ។

ក្រោយពីរបបខ្មែរក្រហមបានដួលរលំទៅ ម្តាយរបស់ពន្ទឹក បាននិយាយរៀបរាប់អំពីដំណើរជីវិតរបស់ឪពុកថា ថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ដោយសារតែខ្មែរក្រហមដឹងថាឪពុកគាត់ជាគ្រូបង្រៀន ឈ្លបពីរនាក់បានមកហៅឪពុកគាត់ដោយយកលេសថា

យកទៅធ្វើការនៅសហករណ៍ ។

ឪពុករបស់ ពន្ទឹក ក៏បាត់រហូត ហើយម្ដាយរបស់គាត់តែង តែគិតថា ប្ដីរបស់គាត់ប្រហែលជាស្លាប់នៅទីនោះហើយ ។ ក្រុមគ្រួសាររបស់ ពន្ទឹក តែងតែគិតថា ឪពុករបស់គាត់ស្លាប់នៅក្នុងខេត្តបាត់ដំបងរហូតមក ។

ក្រោយមក ពេលទទួលបានដំណឹងថា ឪពុករបស់ខ្លួនបានស្លាប់នៅទួលស្លែង ពន្ទឹក មានអារម្មណ៍រន្ធត់ និងឈឺចាប់យ៉ាងខ្លាំងខណៈពេលដែលឪពុកជាទីស្រឡាញ់របស់ខ្លួនបាត់បង់ជីវិតនៅក្នុងទីកន្លែងព្រៃផ្សៃមួយនេះ ។

ដំបូង ពន្ទឹក សឹងតែមិនជឿថាឪពុករបស់គាត់ស្លាប់នៅទីនោះ ដោយសារតែគាត់រន្ធត់ចិត្តខ្លាំងពេក ។ ដោយសារតែមិនទាន់អស់ចិត្ត ពន្ទឹក ខិតខំចំណាយពេលវេលាជាច្រើនដើម្បីតស៊ូសិក្សាស្រាវជ្រាវរិះរកគ្រប់វិធីដើម្បីចង់ដឹងថាឪពុករបស់គាត់ពិតជាបានស្លាប់នៅមន្ទីរស-២១ឬយ៉ាងណា ។

ពន្ទឹក បានទទួលចម្លើយសារភាពរបស់ឪពុកគាត់ដែលមានកម្រាស់ជិតមួយរយទំព័រដែលមានអ្នកសួរចម្លើយឈ្មោះ ខន នៅមន្ទីរស-២១ ។

ពន្ទឹក បាននិយាយថា គាត់នឹងបានដឹងច្រើនបន្ថែមទៀតតាមរយៈចម្លើយសារភាពនេះ ហើយគាត់នឹងខិតខំស្រាវជ្រាវបន្តទៀតដើម្បីឲ្យដឹងពីមូលហេតុដែលខ្មែរក្រហមចាប់ឪពុកគាត់ទៅ ។

ក្រោយពីបានទទួលដំណឹងនេះ ក្រុមគ្រួសាររបស់ ពន្ទឹក តក់ស្លុត អាណិត និងស្រណោះយ៉ាងខ្លាំងនៅពេលដែលដឹងថាឪពុករបស់គាត់ស្លាប់នៅទួលស្លែង ។

ជាចុងក្រោយ ពន្ទឹក បានបន្ថែមទៀត បន្ទាប់ពីគាត់បានទទួលដំណឹងនេះរួចមក គាត់និងក្រុមគ្រួសារបងប្អូន និងសាច់ញាតិរបស់គាត់នឹងនាំគ្នារៀបចំធ្វើបុណ្យដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់ឪពុកគាត់នាពេលខាងមុខនេះ ។

**សុិន សុធីតា**

# ខ្សែភាពយន្តឯកសាររឿង "ក្បង់ទឹកទន្លេ"



"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្ដើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទ នៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្សិក អាឡឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី និងប្រទេសអង់គ្លេស ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្ដីពីការផ្លាស់ប្ដូរបរិស្ថានដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៨ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*

# ជីវិតក្រោមរបបខ្មែរក្រហម

ក្រោយរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាភាគច្រើននាំគ្នាធ្វើដំណើរត្រលប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ចំណែកអ្នកខ្លះទៀតសម្រេចចិត្តធ្វើដំណើរទៅព្រំដែនកម្ពុជា-ថៃដើម្បីស្វែងរកម្ហូបអាហារបរិភោគនិងទីសុវត្ថិភាព ។ កែវ ទីណាង់ ក្រោយពីត្រឡប់ទៅរស់នៅស្រុកកំណើតក្នុងស្រុកឈូក ខេត្តកំពតបានមួយរយៈ ក៏សម្រេចចិត្តនាំគ្រួសារផ្លាស់ទីលំនៅទៅខេត្តមណ្ឌលគិរីវិញដោយសារតែគេចខ្លួនពីការចាប់កំណែនយោធានិងខ្លាចយោធាខ្មែរក្រហម ។

កែវ ទីណាង់ ជាកូនប្រុសម្នាក់ក្នុងចំណោមបងប្អូនប្រុសស្រីប្រាំពីរនាក់ដែលមានឪពុកម្តាយជាកសិករ ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់និងគ្រួសារបន្តរស់នៅស្រុកឈូក ខេត្តកំពតដដែលនិងធ្វើស្រែជាធម្មតា ។ ទីណាង់ បាននិយាយថា ការរស់នៅទីនោះមួយឆ្នាំដំបូងមិនមានការលំបាកអ្វីទេ ព្រោះការងារក៏មិនសូវធ្ងន់ ហើយរបបអង្ករក៏បានច្រើនគួរសមគឺម្នាក់មួយកំប៉ុងក្នុងមួយថ្ងៃ។ ទីណាង់ បានបន្ថែមទៀតថា ក្នុងឆ្នាំ១៩៧៦ អង្គការបានចាត់តាំងឲ្យគាត់ធ្វើការក្នុងកងសេដ្ឋកិច្ចដែលគ្រប់គ្រងដោយប្រធានកងឈ្មោះ ផល ។ គាត់មាននាទីជាអ្នកបុកស្រូវនិងធ្វើការងារផ្សេងៗនៅក្នុងរោងបាយដែលការងារទាំងនោះមិនសូវជាលំបាកប៉ុន្មានទេចំពោះគាត់ ។ មួយរយៈក្រោយមក ប្រធានសហករណ៍បានមកស្នើសុំ ទីណាង់ ពីកងសេដ្ឋកិច្ចឲ្យទៅធ្វើការនៅកងចល័តស្រុកវិញ ។ ទីណាង់ បាននិយាយទាំងត្អូញត្អែរថា ការងារនៅកងចល័តលំបាកជាងការងារនៅកងសេដ្ឋកិច្ចឆ្ងាយណាស់ព្រោះគាត់ត្រូវទៅលើកទំនប់ជីកប្រឡាយ ហើយរបបអាហារក៏មិនគ្រប់គ្រាន់ទៀត ។

នៅឆ្នាំ១៩៧៧ កងចល័តរបស់ ទីណាង់ ត្រូវអង្គការបញ្ជូនឲ្យទៅជីកប្រឡាយនៅភូមិទាន់ហាន់ ឃុំទាន់ហាន់ ស្រុកកំពង់ត្រាច ។ ដោយសារតែធ្វើការជាច្រើនម៉ោងគ្មានពេលសម្រាក ហើយអាហារហូបចុកមិនគ្រប់គ្រាន់ធ្វើឲ្យអ្នកនៅកងចល័តទាំងអស់ចុះស្គមយ៉ាងឆាប់រហ័ស ។ ទីណាង់ បាននិយាយថា “ខ្ញុំ ចុះស្គមយ៉ាងខ្លាំង នៅសល់តែស្បែកដណ្តប់ឆ្អឹង ក្បាលជង្គង់ធំជាងក្បាល មើលទៅហាក់បីដូចជាខ្មោច ។ ដោយអំណាចនៃសេចក្តីស្រេកឃ្លាន យប់មួយ ទីណាង់ និងមិត្តម្នាក់ទៀតបាននាំគ្នាទៅលួចអាហារនៅរោងបាយហូបតែចៃដន្យអាក្រក់ ឈ្លបមកទាន់ក៏ចាប់បានមិត្តរបស់គាត់ ។ ឈ្លបទាំងនោះវាយទាត់ធាក់មិត្តរបស់គាត់យ៉ាងខ្លាំងមុននឹងលែងមកវិញ ។ តែជាសំណាង ពេលនោះ ទីណាង់ រត់រួច ហើយឈ្លបក៏មិនសួរដេញដោលរកអ្នកផ្សេងទៀតដែរ ។ ចាប់តាំងពីថ្ងៃនោះមក គាត់និងមិត្តរបស់គាត់លែងហ៊ានប្រថុយជីវិតទៅលួចអាហារនៅរោងបាយទៀតដែរ ។

ចុងឆ្នាំ១៩៧៨ អង្គការបានផ្លាស់កងចល័តរបស់ ទីណាង់ ទៅលើកទំនប់បឹងទូកដែលស្ថិតនៅខាងលិចផ្សារកំពតវិញ ។ ឆ្លៀតពេលនោះ ទីណាង់ បានលួចរត់មកស្រុកកំណើតនៅឯឃុំត្រពាំងរាំង ស្រុកឈូក ព្រោះគាត់ដឹងពីផែនការរបស់អង្គការ ក្រោយពីលើកទំនប់បឹងទូកហើយ នឹងបញ្ជូនកងរបស់គាត់ទៅធ្វើការនៅភូមិទាន់ហាន់វិញ ដែលជាកន្លែងពិបាកនឹងរស់ ។ ទីណាង់ ក៏លាក់ខ្លួននៅស្រុកកំណើតរហូតដល់ថ្ងៃដែលកងទ័ពវៀតណាមចូលរំដោះ ។ ក្នុងព្រឹត្តិការណ៍ច្បាំងគ្នានៅពេលនោះ ទីណាង់ បាត់បង់បងប្រុសម្នាក់ឈ្មោះ កែវ អន ព្រោះនៅពេលនោះសភាពការណ៍ជ្រួលច្របល់ខ្លាំង គាត់ក៏បែកពីបងប្រុសនៅពេលនោះទៅដោយមិនដឹងបែកទៅទីណា ។

ទីណាង់ រៀបការក្នុងឆ្នាំ១៩៧៨ ដោយអង្គការជាអ្នកផ្សំផ្គុំ តែក្រោយឆ្នាំ១៩៧៩ ក៏លែងលះគ្នាដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា ។

ទីណាង់ បានរស់នៅស្រុកកំណើតរហូតដល់ឆ្នាំ១៩៨២ ទើបផ្លាស់ទីលំនៅមកនៅស្រុកកោះញែក ខេត្តមណ្ឌលគិរីវិញ ។ គាត់បានរៀបការជាមួយប្រពន្ធថ្មីទៀតនិងមានកូនប្រុសស្រីប្រាំមួយនាក់ ។

ទីណាង់ បានមកស្តាប់ការជំនុំជម្រះនៅសាលាក្តីខ្មែរក្រហមដើម្បីចង់ដឹងចម្លើយពិតរបស់មេដឹកនាំខ្មែរក្រហមពីហេតុផលដែលធ្វើឲ្យប្រជាជនខ្មែររាប់លាន់នាក់រងទុក្ខវេទនា ។ ទីណាង់ មានការពេញចិត្តចំពោះសាលាក្តីនេះនិងសង្ឃឹមថា តុលាការមួយ នេះនឹងផ្តល់ឲ្យគាត់នូវយុត្តិធម៌យ៉ាងពិតប្រាកដ ។ **អ៊ុន សុជាទី**

# ការឈឺចាប់ដែលមិនអាចបំភ្លេចបាន

ឈឹង សាខន អាយុ៤៨ឆ្នាំ ជាជនជាតិគួយ រស់នៅស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។ សព្វថ្ងៃនេះ គាត់ប្រកបមុខរបរធ្វើស្រែ ចម្ការ និងដងជ័រទឹកនៅក្នុងព្រៃ ។ ឪពុករបស់ សាខន ឈ្មោះ អៀម ឈឹង ។ សាខន មានប្ដីឈ្មោះ ដាន់ រ៉េត និងកូនទាំងអស់បីនាក់ ។ នៅពេលសាកសួរពីប្រវត្តិរឿងរ៉ាវសម័យខ្មែរក្រហម សាខន និយាយទាំងសំឡេងរដឹកៗ ដែលមានសៀងជាភាសាគួយថា ក្នុងចិត្តរបស់គាត់ពោរពេញទៅដោយកំហឹង និងសេចក្ដីសង្សឹកព្រោះគាត់បានបាត់បង់អ្នកជាទីស្រលាញ់ដែលនៅជុំវិញខ្លួនរបស់គាត់ ។

សាខន បានរៀបរាប់ថា គាត់ឈឺចាប់ណាស់នៅក្នុងសម័យខ្មែរក្រហមដោយសារអំពើឃោរឃៅរបស់កម្មាភិបាលខ្មែរក្រហម ។ គាត់ពុំបានចាំឈ្មោះអ្នកទាំងនោះជាក់លាក់ទេគឺគ្រាន់តែដឹងថា “ទាហាន ប៉ុល ពត” ប៉ុណ្ណោះ ។

នៅវេលាថ្ងៃមួយ ក្នុងឆ្នាំ១៩៧២ ពេលដែល សាខន នៅក្រោមផ្ទះ គាត់បានឃើញយោធាខ្មែរក្រហមមួយក្រុមទៅដល់ផ្ទះរបស់គាត់ ហើយស្រែកហៅឲ្យឪពុករបស់គាត់ចុះមកក្រោម ។ នៅពេលដែលឪពុកគាត់ចុះមកស្រាប់តែយោធាទាំងនោះចាប់ចងស្លាបសេក ហើយក៏បណ្ដើរឪពុកគាត់ចេញទៅ ។ ពេលនោះ ម្ដាយគាត់ពុំនៅផ្ទះទេ ព្រោះខ្មែរក្រហមបញ្ជាឲ្យទៅរុតត្រីនៅឆ្ងាយពីភូមិតាំងពីព្រឹកព្រលឹម ។ សាខន នៅផ្ទះពីរនាក់ប្អូនប៉ុណ្ណោះ ដូច្នេះគាត់បានត្រឹមតែតោងជើងឪពុក និងរត់តាមស្រែកហៅឪពុកឲ្យចាំគាត់ ។ ឃើញដូច្នេះ យោធាខ្មែរក្រហមបានបញ្ជាឲ្យបងប្អូនគាត់ត្រឡប់មកផ្ទះវិញដោយប្រាប់ថា យកទៅនោះ ពុំមែនយកទៅសម្លាប់ចោលទេ គឺយកគាត់ឲ្យទៅសម្រាកព្យាបាលនៅពេទ្យតែប៉ុណ្ណោះ ។ ទោះបីយ៉ាងណា សាខន មិនជឿយោធានោះទេព្រោះឪពុករបស់គាត់ពុំមានជំងឺទេ ហេតុអ្វីបានជាចាប់គាត់ទៅដាក់នៅពេទ្យ?

រយៈពេលប៉ុន្មានថ្ងៃក្រោយមក មានមេភូមិម្នាក់ឈ្មោះ



ជីង សុខន រូបទីប្រាំពីររាប់ពីឆ្វេង ជួរខាងក្រោយ ថតនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាមួយអ្នកភូមិផ្សេងទៀត

តាកែន ជាមនុស្សចិត្តល្អមកលួចប្រាប់គាត់ថា ឪពុករបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលហើយ ថែមទាំងប្រាប់ពីទីតាំងសម្លាប់ទៀតគឺនៅភូមិពោធិ៍ ហើយប្រាប់ឲ្យគាត់ទៅមើល ។ ពេល តាកែន និយាយចប់ សាខន ដើរទៅកន្លែងនោះភ្លាម ។ ពេលទៅដល់ទីតាំងសម្លាប់នោះ សាខន ទ្រូតយ៉ាងខ្លាំង ទោះបីជាគាត់មិនបានឃើញយោធា ខ្មែរក្រហមវាយធ្វើបាប និងសម្លាប់ឪពុកផ្ទាល់ភ្នែកក៏ដោយ ។ សាខន ឃើញសាកសពឪពុកគាត់ដេកផ្កាប់មុខដោយមានស្នាមវះលើខ្នង ។ សាខនបន្តថា ការវះនោះគឺប្រាកដជាវះយកថ្លើមឪពុកគាត់ ។ សាខន បានលួចកាយដីកប់សាកសពឪពុកនៅទីនោះ ។ ទាំងម្តាយ ហើយ សាខន ពុំហ៊ានយំឲ្យឮសំឡេងទេ ព្រោះខ្លាចអង្គការចោទថាខ្មាំងរួចយកទៅសម្លាប់ទៀត ។

រំលងបានប្រាំថ្ងៃក្រោយមកទៀត អ៊ំខាងម្តាយរបស់ សាខន ម្នាក់ត្រូវខ្មែរក្រហមចាប់យកទៅបន្តទៀត ។ នៅពេលដែលចាប់ទៅនោះ យោធាខ្មែរក្រហមប្រាប់ថា អ៊ំរបស់គាត់ត្រូវយកសំបុត្រទៅភូមិពោធិ៍ជ្រិតនៅសម័យនោះអ៊ំរបស់គាត់មានតួនាទីជានីសារ ប៉ុន្តែ សាខន មិនបានឃើញអ៊ំរបស់គាត់ត្រឡប់មកផ្ទះវិញទេ ។ អ្នកភូមិបានប្រាប់ថា ខ្មែរក្រហមយកអ៊ំរបស់គាត់ទៅសម្លាប់ចោលហើយ គឺនៅតាមផ្លូវចម្ងាយ២គីឡូម៉ែត្រពីភូមិពោធិ៍ ។ សាខន បានរកឃើញសាកសពអ៊ំរបស់គាត់ផ្ទាល់ភ្នែក ដោយខ្មែរក្រហមសម្លាប់រួចហើយញាត់ចូលទៅក្នុងប្រហោងឈើធំមួយ ។ មិនត្រឹមតែឪពុកនិងអ៊ំរបស់ សាខន ទេ សូម្បីតែកុមារ ដែលមានអាយុស្របាល១ សាខន ឈ្មោះ ទេព ក៏ត្រូវខ្មែរក្រហមចាប់ទៅសម្លាប់ចោលដែរ ។ ចំណែកបងប្អូនជីដូនមួយរបស់គាត់ ទាំងម្តាយទាំងកូន ដែលពុំដឹងថាមានកំហុសអ្វីនោះ ក៏ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ចោលទៀត ។

បន្ទាប់ពីឪពុកស្លាប់ទៅ សាខន ដែលពេលនោះគាត់មានអាយុប្រមាណដប់ឆ្នាំ ត្រូវអង្គការបំបែកចេញពីម្តាយនិងបងប្អូនឲ្យទៅរស់នៅក្នុងអង្គភាពកុមារដែលគ្រប់គ្រងដោយ យាយពៀ ជាប្រធានកង និង តាលុច ជាគណៈឃុំ ។ នៅទីនោះ ប្រធានកងប្រើ សាខន ឲ្យដឹកប្រឡាយ លើកទំនប់ និងឲ្យហូបតែបបរប៉ុណ្ណោះ ។ សាខន និងអ្នកដទៃទៀត ដែលជាជនជាតិគួយ មិនត្រូវបានអនុញ្ញាតឲ្យនិយាយភាសារបស់ខ្លួនទេ គឺនិយាយភាសាខ្មែរទាំងអស់ បើពុំដូច្នោះទេអង្គការនឹងយកទៅសម្លាប់មិនខាន ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាប់ សាខន ដាក់នៅក្រោមទំនប់ មុំសាលារៀនភូមិព្រះមេ ដោយចោទថាគាត់ជាកូនខ្មាំង ។ យោធាខ្មែរក្រហមបានចាប់គាត់ចងស្លាបសេក ហើយវាយធ្វើបាបរហូតដល់បែកឈាម ហើយយកសំបុកអង្ក្រងមកដាក់លើក្បាល និងខ្លួនគាត់ធ្វើឲ្យគាត់ឈឺចាប់យ៉ាងខ្លាំង ។ ដោយសារទ្រាំទ្រពុំបានជាមួយនឹងទារុណកម្មនោះ សាខន បានលួចរត់ឡើងទៅលើទំនប់ តែយោធាបានចាប់គាត់ទម្លាក់ចុះមកក្រោមវិញ ហើយវាយគាត់បន្ថែមទៀត ។ ពេលនោះ សាខន បានឮយោធាម្នាក់និយាយថា "ឲ្យបាយទឹកវាស៊ីសិនទៅ ចាំវាយទៀត" ។

សាខន និយាយថា គាត់បានរួចជីវិតនៅពេលដែលវៀតណាមចូលមករំដោះ តែអ្វីដែលគាត់សោកស្តាយបំផុតនោះ គឺឪពុកជាទីស្រលាញ់របស់គាត់ និងអ្នកដទៃទៀតបានស្លាប់ទៅដោយពុំមានកំហុស ។ **ឆាយ ដាវីន**

# ដំណឹងស្វែងរកប្អូន

នាងខ្ញុំឈ្មោះ ហង្ស ហួន និងប្តីឈ្មោះ សរ មឿន រស់នៅភូមិត្រពាំងសិរិត សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នាងខ្ញុំសូមប្រកាសរកប្អូនពីរនាក់ គឺ ៖ ◆ ប្អូនស្រី ហង្ស ហ៊ឹម និងប្តីឈ្មោះ មុំ ភីន ។ អ្នកទាំងពីរមានកូនបួននាក់ ទី១) ស្រីញឹប, ទី២) សុភី, ទី៣) សុជាត និង ទី៤) អាចក់ ◆ ប្អូនប្រុស ហង្ស សំណាង ហៅ គ្រឹម និងប្រពន្ធឈ្មោះ សយ យឿន ។ អ្នកទាំងពីរមានកូនពីរនាក់ ទី១) ណាក់ និង ទី២) ណូត ។

សូមបញ្ជាក់ថា គ្រួសារប្អូនៗទាំងពីរបែកគ្នាជាមួយនាងខ្ញុំនៅម្តុំអូរបែកក្អមក្នុងឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។ ក្រោយមកនាងខ្ញុំឮដំណឹងថា គ្រួសារប្អូនទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង ហើយក៏បាត់ដំណឹងរហូតមកដល់ពេលនេះ ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង ឬស្គាល់ឈ្មោះដែលបានរៀបរាប់ខាងលើសូមទំនាក់ទំនងតាមរយៈអាសយដ្ឋាន ផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខៈ ០១៦ ៨៧៦ ៦៩២ ។ ***សូមអរគុណ!***

# ច័ន្ទ ស្រីមុំ ៖ ស្ថានភាពក្នុងគុកមើលទៅដូចឋាននរក

ច័ន្ទ ស្រីមុំ អាយុ២៥ឆ្នាំ កំពុងអង្គុយមើលជាប់ចិត្តទៅនឹងភាពយន្តឯកសារដែលបញ្ចាំងនៅក្នុងបន្ទប់សិក្សានៃសកលវិទ្យាល័យឯកទេសកម្ពុជា ទីរួមខេត្តកំពង់ធំ ។ ភាពយន្តឯកសារនោះបង្ហាញពីមនុស្សដែលជាប់ច្រវាក់ជើង មានរូបរាងកាយស្គមរីងរៃដោយការបង្អត់អាហារ និងការធ្វើទារុណកម្ម និងមានរូបភាពសាកសពត្រូវជាប់ច្រវាក់នៅលើគ្រែដែក និងនៅលើឥដ្ឋផ្ទាល់ដីក្នុងថ្លុកឈាម ។ ចប ប៉ែល សោរដែក ម៉ាស៊ីនថតរូប និងរូបភាពដ៏គួរឲ្យរន្ធត់ជាច្រើនទៀតត្រូវបានដាក់ពង្រាយនៅក្បែរនោះ ។ ទិដ្ឋភាពទាំងនោះបានកើតឡើងនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ នៅគុកទួលស្លែង ក្រុងភ្នំពេញ ។ ឆ្មាំគុក និងកម្មាភិបាលដទៃបានចាកចេញប៉ុន្មានថ្ងៃមុនថ្ងៃដោយបន្សល់ទុកនូវសាកសពដែលស្អុយរលួយមួយចំនួន ។

ស្រីមុំ ដែលជានិស្សិតឆ្នាំទី១ ផ្នែកអក្សរសាស្ត្រនៅសកលវិទ្យាល័យឯកទេសកម្ពុជាបានដឹងអំពីរបបខ្មែរក្រហម (ចន្លោះឆ្នាំ ១៩៧៥-១៩៧៩) តាមរយៈម្តាយរបស់ខ្លួននិងគ្រូបង្រៀន ។ ស្រីមុំ ធ្លាប់បានធ្វើដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងម្តងក្នុងនាមជាភ្ញៀវទេសចរណ៍ ។

ប៉ុន្តែស្រីមុំ មិនដែលបានឃើញវីដេអូរយៈពេលប្រាំពីរនាទីដែលក្រុមឃ្លាំមើលសាលាក្តីខ្មែរក្រហមបានបង្ហាញនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣ ដល់ខ្លួន និងមិត្តរួមថ្នាក់នោះឡើយ ។

នៅក្នុងខ្សែភាពយន្តឯកសារនោះ ទាហានវៀតណាមបានចូលដល់ភ្នំពេញ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ទាហានទាំងនោះបានទៅកាន់គុកទួលស្លែង ដែលជាអតីតសាលារៀន ដោយសារក្លិនស្អុយនៃសាច់រលួយ ។ នៅទីនោះ ទាហានវៀតណាមបានរកឃើញថា ថ្នាក់រៀនជាច្រើនត្រូវបានប្រែក្លាយទៅជាកន្លែងធ្វើទារុណកម្ម ។ ទាហានទាំងនោះបានឲ្យអ្នកកាសែតវៀតណាមពីរនាក់ថតភាពយន្តនិង


ច័ន្ទ ស្រីមុំ ឡើងសួរសំណួរទាក់ទងនឹងគេហទំព័រឃ្លាំមើលតុលាការខ្មែរក្រហម

រូបភាពដ៏ឃោរឃៅដែលប្រព្រឹត្តដោយខ្មែរក្រហម ។

ទោះបីជារូបភាពវីដេអូ ស-ខ្មៅ មិនសូវច្បាស់ហើយដៃរបស់អ្នកថតរូបមិននៅនឹងក៏ដោយ ស្រីមុំ បានចាប់អារម្មណ៍លើរូបភាពអ្នកទោសដែលស្លាប់ដោយសារការវះពោះ ។ រូបភាពនោះគឺនៅគុកទួលស្លែងដែលស្គាល់ថាជាមន្ទីរសន្តិសុខស-២១ ជាទីដែលខ្មែរក្រហមបានធ្វើទារុណកម្ម និងសម្លាប់មនុស្សប្រហែលមួយម៉ឺនបួនពាន់នាក់ ។

ខណៈដែលកញ្ញា ជា ដល្លា ប្រធានក្រុមឃ្លាំមើលសាលាក្តីខ្មែរក្រហមបានស្នើសុំយោបល់តបពីនិស្សិតទាំងអស់ចំពោះការចាក់ផ្សាយភាពយន្តឯកសារ ។ ស្រីមុំ គឺជាមនុស្សដំបូងដែលលើកដៃ ។ ស្រីមុំ បានប្រាប់និស្សិតដទៃដោយទឹកមុខក្រៀមក្រំ និងចងកំហឹងថា «ខ្ញុំមានការសោកស្តាយចំពោះមនុស្សដែលបានបាត់

បង់ជីវិត ។ ស្ថានភាពនៅក្នុងគុកនោះមើលទៅដូចឋាននរក ។ ខ្ញុំចង់ថ្កោលទោសដល់មនុស្សដែលបានធ្វើរឿងនេះ» ។

## កម្មវិធីធ្វើដំណើរអប់រំ

ស្រីមុំ គឺនិស្សិតម្នាក់ក្នុងចំណោមនិស្សិតប្រហែលជា១០០ នាក់ ដែលបានចូលរួមសិក្ខាសាលានៃការធ្វើបទបង្ហាញនៅសាកលវិទ្យាល័យឯកទេសកម្ពុជា ខេត្តកំពង់ធំ ។

កម្មវិធីធ្វើដំណើរអប់រំគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការលើកស្ទួយការយល់ដឹងអំពីសម័យកាលដ៏ខ្មៅងងឹតក្នុងចំណោមប្រជាជនកម្ពុជាទាំងមូល ។ មានការប៉ាន់ស្មានមួយបង្ហាញថា ប្រជាជនចន្លោះចាប់ពី១.៧លាននាក់ដល់២.២លាននាក់ បានស្លាប់ដោយសារការបង្អត់អាហារ ការធ្វើទារុណកម្ម និងការសម្លាប់ក្រោមរបបខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ កញ្ញា ជា ផល្លា បាននិយាយថា មានយុវជនតិចតួចនៅឡើយដែលបានយល់ដឹងអំពីព្រឹត្តិការណ៍កាលពីរបបខ្មែរក្រហម ។

ក្នុងឆ្នាំ២០០៨ ក្រសួងអប់រំ យុវជន និងកីឡា បានតម្រូវឲ្យសាលាមធ្យមសិក្សាដាក់បញ្ចូលប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហមក្នុងកម្មវិធីសិក្សារបស់ខ្លួន ។ អំឡុងពេលការធ្វើបទបង្ហាញនៅសាកលវិទ្យាល័យនេះ ក្រុមឃ្លាំមើលសាលាក្តីខ្មែរក្រហមបានចែកសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រុមឃ្លាំមើលសាលាក្តីខ្មែរក្រហមបានចែកចាយព្រឹត្តិប័ត្រសំណុំរឿង០០២ ចំនួន២០០ច្បាប់ស្តីពីថាតើមេដឹកនាំខ្មែរក្រហមកំពូលរូបណាដែលត្រូវវិនិច្ឆ័យ? ព្រឹត្តិប័ត្រសង្ខេបការណ៍ដំណើរការកាត់ទោសខ្មែរក្រហម និងទស្សនាវដ្តី «ស្វែងរកការពិត» ។

បន្ទាប់ពីបានបង្ហាញភាពយន្តឯកសារដល់និស្សិតទាំង កញ្ញា ជា ផល្លា បានធ្វើបទបង្ហាញពីមន្ទីរសន្តិសុខស-២១ ហើយបានទទួលចម្លើយតបពីនិស្សិតស្តីពីបទពិសោធន៍ និងការយល់ឃើញទាក់ទងនឹងរបបខ្មែរក្រហម ។ អ្នកស្រី គីម សុវណ្ណដានី បានផ្តល់នូវបទបង្ហាញអំពីគេហទំព័រឃ្លាំមើលសាលាក្តីខ្មែរក្រហមដែលមានទាំងភាសាខ្មែរ និងភាសាអង់គ្លេស ។ អ្នកស្រី គីម សុវណ្ណដានី បានគូសបញ្ជាក់អំពីសារសំខាន់បីយ៉ាងនៅលើគេហទំព័រ ៖ គេហទំព័រ



ព្រះសង្ឃដែលជានិស្សិតឡើងសួរសំណួរ

បញ្ចេញមតិ (Blog) ផ្នែកវីដេអូ (Multimedia) ផ្នែកព័ត៌មាន (News Sections) ។ អ្នកស្រីបាននិយាយថា គេហទំព័របញ្ចេញមតិដែលបានដាក់បញ្ចូលព័ត៌មានថ្មីជាទៀងទាត់គឺជាមធ្យោបាយដ៏សំខាន់ក្នុងការផ្តល់ការយល់ដឹងអំពីដំណើរការជំនុំជម្រះក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់មក អ្នកស្រីបានបង្ហាញនិស្សិតអំពីផ្នែកវីដេអូដែលរួមមានវីដេអូខ្លីៗស្តីពីការជំនុំជម្រះ បទសម្ភាសន៍តាមខ្សែវីដេអូនិងគម្រោងការចងចាំអំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ ជាចុងក្រោយ អ្នកស្រីបានចង្អុលបង្ហាញដល់និស្សិតទាំងអស់ក្នុងការស្វែងរកអត្ថបទ បទវិចារណកថា និងបទអត្ថាធិប្បាយផ្សេងទៀត ។

ផ្នែកចុងក្រោយនៃការធ្វើបទបង្ហាញ លឹម ជ័យច័ត្ត បានធ្វើបទបង្ហាញស្តីពីដំណើរវិវឌ្ឍន៍នៃដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញជាទីដែលមេដឹកនាំកំពូលខ្មែរក្រហមមួយចំនួនកំពុងតែត្រូវបានផ្តន្ទាទោស ។

និស្សិតជាច្រើនដែលចូលរួមភាគច្រើនរៀនខាងជំនួញ និងហិរញ្ញវត្ថុ ។ និស្សិតទាំងនោះបានសិក្សានៅថ្ងៃសៅរ៍ និងអាទិត្យដូច្នេះហើយ និស្សិតទាំងនោះអាចធ្វើការងារពេញម៉ោងបាន ។ អំឡុងពេលការស្ទាបស្ទង់មតិ និស្សិតដែលចូលរួមក្នុងកម្មវិធីធ្វើបទបង្ហាញនៅថ្ងៃទី២២ ខែមិថុនា ក្រុមឃ្លាំមើលសាលាក្តីខ្មែរក្រហម

បានរកឃើញថា ប្រហែលជា៨៥ភាគរយនៃនិស្សិតចូលរួមគឺកើតក្រោយរបបខ្មែរក្រហម ។ និស្សិតដទៃទៀតមានអាយុលើស ៣០ឆ្នាំ ។ មានតែប្រាំបីភាគរយនៃសិស្សទាំងនោះបាននិយាយថា មានអ៊ីមែលប្រើប្រាស់ ។ ដប់ភាគរយអាចប្រើប្រាស់អ៊ីនធឺណេតបាន ។

អំឡុងពេលធ្វើបទបង្ហាញ កញ្ញា ជា ដល្លា បានកត់សម្គាល់ថា មនុស្សមួយចំនួននៅក្នុងថ្នាក់រៀនអាចនឹងក្លាយទៅជាមេដឹកនាំនៅពេលអនាគត ។ កញ្ញា បានបន្ថែមដោយបញ្ជាក់អំពីខ្លឹមសារមួយក្នុងចំណោមខ្លឹមសារស្នូលនៃការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា "អ្នកត្រូវតែសិក្សាអំពីអតីតកាល ដើម្បីយល់ដឹងអំពីអនាគត" ។

ខេត្តកំពង់ធំ ដែលមានទីតាំងនៅភាគខាងជើងក្រុងភ្នំពេញត្រូវធ្វើដំណើរប្រមាណបួនម៉ោង ហើយខេត្តនេះមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ។ ខេត្តនេះគឺជាកន្លែងកំណើតរបស់អតីតមេដឹកនាំខ្មែរក្រហម ប៉ុល ពត (ឬសាឡុត ស) និងមេដឹកនាំមន្ទីរសន្តិសុខ ស-២១ កាំង ហ្គេកអ៊ាវ (ហៅឌុច) ។

ប្រជាជនកម្ពុជានិងនិស្សិតបានបញ្ចេញមតិមួយចំនួនបាននិយាយថា គាត់មានសមាជិកគ្រួសារដែលត្រូវបានបង្ខំឲ្យធ្វើការងារពលកម្មហើយត្រូវបានសម្លាប់ចោលចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។ ជាក់ស្តែង ស្រីមុំ បាននិយាយថា ឪពុកម្តាយរបស់គាត់ត្រូវបានបំបែកឲ្យទៅធ្វើការនៅវាលស្រែផ្សេងគ្នា ហើយមិនអាចទាក់ទងគ្នាបាន ។

ស្រីមុំ បាននិយាយថា មានពូម្នាក់ស្លាប់ក្រោយពេលជម្លៀសពីទីក្រុងភ្នំពេញដោយត្រូវឡានបុក ។ អ៊ំម្នាក់របស់ស្រីមុំ គឺជាទាហាន លន់ នល់ ។ ស្រីមុំ បាននិយាយថា មន្ត្រីរដ្ឋាភិបាល លន់ នល់ បានប្រាប់អ៊ំរបស់គាត់ថានឹងយកអ៊ំគាត់និងគ្រួសារចេញពីប្រទេសកម្ពុជាដោយសារដឹងថាខ្មែរក្រហមនឹងចូលមក ។ គ្រួសាររអ៊ំរបស់ ស្រីមុំ បានរត់គេចខ្លួន ប៉ុន្តែមន្ត្រីផ្សេងទៀតបានប្រាប់អ៊ុំរបស់ ស្រីមុំ ឲ្យរង់ចាំមេរបស់ខ្លួននៅភ្នំពេញមុននឹងចាកចេញ ។ មនុស្សដដែលនោះក៏បានសម្លាប់អ៊ំរបស់ស្រីមុំ ។

**បាបារ៉ា ហ្សឺរ៉ាណូ និង អាស្លី ស្មិតហ្សឺ**



និស្សិតនិងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យឯកទេសកម្ពុជា ខេត្តកំពង់ធំ ថតរូបជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០១៣

# បូជនីយដ្ឋាន និង ការចងចាំ : អណ្ដូងស្រះមោល

មិនឆ្ងាយប៉ុន្មាន បូជនីយដ្ឋានមួយអាចមើលពីទីរួមខេត្តបាត់ដំបង ។ មានទីតាំងនៅលើវាលមួយខាងក្រោយវត្ត មានសំណង់បូជនីយដ្ឋានរាងចតុកោណមួយដែលមានបង្អួចកញ្ចក់នៅជុំវិញនិងមានសំណល់ឆ្អឹងមនុស្សដែលបានស្លាប់ក្នុងរបបខ្មែរក្រហមពេញនៅក្នុងនោះ ។ នៅជុំវិញបូជនីយដ្ឋាននោះ មានចម្លាក់ថ្មជាច្រើនដែលរៀបរាប់អំពីហេតុការណ៍កាលពីរបបកម្ពុជាប្រជាធិបតេយ្យនៅពេលដែលខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជា ។ នៅជិតបូជនីយដ្ឋាននោះជាវត្តសំរោងក្នុង គឺជាវត្តមួយដែលខ្មែរក្រហមធ្លាប់ប្រើប្រាស់ជាគុក និងជាទីតាំងសួរចម្លើយ ។ អក្សរចរិកនៅលើបូជនីយដ្ឋាននោះបានរៀបរាប់ថា មនុស្សចំនួន ១០០.០៨ ត្រូវបានសម្លាប់នៅទីនោះ ។ អ្វីដែលគួរឲ្យរន្ធត់នោះគឺថា អ្នកស្រុកដែលរស់នៅទីនោះបាននិយាយថា ឆ្អឹង និងលលាដ៏ក្បាលដែលតាំងនៅក្នុងបូជនីយដ្ឋាននោះត្រូវបានគាស់ចេញពីរណ្ដៅមួយដែលជាគ្រឹះរបស់បូជនីយដ្ឋាននេះតែម្ដង ។ ពេលយើងនិយាយអំពីប្រវត្តិបូជនីយដ្ឋានទៅកាន់អាចារ្យ និងដូនជីនៅវត្តនោះ គាត់បានប្រាប់យើងថា ជាទូទៅ មានបរទេសខ្លះបានមកទស្សនាបូជនីយដ្ឋាននេះដែរ ។ អាចារ្យនិងដូនជីបាននិយាយទៀតថា សាច់ញាតិរបស់អ្នកដែលបានស្លាប់ក៏បានមកទស្សនាទីតាំងនេះ និងបានយកផ្កាមកបូជាដែរ តែកម្រមានណាស់ ។

ចម្ងាយប្រមាណជា១០០គីឡូម៉ែត្រពីវត្តសំរោងក្នុង តាមផ្លូវជាតិលេខ៥៧ គឺជាទីរួមខេត្តប៉ៃលិន ។ ទីតាំងខេត្តប៉ៃលិនគឺជាតំបន់ដែលធ្លាប់គ្រប់គ្រងដោយកងទ័ពដែលស្មោះនឹងមេដឹកនាំខ្មែរក្រហម អៀង សារី ។ អៀង សារី បានផ្ដាច់ខ្លួនចូលមករួមរស់ជាមួយរដ្ឋាភិបាល និងទទួលបាននូវការអភ័យទោស និងការលើកលែងទោសពីសំណាក់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ក្នុងឆ្នាំ១៩៩៦ ។ ក្រោយពីចុះចូលជាមួយរដ្ឋាភិបាល កងទ័ពខ្មែរក្រហម




រូបចម្លាក់ថ្មដែលរៀបរាប់ពីហេតុការណ៍ក្នុងរបបខ្មែរក្រហម នៅវត្តសំរោង ក្នុងខេត្តបាត់ដំបង


មន្ទីរឃុំឃាំងវត្តសំរោង ក្នុងខេត្តបាត់ដំបង

ជាច្រើនបានផ្លាស់ប្តូរជីវិតពីកងទ័ព មកជាប្រជាជនស៊ីវិលវិញ និងបានរស់នៅក្នុងទីតាំងដដែលគឺខេត្តប៉ៃលិននេះ ។ សព្វថ្ងៃ ភាគច្រើននៃអ្នកទាំងអស់នេះកំពុងរស់នៅទីនេះ ។ ទោះបីជារបបខ្មែរក្រហមដួលរលំហើយក៏ដោយ ផ្នត់គំនិត “អង្គការ” នៅតែឋិតនៅក្នុងចិត្តនិងការគិតរបស់អតីតកម្មាភិបាលខ្មែរក្រហមនោះនៅឡើយ ។ នៅខេត្តប៉ៃលិននេះ យើងបានជួបប្រទះនូវភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងអ្នកដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម និងក្មេងដែលកើតក្រោយរបបនេះ ។


អតីតកម្មាភិបាលខ្មែរក្រហមនៅប៉ៃលិន

កើតក្នុងឆ្នាំ១៩៧៧ អតីតកម្មាភិបាលខ្មែរក្រហមម្នាក់មានអាយុជាងមួយឆ្នាំប៉ុណ្ណោះពេលដែលរបបខ្មែរក្រហមដួលរលំក្នុងខែមករា ឆ្នាំ១៩៧៩ ។ ប៉ុន្តែ អតីតកម្មាភិបាលខ្មែរក្រហមរូបនេះនៅតែរៀបរាប់ថា របបខ្មែរក្រហមជារបបមួយដែលមិនមានជំងឺអេដស៍ ពេស្យាចារ្យ និងអំពើឆក់ប្លន់នានាៗឡើយ ។ ស្ថិតក្នុងសម្លៀកបំពាក់យោធាខ្មែរក្រហមផ្តល់ជំនួយដោយចិនកាលពីទសវត្សរ៍៨០ អតីតកម្មាភិបាលខ្មែរក្រហមរូបនោះបានបង្ហាញនូវការកោតសរសើរយ៉ាងជ្រាលជ្រៅដល់មនោគមវិជ្ជាខ្មែរក្រហម ព្រមទាំងបានព្យាយាមបកស្រាយអំពីហេតុការណ៍កាប់សម្លាប់ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

កម្មាភិបាលរូបនោះបាននិយាយថា “សង្គមកម្ពុជាហាក់បីដូចជាកសិដ្ឋានមួយអ៊ីចឹង ។ នៅពេលដែលកសិដ្ឋាននោះមានសត្វពាហនៈច្រើនណែនណាន់តាន់តាប់ពេក សត្វពាហនៈដែលមិនសូវល្អ និងម្ចាស់មិនសូវពេញចិត្ត និងត្រូវសម្លាប់ចោលដើម្បីការពារសត្វពាហនៈផ្សេងទៀត” ។ កម្មាភិបាលរូបនោះគាំទ្រនូវកិច្ចប្រឹងប្រែងរបស់ខ្មែរក្រហមយ៉ាងពេញទំហឹងដែលបានលុបបំបាត់ចោលនូវជំងឺសង្គម ។ គាត់បានបន្តថា “ក្នុងរបបខ្មែរក្រហមមិនមានពេស្យាចារ្យ មិនមានអេដស៍ និងមិនមានអំពើឆក់ប្លន់ទេ ។ ខ្ញុំគិតថានេះគឺជាចំណុចល្អមួយ” ។ ទោះបីជាគាត់គិតថារបបខ្មែរក្រហមល្អបែបនេះក៏ដោយ ក៏គាត់ទទួលស្គាល់ថា របបខ្មែរក្រហមបានសម្លាប់មនុស្សជាច្រើនដែល “ជារឿងពិបាកនឹងជឿដែលថាខ្មែរក្រហមសម្លាប់មនុស្សច្រើនបែបនេះ” ។

នៅពេលសួរអំពីអារម្មណ៍របស់គាត់អំពីថ្នាក់ដឹកនាំរបស់ខ្មែរក្រហម អតីតកម្មាភិបាលរូបនេះបានឆ្លើយថា ការដាក់ឲ្យមានការទទួលខុសត្រូវចំពោះតែអ្នកដែលមានដំណែងខ្ពស់បំផុតនោះហាក់ដូចជាអ្វីដែល តាម៉ុក ធ្លាប់និយាយថា “ស៊ីមួយតុឲ្យ តាម៉ុកចេញលុយតែម្នាក់ឯង!” ។ តាម៉ុក គឺជាអតីតមេបញ្ជាការខ្មែរក្រហមដ៏អសោចម្នាក់ដែលបានស្លាប់ក្នុងឆ្នាំ២០០៦ ពេលកំពុងតែរង់ចាំការកាត់ទោស ។

ការឈរទល់មុខគ្នាដូច្នេះជាមួយអតីតទាហានខ្មែរក្រហមម្នាក់ដែលបានរៀបរាប់ពីការសម្លាប់ ដោយឈរនៅលើកំពូលភ្នំដ៏ស្រស់ស្អាតបែបនេះហាក់បីដូចជារឿងចម្លែកមួយ ហើយប៉ៃលិនធ្លាប់ជាតំបន់ដែលធ្លាប់គ្រប់គ្រងដោយខ្មែរក្រហមដែលជាអ្នកសម្លាប់មនុស្ស ។

តំបន់ប៉ៃលិននេះគឺជាទីតាំងមួយនៃក្រុមមួយដែលបង្កឲ្យមានអំពើឃោរឃៅដ៏ធំមួយក្នុងសតវត្សរ៍ទី២០នេះ ។

**សែម៉ុន គ្រូសេុី និង ចច រ៉ាយត៍**

# ការអត់ឃ្លាន និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

## សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

***កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី៥)***

*វគ្គទី៥ នេះ នឹងផ្តោតសំខាន់ទៅលើការអត់ឃ្លាន និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យើងនឹងបកស្រាយអត្ថន័យនៃពាក្យ “ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ” ព្រមទាំងលើកយកឧក្រិដ្ឋកម្មផ្សេងៗមកពិភាក្សាដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មទាំងនោះទៅនឹងភាពអត់ឃ្លាន ដែលបានកើតនៅក្នុងបរិបទទូទៅក៏ដូចជានៅក្នុងប្រទេសកម្ពុជា ។*

*រយៈពេលថ្មីៗកន្លងទៅនេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកំពុងស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីបានពោលរៀបរាប់ពីរឿងរ៉ាវផ្ទួរចត់របស់ខ្លួនដែលផ្តោតទៅលើភាពលំបាកវេទនា អំពើហិង្សា និងភាពអត់ឃ្លានដែលខ្លួនបានជួបប្រទះ ។ ទន្ទឹមនឹងការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម នួន ជា បានសម្តែងនូវការសោកស្តាយ និងបានឆ្លើយទទួលខុសត្រូវដោយផ្នែកចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ នួន ជា បានលើកឡើងថា ៖ “ក្នុងនាមជាមេដឹកនាំខ្មែរក្រហមមួយរូប ខ្ញុំមិនមែនគេចពីការទទួលខុសត្រូវទេ ។ ខ្ញុំសូម*



*កងកុមារត្រូវបានបង្ខំឲ្យរែកដីនៅក្នុងរបបខ្មែរក្រហម ជិតស្ទឹងព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ ក្នុងអំឡុងឆ្នាំ១៩៧៧*

ចូលរួមចំណែកទទួលខុសត្រូវ ។ ប៉ុន្តែខ្ញុំគ្មានតួនាទីអីខាងនីតិប្រតិបត្តិទេ» ។ នួន ជា ក៏បានបញ្ជាក់បន្ថែមទៀតថា ៖ «ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ការខូចខាត ការគ្រោះថ្នាក់របស់ជាតិខ្ញុំ ក្នុងឋានៈខ្ញុំជាអ្នកទទួលនាទីដឹកនាំ ខ្ញុំត្រូវតែទទួលការខុសត្រូវ ។ ខ្ញុំសូមទទួលដោយស្មោះអស់ពីដួងចិត្ត ។ ខ្ញុំសោកស្តាយណាស់ចំពោះព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងដោយចេតនា ឬអចេតនា ។ ហើយទោះបីជាខ្ញុំដឹង ឬមិនដឹងក៏ដោយ» ។ ទោះបីជាសេចក្តីថ្លែងការណ៍របស់ នួន ជា មិនបានបង្ហាញពីការទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មកលើខ្លួនក៏ដោយ ក៏សេចក្តីថ្លែងការណ៍នេះ បានបង្ហាញថា នួន ជា បានទទួលខុសត្រូវចំពោះការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនខ្លួនក្នុងរបបខ្មែរក្រហម ។

## តើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាអ្វី?

ពាក្យ «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ត្រូវបានប្រើប្រាស់ដំបូងបង្អស់ដើម្បីសំដៅទៅលើឧក្រិដ្ឋកម្មអន្តរជាតិមួយដែលបានកើតឡើងនៅក្នុងឆ្នាំ១៩១៥ ។ នៅពេលនោះ រដ្ឋាភិបាលបារាំង អង់គ្លេស និងសូវៀត បានចេញសេចក្តីប្រកាសរួមគ្នាមួយដើម្បីចោទប្រកាន់ជនជាតិអាមេនី (Armenia) ពីបទសម្លាប់រង្គាលនៅក្នុងចក្រភពទួរគីអូតូម៉ង់ (Turkish Ottoman Empire) ។ ការសម្លាប់នេះត្រូវបានទទួលស្គាល់ថាជា «ឧក្រិដ្ឋកម្មថ្មីដែលប្រឆាំងនឹងមនុស្សជាតិ និងអារ្យធម៌ជនជាតិទួរគី» ដែលក្នុងនោះរួមមាន «សមាជិក និងភ្នាក់ងារទាំងអស់នៃចក្រភពអូតូម៉ង់ (Ottoman Empire) ដែលជាប់ពាក់ព័ន្ធទៅនឹងវិនាសកម្មនេះ» ។ បើទោះបីជាពុំមានការកាត់ក្តីណាមួយត្រូវបានធ្វើឡើងក៏ដោយ ប៉ុន្តែសន្និសញ្ញានេះបានក្លាយជាចំណុចចាប់ផ្តើមនៃការកើតមានច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ បន្ទាប់ពីសង្គ្រាមលោកលើកទី២ ។ ជាក់ស្តែង លោក អាប់ឌុល អ៊ីចម៉ាន់ (Adolf Eichmann) ត្រូវបានតុលាការថ្នាក់ស្រុករបស់ប្រទេសអ៊ីស្រាអែល ផ្តោលទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ បន្ទាប់មក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានតុលាការជាច្រើនដូចជា នៅប្រទេសយូហ្គោស្លាវី (Yugoslavia)



*ការដ្ឋានសាងសង់ទំនប់ទឹកក្នុងរបបខ្មែរក្រហម*

រ៉្វាន់ដា (*Rwanda*) សេរ៉ាឡេអូន (*Sierra Leone*) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម យកមកប្រើប្រាស់ដើម្បីចោទប្រកាន់ជនជាប់ចោទ ។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាសំណុំនៃឧក្រិដ្ឋកម្មដែលត្រូវបានដាក់បញ្ចូលក្នុងកម្រិតច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ដែលឧក្រិដ្ឋកម្មនេះឆ្លុះបញ្ចាំងនូវ «ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល» ។ ការវាយប្រហារជាទូទៅ សំដៅទៅលើការវាយប្រហារដែលកើតឡើងពេញផ្ទៃប្រទេស ឬកើតឡើងក្នុងរយៈពេលយូរ ។ រីឯការវាយប្រហារជាប្រព័ន្ធ គឺជាការវាយប្រហារដោយចំពោះ ដែលមានគម្រោង និងការរៀបចំទុកជាមុន ។ ចំណុចទាំងពីរខាងលើនេះ គឺជាសមាសធាតុយោងសំខាន់ ដើម្បីអាចកាត់សេចក្តីបានថា ជនណាម្នាក់ជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យើងអាចកាត់សេចក្តីថា ជនណាម្នាក់ជាប់ចោទពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិបាន លុះត្រាតែការវាយប្រហារទាំងពីរខាងលើនេះត្រូវបានបង្ហាញឲ្យឃើញ ។ ជាក់ស្តែង នៅក្នុងបរិបទនៃរបបខ្មែរក្រហម យើងសង្កេតឃើញមានសកម្មភាពជាច្រើន ដែលស្ថិតក្នុងការវាយប្រហារទាំងពីរដែលបានរៀបរាប់ខាងដើមដែលខ្មែរក្រហមបានប្រព្រឹត្តលើប្រជាជនកម្ពុជា ដូចជា ការកាប់សម្លាប់ ការរំលោភបំពាន ការបង្ខំឲ្យធ្វើការហួសកម្លាំង និងគោលនយោបាយផ្សេងៗទៀត ដែលសុទ្ធសឹងតែបានប្រព្រឹត្តឡើងជាទូទៅ និងជាប្រព័ន្ធ ។ មិនតែប៉ុណ្ណោះ សកម្មភាពទាំងនេះបានកើតឡើងក្នុងទ្រង់ទ្រាយធំស្ទើរគ្រប់តំបន់នៃប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម និងមានរយៈពេលរហូតដល់ជាងបីឆ្នាំ ។ ជាងនេះទៅទៀត សកម្មភាពទាំងនោះត្រូវបានបញ្ជាដោយផ្ទាល់ពីបក្សកុម្មុយនិស្តកម្ពុជាដែលមានទីតាំងកណ្តាលនៅទីក្រុងភ្នំពេញ ។ ដូច្នេះ ក្នុងចំណោមឧក្រិដ្ឋកម្មអន្តរជាតិទាំងបី រួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្រ្គាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាបទចោទប្រកាន់មួយ ដែលអាចយកមកធ្វើការចោទប្រកាន់បានចំពោះការឈឺចាប់ និងស្លាប់បាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាដែលបង្កឡើងដោយខ្មែរក្រហម ។

ទន្ទឹមនឹងនេះ គោលនយោបាយដទៃទៀតរបស់ខ្មែរក្រហមដែលទាក់ទងទៅនឹងលក្ខខណ្ឌរស់នៅដូចជា កង្វះខាតចំណីអាហារ ការធ្វើការហួសកម្លាំង និងការគំរាមធ្វើទារុណកម្មចំពោះជនណាដែលលួចរកអាហារបន្ថែម ក៏អាចចាត់ទុកថាជាផ្នែកមួយដែលនាំឲ្យមានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធទៅលើប្រជាជនកម្ពុជាដែរ ។ ជាបន្តទៅទៀត យើងនឹងធ្វើការបកស្រាយអំពីទំនាក់ទំនងរវាងការអត់ឃ្លាន និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗ ។

## ការសម្លាប់រង្គាល

ការសម្លាប់រង្គាល គឺជាឧក្រិដ្ឋកម្មមួយដែលកើតចេញពីការសម្លាប់ក្នុងទ្រង់ទ្រាយធំដោយផ្ទាល់ ឬដោយប្រយោល រួមមាន «ការបង្ខំជនណាម្នាក់ឲ្យរស់នៅក្នុងស្ថានភាពលំបាកដែលអាចបណ្តាលឲ្យជននោះបាត់បង់ជីវិត» ។ យោងតាមមាត្រា៧ នៃច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ថា ការសម្លាប់រង្គាលអាចធ្វើឡើងតាមរយៈ «ការបង្អត់អាហារ និងថ្នាំសង្កូវ» ។ នៅក្នុងរបបខ្មែរក្រហម ភាពអត់ឃ្លានដែលបានបង្កឲ្យមនុស្សរាប់សែននាក់ស្លាប់បាត់បង់ជីវិត បានឆ្លើយតបទៅនឹងនិយមន័យនៃ «ការសម្លាប់រង្គាល» ។ មិនតែប៉ុណ្ណោះ ការស្លាប់របស់ប្រជាជនកម្ពុជាដ៏ច្រើនសន្ធឹកសន្ធាប់នេះ បានកើតឡើងដោយសារគោលនយោបាយរបស់ខ្មែរក្រហម ដែលមជ្ឈិមបក្សបានដាក់ចេញ ។ គោលនយោបាយទាំងនោះរួមមាន ការបង្ខំឲ្យធ្វើការហួសកម្រិត ការបង្ខំឲ្យរស់នៅនិងហូបចុកជាសមូហភាព ការហាមមិនឲ្យធ្វើការបង្កបង្កើនផលជាលក្ខណៈឯកជន និងការគំរាមប្រើអំពើហិង្សា បានធ្វើឲ្យប្រជាជនកម្ពុជាទទួលរងនូវបាក់កម្លាំង និងទទួលទានអាហារមិនគ្រប់គ្រាន់ ។ ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថា ជាប់ចោទពីបទសម្លាប់រង្គាល ក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លុះត្រាតែជននោះ «មានគោលបំណងបង្ខំប្រជាជនឲ្យរស់នៅក្នុងស្ថានភាពមួយដែលអាចបណ្តាលឲ្យពួកគាត់ស្លាប់បាត់បង់ជីវិតដោយការចាប់បង្ខំនេះធ្វើឡើងជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ» ។

ភស្តុតាងជាច្រើនដែលមិនអាចប្រកែកបានបង្ហាញថា ការអត់ឃ្លានពិតជាបានកើតឡើង និងមានសភាពកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ហើយមេដឹកនាំខ្មែរក្រហម

ក៏បានដឹងថាប្រជាជនរបស់ខ្លួនរាប់សែននាក់កំពុងតែជួបប្រទះការខ្វះខាតស្បៀងអាហារ ។ ភ័ស្តុតាងទាំងនោះមានដូចជា បទសម្ភាសជាមួយអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម និងសក្ខីកម្មនានាដែលបានរៀបរាប់នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បើទោះបីជា មេដឹកនាំខ្មែរក្រហមទាំងនោះដឹងថាប្រជាជនរបស់ខ្លួនកំពុងរងគ្រោះដោយសារការអត់ឃ្លានក៏មេដឹកនាំទាំងនោះនៅតែបន្តដាក់ចេញគោលនយោបាយផ្សេងៗទៀត ដែលបានបង្កឲ្យការអត់ឃ្លានមានសភាពធ្ងន់ធ្ងរឡើងៗ ។ ជាលទ្ធផលប្រសិនបើសមាជិកមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ពិតជាបានប្រព្រឹត្តនូវទង្វើដូចដែលបានរៀបរាប់ខាងលើនោះមែន នោះមេដឹកនាំខ្មែរក្រហមអាចនឹងជាប់ទោសពីបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារតែមេដឹកនាំខ្មែរក្រហមទាំងនោះ បានរួមចំណែកក្នុងការសម្លាប់ប្រជាជនកម្ពុជា តាមរយៈការបង្ខំឲ្យប្រជាជនទាំងនោះរស់នៅក្នុងភាពអត់ឃ្លាន ។ ហេតុដូច្នេះហើយ នៅក្នុងករណីខ្មែរក្រហម ក៏ដូចជាករណីផ្សេងទៀត ការសម្លាប់រង្គាល គឺជាឧក្រិដ្ឋកម្មអន្តរជាតិមួយដែលបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ ពីការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំតាមរយៈការបង្កឲ្យមានភាពអត់ឃ្លាន ។

## ការធ្វើទុក្ខបុកម្នេញ

បើទោះបីជាភាពអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម បានប៉ះពាល់ដល់ប្រជាជនទូទៅ ក៏ប៉ុន្តែ ការអត់ឃ្លានរបស់ជនដែលត្រូវបានចាត់ទុកជាសត្រូវនយោបាយរបស់បដិវត្តន៍រិតតែមានសភាពធ្ងន់ធ្ងរ ។ ជនទាំងនេះរួមមាន អ្នកដែលរស់នៅក្នុងតំបន់គ្រប់គ្រងរបស់រដ្ឋាភិបាល លន់ នល់ ដូចជា បញ្ញវន្ត អ្នករស់នៅទីក្រុង និងអតីតមន្ត្រីរាជការក្នុងរបប លន់ នល់ ត្រូវបានចាត់ទុកថាជា «ប្រជាជនថ្មី ឬ ប្រជាជន១៧ មេសា» ត្រូវបានបង្ខំឲ្យរស់នៅក្នុងលក្ខខណ្ឌលំបាកបំផុត ។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការធ្វើទុក្ខបុកម្នេញ គឺជាការបំបិទសិទ្ធិមូលដ្ឋានទាំងឡាយណា ដែលស្ថិតក្រោមការការពារនៃច្បាប់អន្តរជាតិ ។ ការធ្វើទុក្ខបុកម្នេញនោះ ធ្វើឡើងដោយចេតនា និង ប្រព្រឹត្តឡើងក្នុងគោលបំណងរើសអើងជាតិសាសន៍ សាសនា ឬនយោបាយណាមួយ ។ យោងតាមនិយមន័យខាងលើ ទង្វើដែលបានបង្កឡើងដោយមជ្ឈិមបក្សរបស់ខ្មែរក្រហមគួរត្រូវបានជាប់ទោសពីបទធ្វើទុក្ខបុកម្នេញ ព្រោះមេដឹកនាំខ្មែរក្រហមបានបង្ខំឲ្យប្រជាជនថ្មីរស់នៅក្នុងការអត់ឃ្លាន ។

មជ្ឈិមបក្សខ្មែរក្រហម បានដាក់បញ្ជាឲ្យជម្លៀសប្រជាជន «ថ្មី» ទៅកន្លែងណាត្រូវការកម្លាំងពលកម្មច្រើន ។ នៅតាមផ្លូវធ្វើដំណើរ ប្រជាជនថ្មីទាំងនោះមិនបានទទួលអាហារគ្រប់គ្រាន់នោះទេ ហើយកន្លែងដែលប្រជាជនថ្មីត្រូវបានជម្លៀសទៅ ពុំមានអាហារបរិភោគគ្រប់គ្រាន់ ឬផ្ទះស្នាក់នៅត្រឹមត្រូវនោះទេ ។ ជាក់ស្តែងការជម្លៀសប្រជាជននៅភូមិភាគពាយ័ព្យក្នុងទ្រង់ទ្រាយធំ ។ ទន្ទឹមនឹងនេះ ប្រជាជនថ្មី ត្រូវរស់នៅដោយកង្វះអនាម័យ និងចំណីអាហារមិនស្អាត ដែលជាមូលហេតុនៃការអត់ឃ្លាន និងជំងឺផ្សេងៗ ។ ជាមួយគ្នានេះដែរ មជ្ឈិមបក្សក៏បានចាត់ទុកប្រជាជនថ្មី ជាសត្រូវរបស់បដិវត្តន៍ ហើយបានចាត់ទុកអ្នកទាំងនោះគេថាជា «ជនបញ្ញើក្អែក» ទុកក៏មិនចំណេញ ដកចេញក៏មិនខាត ។ ប្រជាជនថ្មីនេះទៀតសោត ត្រូវបានខ្មែរក្រហមទម្លាក់កំហុស ក្នុងករណីដែលខ្មែរក្រហមតាមមូលដ្ឋាន មិនអាចសម្រេចបាននូវទិន្នផលកសិកម្មដែលបានដាក់ឲ្យដោយមជ្ឈិមបក្ស ។ ជាក់ស្តែង នៅពេលដែលទិន្នផលស្រូវមិនអាចសម្រេចបាន ប្រជាជនថ្មីត្រូវបានចាប់ខ្លួន និងបានបង្ខំឲ្យសារភាពថាបានបំផ្លិចបំផ្លាញផលដំណាំមុនពេលដែលប្រជាជនថ្មីនោះត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ។ ដូច្នេះ ការរើសអើងចំពោះប្រជាជនថ្មី រួមផ្សំនឹងលក្ខខណ្ឌរស់នៅលំបាកវេទនា អាចបំពេញនូវធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ ដោយការបង្ខាំងសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនថ្មីទាំងនោះ ដែលពាក់ព័ន្ធនឹងសុខភាព សេចក្តីថ្លៃថ្នូរ និងរូបរាងកាយ ។

## អំពើអមនុស្សធម៌ផ្សេងៗ

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីអំពើអមនុស្សធម៌ដទៃទៀត គឺជាទង្វើទាំងឡាយដែលបង្ហាញពីការធ្វើទុក្ខទោសទៅលើជនស៊ីវិល ដែលមិនមែនជាការសម្លាប់រង្គាល ឬការធ្វើទុក្ខបុកម្នេញដូចបានរៀបរាប់ខាងលើ ។ ប៉ុន្តែ អំពើអមនុស្សធម៌នោះក៏មានស្ថានទម្ងន់ទោសធ្ងន់ធ្ងរដែរ ។ គណៈកម្មាធិការច្បាប់អន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ៉្វាន់ដា បានធ្វើសេចក្តីសន្និដ្ឋានថា ស្ថានទម្ងន់ទោសធ្ងន់ធ្ងរ

សំដៅទៅលើទង្វើទាំងឡាយណា ដែលបង្ករបួសដល់ជនរងគ្រោះ ជាពិសេសទៅលើរូបរាងកាយ សតិអារម្មណ៍ សុខភាព ក៏ដូចជាភាពថ្លៃថ្នូររបស់បុគ្គលនោះ ។

ការរងគ្រោះដោយសារការអត់ឃ្លាន រួមមាន ការប៉ះពាល់ផ្នែកផ្លូវកាយ និងសតិអារម្មណ៍ ព្រមទាំងសុខភាព និងភាពថ្លៃថ្នូររបស់មនុស្ស ។ ផលប៉ះពាល់ដែលបានរៀបរាប់នេះ បានកើតមានចំពោះប្រជាជនកម្ពុជាក្នុងអំឡុងពេលដែលមានការអត់ឃ្លានកើតឡើងនៅក្នុងរបបខ្មែរក្រហមអស់រយៈពេលជាងបីឆ្នាំ ។ នៅក្នុងអំឡុងពេលនៃភាពអត់ឃ្លាននេះ កម្លាំងកាយរបស់ប្រជាជនកម្ពុជាបានចុះទ្រុឌទ្រោមជារៀងរាល់ថ្ងៃ ដោយសារតែកង្វះខាតអាហារបរិភោគ ការធ្វើការងារហួសកម្លាំង និងការប្រឈមមុខនឹងអំពើហិង្សាជាប្រចាំ ។

ជាការពិតណាស់ នៅពេលដែលយើងសួរអំពីបទពិសោធជីវិតរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ជនរងគ្រោះទាំងនោះតែងតែសង្កត់ធ្ងន់ទៅលើការអត់ឃ្លាន ដែលជាកត្តាចម្បងដែលចង់ឲ្យតុលាការលើកឡើងនៅក្នុងការកាត់សេចក្ដី ។ លើសពីនេះទៅទៀត ដូចដែលបានពិភាក្សាពីខាងលើ ប្រសិនបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចបញ្ជាក់បានថា មជ្ឈិមបក្សបាន ដឹងថា ប្រជាជនកម្ពុជាកំពុងរស់នៅក្នុងស្ថានភាពអមនុស្សធម៌ ដូចជាការអត់ឃ្លានធ្ងន់ធ្ងរ ប៉ុន្តែ មេដឹកនាំទាំងនោះនៅតែបន្តអនុវត្តគោលនយោបាយរបស់ខ្លួន នោះមេដឹកនាំទាំងនោះត្រូវតែទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីអំពើអមនុស្សធម៌ផ្សេងៗ ដោយសារតែមេដឹកនាំទាំងនោះបានបង្កប្រជាជនកម្ពុជារស់នៅក្នុងស្ថានភាពលំបាកវេទនា ជាពិសេសបង្កឲ្យមានភាពអត់ឃ្លានកើតឡើង ។

អំពើអមនុស្សធម៌ គឺជាបទឧក្រិដ្ឋមួយដ៏សំខាន់សម្រាប់បរិយាយអំពីរឿងរ៉ាវទាំងមូលនៃការរងគ្រោះដោយសារភាពអត់ឃ្លានដែលកើតមានឡើងក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ។ នេះក៏ដោយសារតែការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញពាក់ព័ន្ធទាំងស្រុងទៅនឹងការសម្លាប់ជាទ្រង់ទ្រាយធំ និងការធ្វើទុក្ខបុកម្នេញទៅលើក្រុមមនុស្សណាមួយដោយចំពោះ ។ ផ្ទុយទៅវិញ អំពើអមនុស្សធម៌រួមបញ្ចូលនូវទុក្ខលំបាកវេទនាជាទូទៅ បើទោះបីជាទុក្ខលំបាកវេទនានោះមិនបានបង្កឲ្យមានការស្លាប់បាត់បង់ជីវិតក៏ដោយ ហើយអំពើអមនុស្សធម៌នោះបានកើតឡើងដល់ប្រជាជនស៊ីវិលទាំងអស់ ដោយមិនរើសអើងចំពោះជនជាតិណាមួយឡើយ ។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្តីពីអំពើអមនុស្សធម៌អាចត្រូវបានយកមកចោទប្រកាន់មេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តតាមរយៈគោលនយោបាយរបស់ខ្លួន ទៅលើរូបរាងកាយ និងសតិអារម្មណ៍របស់ជនរងគ្រោះ ។ រហូតមកដល់សព្វថ្ងៃនេះ ការប៉ះទង្គិចផ្លូវចិត្ត និងបញ្ហាសុខភាព នៅតែបន្តជាបញ្ហាប្រឈមដល់អ្នកដែលរស់រានមានជីវិតពីភាពអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមនៅឡើយ ។

ជាសរុប យើងអាចសន្និដ្ឋានបានថា គោលនយោបាយរបស់មជ្ឈិមបក្សខ្មែរក្រហម បានបង្កឲ្យមានភាពអត់ឃ្លាននៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ហើយបានបង្កជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារតែទង្វើរបស់ខ្មែរក្រហមបានបង្កឲ្យមានផលប៉ះពាល់ "ជាទូទៅ" និង "ជាប្រព័ន្ធ" ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃផ្សេងទៀត អាចយកមកប្រើប្រាស់ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលពាក់ព័ន្ធនឹងសោកនាដកម្មទាំងឡាយដែលបានកើតឡើងដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អាចនឹងមិនលើកយកបញ្ហាដែលពាក់ព័ន្ធនឹងលក្ខខណ្ឌរស់នៅ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមមកពិភាក្សាជាពិស្តារ ហើយកម្មវិធីវិទ្យុរបស់យើងខ្ញុំ ក៏មិនមានចេតនាបង្ខំឲ្យតុលាការលើកពីបញ្ហានេះមកកាត់សេចក្ដីឲ្យដោយខាងតែបាននោះទេ ។ មិនតែប៉ុណ្ណោះ ប្រសិនបើមិនមានសាលក្រមចុងក្រោយរបស់តុលាការថាឧក្រិដ្ឋកម្មដែលបានលើកឡើងខាងលើត្រូវបានចោទប្រកាន់ចំពោះការអត់ឃ្លានដែលបានកើតឡើងនោះទេ ដូច្នេះវាស្ថិតនៅលើទស្សនៈរបស់បុគ្គលម្នាក់ៗ អំពីបទឧក្រិដ្ឋដែលខ្មែរក្រហមបានប្រព្រឹត្ត ជាពិសេសការបង្កឲ្យមានភាពអត់ឃ្លានចំពោះប្រជាជនកម្ពុជា នៅក្នុងសម័យខ្មែរក្រហម ថាតើវាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬទេ ។

**រ៉ែនឌុល ដីហ្សាល់ក្ស**

# ខៀវ សំផន នឹងនៅតែបន្តឃុំខ្លួន ទោះបីរកមិនឃើញកំហុសនៅក្នុងសំណុំរឿង០០២/១

ខៀវ សំផនគឺជាជនជាប់ចោទមួយរូប ក្នុងចំណោមជនជាប់ចោទបួនរូបក្នុងសំណុំរឿង០០២ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ បទចោទប្រកាន់ទាំងអស់នេះ សុទ្ធសឹងជាបទឧក្រិដ្ឋធ្ងន់ធ្ងរនៅក្នុងរឿងក្ដីព្រហ្មទណ្ឌអន្តរជាតិ ។

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ខៀវ សំផន ត្រូវបានចាប់ខ្លួន និងបញ្ជូនមកឃុំខ្លួនបណ្ដោះអាសន្ននៅមន្ទីរឃុំឃាំងរបស់សាលាក្ដីខ្មែរក្រហម សម្រាប់រយៈពេលមួយឆ្នាំ តាមអំណាចនៃដីកាឃុំខ្លួនបណ្ដោះអាសន្នដែលចេញដោយសហចៅក្រមស៊ើបអង្កេត ។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចពន្យារពេលឃុំខ្លួន ខៀវ សំផន ជាបណ្ដោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំទៀត ដើម្បីបន្តធ្វើការស៊ើបអង្កេត ។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយសារតែការស៊ើបអង្កេតនៅពុំទាន់បានបញ្ចប់ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចពន្យារពេលឃុំខ្លួនជាលើកទីពី សម្រាប់រយៈពេលមួយឆ្នាំបន្តទៀត ។ ដូច្នេះ ការឃុំខ្លួនជនជាប់ចោទ ខៀវ សំផន នៅក្នុងដំណាក់កាលស៊ើបអង្កេតមានរយៈពេលបីឆ្នាំ ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដោយធ្វើការបង្គាប់ថា ជនជាប់ចោទត្រូវរក្សាទុកក្នុងមន្ទីរឃុំឃាំងជាបណ្ដោះអាសន្នរហូតដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ដូច្នេះ ខៀវ សំផន ត្រូវបន្តស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នក្នុងមន្ទីរឃុំឃាំងរហូតដល់មានការជំនុំជម្រះក្ដីដោយអង្គជំនុំជម្រះសាលាដំបូង ។

ក្នុងដំណាក់កាលនៃការជំនុំជម្រះលើអង្គសេចក្ដី អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ ខៀវ សំផន ដោយអនុលោមតាមវិធាន៨២(១) នៃវិធានផ្ទៃក្នុង ដែលចែងថា៖ "នៅក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួន នៅពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្ដី" ។ ទោះបីជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងនៅតែមានឆន្ទានុសិទ្ធិក្នុងការបង្គាប់ឲ្យដោះលែងជនជាប់ចោទ ខៀវ សំផន ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមការស្នើសុំរបស់ជនជាប់ចោទ ឬ មេធាវីរបស់ជនជាប់ចោទនៅក្នុងករណីចាំបាច់ ។



ខៀវ សំផន នៅអំឡុងឆ្នាំ១៩៧៧



ខៀវ សំផន នៅឆ្នាំ២០១២ (រូបថត៖ អ.វ.ត.ក)

មុនពេលនៃការចាប់ផ្ដើម

សវនាការលើអង្គសេចក្តី អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ដោយធ្វើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ឲ្យទៅជាផ្នែកតូចៗ ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចជ្រើសរើសយកអង្គហេតុ ឬបទចោទប្រកាន់ត្រង់ផ្នែកណាមួយក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីយកមកបើកសវនាការ ។ ផ្នែកដំបូងដែលអង្គជំនុំជម្រះលើកយកមកបើកសវនាការនោះត្រូវបានកំណត់ថាជាសំណុំរឿង ០០២/០១ ។ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានលើកយកបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមកធ្វើការវិនិច្ឆ័យ ។ រីឯបទចោទប្រកាន់ផ្សេងទៀតដែលទាក់ទងនឹងបទប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ត្រូវបានទុកមួយអន្លើសម្រាប់ដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី ។

ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការក្នុងសំណុំរឿង ០០២/០១ ខៀវ សំផន បានបដិសេធរាល់ការចោទប្រកាន់ទាំងអស់ និងថាពុំបានដឹងអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ហើយនៅក្នុងរបបនោះខ្លួនក៏ពុំមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចអ្វីទាំងអស់ ។

ប្រសិនបើ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០២/០១ ដែលគ្រោងនឹងចេញនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៤ រកឃើញថា ខៀវ សំផន ពិតជាមានពិរុទ្ធភាព អង្គជំនុំជម្រះនឹងផ្តន្ទាទោស ខៀវ សំផន នៅក្នុងកម្រិតណាមួយ ដែលស្របទៅនឹងកិច្ចព្រមព្រៀងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុង ។ ផ្ទុយទៅវិញ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ថា អំពើដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនមានភស្តុតាងបង្ហាញពិតប្រាកដ ឬយល់ឃើញថា ខៀវ សំផន មិនមានពិរុទ្ធភាពក្នុងអំពើទាំងនោះទេ ខៀវ សំផន នឹងរួចផុតពីបទចោទ ។

ទោះបីជាផ្អែកតាមការបង្ហាញពីខាងលើ ខៀវ សំផន ត្រូវបានរកឃើញថា មានពិរុទ្ធភាព ឬពុំមានពិរុទ្ធភាពសម្រាប់សំណុំរឿង ០០២/០១ ក៏ដោយ ខៀវ សំផន នឹងនៅតែបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងដដែល ។



ខៀវ សំផន (ឆ្វេង) ទទួលប្រធានាធិបតី ណេ វីន (ស្តាំ) នៃប្រទេសភូមានៅព្រលានយន្តហោះពោធិ៍ចិនតុងក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧

មានហេតុផលពីរយ៉ាង ដែល ខៀវ សំផន មិនអាចត្រូវបានដោះលែង ។ ហេតុផលទី១ គឺករណី ដែលសហព្រះរាជអាជ្ញាបន្តប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ។ ហេតុផលទី២ គឺដោយសារ ខៀវ សំផន នៅពុំទាន់រួចផុតពីការចោទប្រកាន់ផ្សេងៗទៀតឡើយ ។

សម្រាប់ហេតុផលទី១ តាមផ្លូវច្បាប់ សហព្រះរាជអាជ្ញានឹងប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីដែលជនជាប់ចោទ ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចថាមិនមានទោស ។ ក្នុងករណីនេះ ខៀវ សំផន នឹងត្រូវបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងរង់ចាំសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល ។ យោងតាមការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះតុលាការកំពូលអាចនឹងចេញនៅចុងឆ្នាំ២០១៥ ។ អនុលោមតាមវិធាន១១១(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចឲ្យរួចផុតពីបទចោទ នោះ ខៀវ សំផន នឹងត្រូវបានដោះលែងឲ្យមានសេរីភាពភ្លាម ។ ប៉ុន្តែ វិធាននេះក៏បានចែងបន្ថែមដែរថា ជនជាប់ចោទអាចនឹងត្រូវបន្តស្ថិតនៅក្នុងឃុំ ក្នុងករណីដែលជននោះត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត ។ ឃ្លាចុងក្រោយនេះហើយ ជាហេតុផលទី២ ដែល ខៀវ សំផន មិនអាចត្រូវបានដោះលែង ទោះបីជារកពុំឃើញមានពិរុទ្ធភាពក្នុងសំណុំរឿង ០០២/០១ ដែលពាក់ព័ន្ធខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ។ ដូចបានបញ្ជាក់ពីខាងលើ ខៀវ សំផន ត្រូវបានចោទប្រកាន់លើបទឧក្រិដ្ឋកម្មអន្តរជាតិចំនួនបីគឺបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ដោយសារការបំបែកសំណុំរឿង០០២ ទៅជាផ្នែកតូចៗ ហើយជ្រើសរើសយកតែបទចោទប្រកាន់មួយមកធ្វើការជំនុំជម្រះ ដូច្នេះ ខៀវ សំផន នៅពុំទាន់រួចផុតពីបទចោទប្រកាន់ពីរផ្សេងទៀត ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតនៅឡើយទេ ។ បើយោងតាមវិធាន១១១(៤) ខៀវ សំផន ទំនងជានឹងត្រូវបន្តដាក់ឲ្យស្ថិតនៅក្នុងមន្ទីរឃុំឃាំងរង់ចាំការកាត់សេចក្ដីលើបទចោទប្រកាន់ផ្សេងទៀត ដែលនៅសេសសល់សម្រាប់ដំណាក់កាលបន្ទាប់ក្នុងសំណុំរឿង០០២/២ ឬសំណុំរឿង០០២/៣ ។

បើពិនិត្យមើលលើរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នលើរូប ខៀវ សំផន ចាប់តាំងពីឆ្នាំ ២០០៧ រហូតដល់បច្ចុប្បន្ន គឺមានរយៈពេលប្រមាណ៥ឆ្នាំ និង៧ខែ ហើយការឃុំខ្លួននេះអាចនឹងបន្តរហូតដល់សំណុំរឿង០០២ទាំងមូលត្រូវបានបញ្ចប់ ។ ខៀវ សំផន មានសិទ្ធិក្នុងការស្នើសុំអង្គជំនុំជម្រះឲ្យដោះលែងខ្លួន ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយ ខៀវ សំផន ក៏ធ្លាប់បានប្រើប្រាស់សិទ្ធិនេះរួចហើយដែរ ។ ក្នុងអំឡុងពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ខៀវ សំផន ធ្លាប់បានដាក់សំណើសុំឲ្យមានការដោះលែងខ្លួនចំនួនប្រាំដងរួចមកហើយ ប៉ុន្តែសំណើទាំងនោះ ត្រូវបានបដិសេធទាំងអស់ ។ មូលហេតុដែលនាំឲ្យអង្គជំនុំជម្រះបដិសេធចំពោះការស្នើសុំដោះលែងរបស់ ខៀវ សំផន គឺការព្រួយបារម្ភចំពោះការរត់គេចខ្លួនរបស់គាត់ ។

ហេតុដូច្នេះ ខៀវ សំផន ទំនងជានឹងត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងរហូតដល់ពេលមានសាលក្រម ឬសាលដីកាសម្រេចអំពីពិរុទ្ធភាពរបស់ខ្លួនក្នុងសំណុំរឿង០០២/០១ និងរង់ចាំការជំនុំជម្រះបទចោទប្រកាន់ផ្សេងៗទៀតដែលនៅសេសសល់ ។ បើពិនិត្យមើលទៅលើវ័យរបស់ ខៀវ សំផន នាពេលបច្ចុប្បន្ន ដែលមានអាយុ៨២ឆ្នាំ ប្រៀបធៀបនឹងរយៈពេលដែលអង្គជំនុំជម្រះគ្រោងនឹងសម្រេចឲ្យបាននូវសាលដីកាស្ថាពរក្នុងសំណុំរឿង០០២/១ទាំងមូល រួមជាមួយនឹងសំណុំរឿង០០២/២ ឬសំណុំរឿង ០០២/៣ (ប្រសិនជាកើតមាន) ឃើញថា លទ្ធភាពដើម្បីនៅក្រៅឃុំរបស់ ខៀវ សំផន ស្ទើរតែពុំអាចកើតមាន ។

ទោះបីជាយ៉ាងណាក្ដី ការបន្តឃុំខ្លួនជនជាប់ចោទក្នុងមន្ទីរឃុំឃាំងក្នុងរយៈពេលយូរ ដោយពុំមានការកំណត់ច្បាស់លាស់អំពីកាលបរិច្ឆេទនៃគម្រោងចេញសេចក្ដីសម្រេចស្ថាពរ ពុំមែនជាជម្រើសល្អសម្រាប់អង្គជំនុំជម្រះឡើយ ព្រោះអាចនឹងធ្វើឲ្យប៉ះពាល់ដល់គោលការណ៍នៃការជំនុំជម្រះក្ដីក្នុងថិរវេលាមួយសមស្រប ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគប្បីត្រូវបង្កើតផែនការទាក់ទងនឹងសំណុំរឿង ដែលនៅសេសសល់ឲ្យបានច្បាស់លាស់ តាមសំណើរបស់អង្គជំនុំជម្រះតុលាការកំពូលដើម្បីជៀសវាងការគំរាមកំហែងពីសំណាក់មេធាវីការពារក្ដីរបស់ជនជាប់ចោទ ។ **លឹម ច័យផត្ក**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ វិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ស៊ីរិ សាវីណា តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthsavina.s@dccam.org

**◆ ទីកន្លែង : អាគារ “ក” ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្តូសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ុរិ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។





















# អង្គជំនុំជម្រះសាលាដំបូងពិចារណាលើការច្រានចោល ការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ

ដោយសារសវនាការលើភ័ស្តុតាងជិតឈានដល់ការបញ្ចប់ អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងពីររូបនៅក្នុងសវនាការសំណុំរឿង០០២ដំណាក់កាលទីមួយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហមបានជូនដំណឹងទៅអង្គជំនុំជម្រះថា ជនជាប់ចោទលែងមានបំណងផ្តល់សក្ខីកម្ម ឬឆ្លើយតបសំណួរទាំងឡាយតទៅទៀតហើយ ។ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានផ្ទុយចេញពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ ។

ជនជាប់ចោទទាំងពីរបានធ្វើសេចក្តីថ្លែងការណ៍ក្នុងអំឡុងពេលសវនាការ និងនៅក្នុងឱកាសដ៏កម្រក្នុងការឆ្លើយតបសំណួរពីសំណាក់ចៅក្រម និងការផ្តល់សក្ខីកម្មពីដើមបណ្តឹងរដ្ឋប្បវេណី ។ ជាញឹកញាប់ ជនជាប់ចោទតែងតែច្រានចោលការឆ្លើយតបសំណួរដោយលើកឡើងថា ខ្លួននឹងមានឆន្ទៈឆ្លើយ លុះត្រាតែក្រោយពេលសហព្រះរាជអាជ្ញាបង្ហាញនូវការដាក់ភ័ស្តុតាងរួចរាល់ ។ រហូតដល់ដើមខែកក្កដាកន្លងទៅនេះ យើងឃើញថា ជនជាប់ចោទទាំងពីរបង្ហាញឆន្ទៈខណៈដែលខ្លួនចូលរួមជាច្រើនថ្ងៃចំពោះការឆ្លើយតបសំណួរដោយសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

កាលពីដើមខែកក្កដានេះដែរ ជនជាប់ចោទ ខៀវ សំផន បានជូនដំណឹងថា ខ្លួនលែងមានឆន្ទៈក្នុងការផ្តល់សក្ខីកម្មឬក៏ឆ្លើយតបសំណួរដោយលើកឡើងនូវកង្វល់ចំនួនប្រាំចំណុចដូចតទៅ ៖ ១) បញ្ហាមួយពីភាគីនានា និងពីអង្គជំនុំជម្រះសាលាដំបូងស្តីពីសំណួរ



នួន ជា នៅសាលាក្តីខ្មែរក្រហម ឆ្នាំ២០១២ (រូបថត ៖ អ.វ.ត.ក)



ខៀវ សំផន នៅសាលាក្តីខ្មែរក្រហម ឆ្នាំ២០១២ (រូបថត ៖ អ.វ.ត.ក)

នានា (តាមប្រធានបទ) ដែលត្រូវសួរទៅជនជាប់ចោទ២) ស្រដៀងគ្នានេះដែរ បញ្ជីមួយពីភាគីនានា និងពីអង្គជំនុំជម្រះសាលាដំបូងស្ដីពីឯកសារនានា ដែលជនជាប់ចោទទាំងពីរគេចង់ប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោល ៣) រយៈពេលបីសប្ដាហ៍សម្រាប់ត្រៀមរៀបចំដោយពុំមានសវនាការចាប់ពីពេលដែលមានបញ្ញត្តិស្ដីពីបញ្ជីសំណួរ និងឯកសារ ៤) បញ្ញត្តិស្ដីពីការដែលក្រុមមេធាវីការពារក្ដីអាចចូលទៅមើលអង្គភាពមន្ទីរឃុំឃាំង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃចុងសប្ដាហ៍ និង ៥) ខៀវ សំផន ត្រូវបានរៀបចំកាលវិភាគឲ្យធ្វើការផ្ដល់សក្ខីកម្មចំនួនកន្លះថ្ងៃតែប៉ុណ្ណោះ ។ ទោះបីជាមានអំណះអំណាងដែលការទាមទារទាំងនេះលើសពីសិទ្ធិរបស់ជនជាប់ចោទ ខៀវ សំផន នៅក្នុងគោរពតាមបទដ្ឋានអន្តរជាតិក៏ភាគីសហព្រះរាជអាជ្ញាពុំមានការជំទាស់ចំពោះក្រុមមេធាវីការពារក្ដីទាក់ទងនឹងផលប្រយោជន៍នៃការធានានូវសក្ខីកម្មរបស់ជនជាប់ចោទឡើយ ។ ខៀវ សំផន ក្រោយមកបានបញ្ជាក់ថាមូលហេតុដែលខ្លួនប្រានបោលនូវការផ្ដល់សក្ខីកម្មពុំមែនដោយសារតែការកំណត់នូវបញ្ហាទាំងប៉ុន្មានខាងលើនោះទេ ប៉ុន្ដែមានឫសគល់នៃបញ្ហាទូទៅពាក់ព័ន្ធនឹងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ៖

> ហេតុផលដែលខ្ញុំសម្រេចប្រើប្រាស់សិទ្ធិរបស់ខ្ញុំនៅស្ងៀម ។ ហេតុផល គឺមកពីតុលាការមិនគោរពនូវសិទ្ធិរបស់ខ្ញុំនិងមេធាវីការពារក្ដីរបស់ខ្ញុំ ។ ពីមុនខ្ញុំជឿតុលាការនេះ ប៉ុន្ដែជាបន្តបន្ទាប់ មកហូរហែមករហូតដល់ដំណាក់កាលចុងក្រោយនេះ ខ្ញុំលែងជឿហើយ ខ្ញុំអស់ជំនឿហើយ ។ ខ្ញុំសូមជម្រាបខ្លីប៉ុណ្ណោះ ។

ស្រដៀងគ្នានេះដែរ កាលពីពាក់កណ្ដាលខែកក្កដា ជនជាប់ចោទ នួន ជា បានជូនដំណឹងជូនអង្គជំនុំជម្រះដោយពុំមានការគ្រោងទុកជាមុនថា ៖

> ដូចដែលខ្ញុំតែងតែបានលើកឡើងមកហើយថា តុលាការនេះមិនបានគោរពទៅលើគោលការណ៍នៃការកាត់សេចក្ដីដ៏ត្រឹមត្រូវនិងយុត្តិធម៌នោះទេ ។ ខ្ញុំបានសង្កេតឃើញការប្រព្រឹត្តមកលើជនជាប់ចោទក៏ដូចជាក្រុមមេធាវីការពាររបស់ខ្ញុំវិវត្តពីអាក្រក់ទៅកាន់ទៅកាន់ តែអាក្រក់ថែមទៀត ។ ខ្ញុំក៏អស់ជំនឿលើតុលាការនេះដូចលោក ខៀវ សំផន ដែរ ។
>
> ការប្រព្រឹត្តរបស់តុលាការមកលើខាងយើងខ្ញុំគឺនៅភពម្ខាង ហើយខាងព្រះរាជអាជ្ញាគឺនៅភពម្ខាង ។ ជាក់ស្ដែងដូចជានៅពេលថ្មីៗនេះ មេធាវីរបស់ខ្ញុំត្រូវបានកាត់ផ្ដាច់មិនឲ្យសួរសំណួរជាសារធាតុដើម្បីដោះស្រាយបន្ទុកមកលើរូបខ្ញុំនោះទេ ។ នេះជាភាពអយុត្តិធម៌មួយដែលរារាំងមិនឲ្យមេធាវីរបស់ខ្ញុំបំពេញនូវតួនាទីការពារខ្ញុំដោយពេញលេញ ។
>
> នេះជារឿងក្ដីនៃអាយុជីវិតរបស់ខ្ញុំ មិនមែនធ្វើលំៗឲ្យតែឆាប់រហ័សដើម្បីដាក់ទោសខ្ញុំនោះទេ ។ ដោយភាពអស់ជំនឿ និងប្រព្រឹត្តដោយលម្អៀងបែបនេះ ខ្ញុំសូមជូនដំណឹងថា ខ្ញុំមិនឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញានិងភាគីនានានៅក្នុងតុលាការដែលមិនយុត្តិធម៌នេះទេ ។ ក្នុងគ្រានេះ ការពិតយុត្តិធម៌ និងមានប្រយោជន៍ត្រូវបានបំផ្លាញដោយតុលាការ ។

ភាគីសហព្រះរាជអាជ្ញាអះអាងថា តាមរយៈការធ្វើសេចក្ដីថ្លែងការណ៍ និងការជ្រើសរើសឆ្លើយតបនឹងសំណួរនៅក្នុងបន្ទប់សវនាការ ជនជាប់ចោទបានបង្ហាញភ័ស្ដុតាងដោយការបោះបង់នូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ ។ កាលពីឆ្នាំមុន សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ៖

> ច្បាស់ណាស់ វាជាទម្លាប់មួយពុំអាចទទួលយកបានទេដែលជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយគាត់បានធ្វើសេចក្ដីថ្លែងការណ៍ថា “ខ្ញុំមិនមានការងាររអ្វីពាក់ព័ន្ធនឹងមន្ទីរស-២១ទេ” “អ្នកចោទប្រកាន់ខ្ញុំឈ្មោះ ឌុច នោះគឺជាជនកុហក” ។ ការដែលបានធ្វើការអះអាងបែបនេះហើយនិងបដិសេធមិនឆ្លើយនូវសំណួរផ្សេងៗគឺដើម្បីការការពារខ្លួនប៉ុណ្ណោះ ។ មានផលវិបាកជាច្រើន កាលណាជនជាប់ចោទដោះសារនៅក្នុងករណីបែបនេះហើយពុំមានអ្វីគួរថ្លឹងថ្លែងជាការកំណត់នូវភ័ស្ដុតាង

> នោះទេ ។ ដំហររបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យតុលាការគប្បីប្រើការបកស្រាយបែបអវិជ្ជមានប្រឆាំងនឹងជនជាប់ចោទនៅក្នុងករណីដែលគាត់នៅស្ងៀមបែបនេះ ។

ដូច្នេះ នៅពេលនេះ ភាគីសហព្រះរាជអាជ្ញាកំពុងតែស្នើថា ការធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់ជនជាប់ចោទកាលពីពេលមុនបានផ្តល់នូវភស្តុតាងតិចតួច ឬក៏គ្មានទម្ងន់ជាភស្តុតាង ហើយថា «គប្បីទាញសេចក្តីសន្និដ្ឋានអវិជ្ជមាននៅក្នុងការពិចារណាលើភាពជាក់ស្តែងប្រឆាំងនឹងជនជាប់ចោទ» ។ ព្រះរាជអាជ្ញារកឃើញបន្ថែមទៀតនូវឱកាសក្នុងការបង្ហាញពី «ប្រធានបទនិងអង្គហេតុ ដែលព្រះរាជអាជ្ញាតាំងសំណួរចំពោះជនជាប់ចោទ ខៀវ សំផន និង «ស្តីអំពីអ្វីដែលព្រះរាជអាជ្ញានឹងស្នើឲ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានជុយនៅក្នុងសេចក្តីសង្ខេបបញ្ចប់សវនាការ» ។

យោងតាមច្បាប់កម្ពុជា ផ្អែកតាមសភាពជាក់ស្តែងពុំបានបញ្ជាក់ពីបញ្ហានេះទេ ។ សហព្រះរាជអាជ្ញាលើកយកយុទ្ធសាស្ត្រអន្តរជាតិ និងនៅក្នុងករណីចំនួនពីរនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន ។ នៅក្នុងសំណុំរឿងទីមួយ ករណីជនជាប់ចោទ ហ្គូតូវីណា និងបក្សពួក អង្គជំនុំជម្រះសាលាដំបូងធ្វើកំណត់សម្គាល់នៅក្នុងឯកសារសង្ខេប ៖ «នៅពេលដែលជនជាប់ចោទសម្រេចចិត្តឡើងមកផ្តល់សក្ខីកម្ម ជនជាប់ចោទមានកាតព្វកិច្ចឆ្លើយតបសំណួរ បើទោះបីជាចម្លើយទាំងនោះអាចដាក់ពិរុទ្ធភាពលើខ្លួនឯងក៏ដោយ ។ ករណីមួយទៀតគឺសំណុំរឿង ប្រាហ្គោចេវិក និង ចូគីក អង្គជំនុំជម្រះសាលាដំបូងជូនដំណឹងទៅជនជាប់ចោទថាមានជម្រើសបីនៅក្នុងវិធានរបស់អង្គជំនុំជម្រះ ៖ នៅស្ងៀមមិនឆ្លើយតបដោយពុំមានការពិចារណាអវិជ្ជមាន សេចក្តីថ្លែងការណ៍ដោយពុំមានការធ្វើសម្បថ ដោយពុំមានការសួរដេញដោល (សេចក្តីថ្លែងការណ៍ពុំសូវមានទម្ងន់ ប៉ុន្តែពុំត្រូវទាញសេចក្តីសន្និដ្ឋានអវិជ្ជមាន) ឬធ្វើសេចក្តីប្រកាសជាឱឡារិកនិងធ្វើសក្ខីកម្មដូចជាសាក្សីនៃសំណុំរឿងដែរ ។ ប្រសិន បើជម្រើសធ្វើសេចក្តីប្រកាសជាឱឡារិក និងធ្វើសក្ខីកម្មដូចជាសាក្សីនៃសំណុំរឿងត្រូវបានទទួលយក បើទោះជាជនជាប់ចោទប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបលើបញ្ហានានាដែលបានលើកឡើង «បញ្ហានេះអាចមានលទ្ធភាពនាំទៅរកការពិចារណាតិចតួចសក្ខីកម្ម ។

ភាគីសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហាក់ដូចជាស្វែងរកផលវិបាកកាន់តែធំឡើងសម្រាប់ជនជាប់ចោទនៅក្នុងសំណុំរឿង០០២ ដោយស្នើឲ្យទាញសេចក្តីសន្និដ្ឋានអវិជ្ជមានមិនត្រឹមតែពាក់ព័ន្ធនឹងប្រធានបទពន្យារពេលពិភាក្សាជាក់ស្តែងរហូតដល់ពេលចុងក្រោយនៃសវនាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធនឹងការខកខានមិនបានឆ្លើយតបសំណួរដែលព្រះរាជអាជ្ញាពុំទាន់បានសួរទៀតផង ។ លទ្ធភាពសម្រាប់ភាពពាក់ព័ន្ធជុយគ្មានដែនកំណត់ ដែលត្រូវលើកឡើងចេញពីអង្គហេតុថា នីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំស្រដៀងទៅនឹងនិតិវិធីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីទេ ។ ទាំងវិធាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ផ្តល់ឱកាសដល់ជនជាប់ចោទក្នុងការធ្វើសេចក្តីថ្លែងការណ៍ ដោយពុំចាំបាច់ធ្វើសម្បថនៅពេលចាប់ផ្តើមសវនាការ ។ ប៉ុន្តែខុសគ្នារវាងច្បាប់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលផ្អែកលើប្រព័ន្ធច្បាប់ខំមិនឡូ និងច្បាប់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលឡូ «ពុំមានច្បាប់សម្រាប់ជនជាប់ចោទក្នុងការធ្វើសម្បថ» និងផ្តល់សក្ខីកម្មដូចជាសាក្សីនោះទេ ។ ឆន្ទៈរបស់ជនជាប់ចោទចង់ឲ្យមានការតាំងសំណួរតាមរយៈនីតិវិធីរបស់តុលាការ ។ ដូច្នេះ ជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំបានប្រកាន់ជំហរសម្រាប់សក្ខីកម្មដែលមានការកម្រិតព្រំដែន ប៉ុន្តែផ្អែកតាមទ្រឹស្តីអាចមានលទ្ធភាពឆ្លើយសំណួរក្នុងអំឡុងពេលមួយឆ្នាំកន្លះនៃសវនាការស្តីពីប្រធានបទជាច្រើនដែលត្រូវលើកឡើង ។

កាលពីឆ្នាំមុន នៅពេលដែលសហព្រះរាជអាជ្ញាដាក់សារណាដំបូងបានលើកឡើងថា ជនជាប់ចោទបានលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបដោយផ្តល់ជូនវិញនូវការជ្រើសរើសធ្វើសក្ខីកម្ម ហើយក្រុមមេធាវីការពារក្តី ខៀវ សំផន បានជំទាស់ ។ មេធាវីការពារក្តី ខៀវ សំផន អះអាងថាពុំអាចអនុវត្តបទដ្ឋានអន្តរជាតិ

បានទេដោយហេតុថា ស្ថានភាពនេះនាំឲ្យជនជាប់ចោទត្រូវហៅដូចជាសាក្សីធ្វើសម្បថ ដែលនេះពុំស្របតាមនីតិវិធីដែលអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។ លើសពីនេះទៀត មេធាវីបានលើកយកគោលការណ៍សំខាន់ថា តុលាការអន្តរជាតិ «បញ្ជាក់ច្បាស់លាស់ពីភាពខុសគ្នារវាងសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទធ្វើនៅក្នុងតុលាការ (អំពីអ្វីដែលជនជាប់ចោទមិនអាចត្រូវគេសួរដេញដោល) និងសេចក្តីថ្លែងការណ៍ដែលជនជាប់ចោទធ្វើនៅពេលបង្ហាញខ្លួន ដូចជាសាក្សីនៅក្នុងការការពារខ្លួន» ស្តីពីអ្វីដែលជនជាប់ចោទ ត្រូវសួរដេញដោល ។ ភាពខុសគ្នានេះមានសារសំខាន់ ប៉ុន្តែមានភាពខុះចន្លោះ ដោយសារនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅពេលជនជាប់ចោទបង្ហាញខ្លួន អនុញ្ញាតឲ្យមានការធ្វើសេចក្តីថ្លែងការណ៍ដោយពុំចាំបាច់ធ្វើសម្បថ ។

នេះជាភាពទូទៅនៅពេលចាប់ផ្តើមសវនាការនីតិវិធី ប៉ុន្តែពុំត្រូវធ្វើសេចក្តីថ្លែងការណ៍ដដែលជាថ្មីម្តងទៀតក្នុងអំឡុងពេលដំណាក់កាលសវនាការ ដូចអ្វីដែលបានកើតឡើងនៅក្នុងសំណុំរឿង ០០២ នេះទេ ។

បញ្ហាស្មុគស្មាញ ការអនុវត្តរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង០០២ តាមរយៈការធ្វើសេចក្តីថ្លែងការណ៍នៅខាងក្រៅការតាំងសំណួរជាផ្លូវការ ពុំបានបង្ហាញឲ្យឃើញជាមុនតាមរយៈវិធានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្ទាល់ទេ ។

បញ្ហាផ្លូវច្បាប់ ការសម្រេចចិត្តរបស់ជនជាប់ចោទ មិនផ្តល់សក្ខីកម្ម នៅពុំទាន់បានកំណត់នៅឡើយ ។ ប៉ុន្តែសំណើររបស់ភាគីសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតទៅលើការសម្រេចផ្ទាល់មាត់របស់ខ្លួនកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ស្តីពីការជាប់ទាក់ទងនឹងជម្រើសផ្តល់សក្ខីកម្ម ដែលទទួលយកការយល់ឃើញរបស់សហព្រះរាជអាជ្ញាដែលថាជម្រើសឆ្លើយតបនៅក្នុងអំឡុងពេលនៃដំណាក់កាលសវនាការ គឺអាចប្រៀបប្រដូចទៅនឹងសក្ខីកម្មរបស់សាក្សី ។ គួរកត់សម្គាល់ថា ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា៣៥ថ្មី(ឆ) ការពារសិទ្ធិជនជាប់ចោទ «មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស» ។ អង្គជំនុំជម្រះសម្រេចថាៈ

> *នៅក្នុងការវាយតម្លៃអំពីពិរុទ្ធភាព ឬសុចរិតភាពរបស់ជនជាប់ចោទនៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះនឹងពិចារណានូវរាល់ភស្តុតាងដែលបានដាក់នៅចំពោះមុខខ្លួន និងជាកម្មវត្ថុនៃការពិនិត្យរួមទាំងសក្ខីកម្មរបស់ជនជាប់ចោទ និងរបៀបដែលជនជាប់ចោទផ្តល់សក្ខីកម្ម ។ នៅក្នុងន័យនេះ និងនៅពេលដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងរវាងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងការផ្តល់សក្ខីកម្មនោះអង្គជំនុំជម្រះអាចនឹងកត់សម្គាល់អំពីបញ្ហានៅពេលវាយតម្លៃអំពីភាពគួរឲ្យជឿជាក់បានរបស់គាត់ ។ យុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបង្ហាញថា ការសម្រេចជ្រើសរើសដោយខ្លួនឯងក្នុងការនៅស្ងៀម មិនឆ្លើយតបអាចត្រូវបានប្រើក្នុងការទាញសេចក្តីសន្និដ្ឋានផ្ទុយ ។ នៅក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះនឹងមិនផ្អែកទាំងស្រុងលើការទាញសេចក្តីសន្និដ្ឋានផ្ទុយចេញពីការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅក្នុងការវិនិច្ឆ័យអំពីកំហុសឡើយ ។*

ប៉ុន្តែ ការមិនឆ្លើយតប គឺជាព្រំដែននៃ «ប្រធានបទ និងអង្គហេតុ» សម្រាប់ការទាញសេចក្តីសន្និដ្ឋានផ្ទុយក្នុងការវិនិច្ឆ័យពីកំហុស ។

**អាន ហាញឱល**

**គម្រោងឃ្លាំមើល តុលាការខ្មែរក្រហម**
CAMBODIA TRIBUNAL MONITOR
តាមដានដំណើរកាត់ទោស ករណី០០២ រៀងរាល់ថ្ងៃ ចាប់ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ តទៅ
សូមចុច www.cambodiatribunal.org

# ខ្មែរក្រហម និងណាហ្ស៊ីមិនអាចប្រៀបធៀបគ្នាបានទេ

*នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បានផ្តល់បទសម្ភាសន៍ជាមួយបណ្ឌិត ហែលម៉ាត ប៊ឹក មន្ត្រីសម្របសម្រួល និងជាកិច្ចការសាធារណៈរបស់វិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ អយកូក្រេឌីត មានមូលដ្ឋាននៅប្រទេសអូទ្រីស អំពីទស្សនវិស័យនៃប្រវត្តិអតីតកាលភ្ជាប់ទៅនឹងបច្ចុប្បន្នភាពនៅប្រទេសកម្ពុជា ។ បណ្ឌិត ហែលម៉ាត ប៊ឹក គឺជាអ្នកធ្វើបទសម្ភាសន៍ ។*

**សំណួរ ៖** ការបោះឆ្នោតបានប្រព្រឹត្តកាលពីថ្ងៃទី២៨ ខែកក្កដា ។ មានការរៀបចំធ្វើបាតុកម្មដ៏ធំមួយនៅទីក្រុងភ្នំពេញដឹកនាំដោយអ្នករស់រានមានជីវិតម្នាក់ពីរបបកម្ពុជាប្រជាធិបតេយ្យ ។ វាហាក់បីដូចជាថា គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចបង្ហាញនូវចំណាប់អារម្មណ៍ក្នុងការក្រើនរំឭកប្រជាជនកម្ពុជាអំពីអតីតកាលរបស់ខ្លួន ។ តើនេះគឺជាខ្លឹមសារនៃយុទ្ធនាការបោះឆ្នោតឬ? តើលោកយល់ឃើញដូចម្តេចចំពោះបញ្ហានេះ?

**ចម្លើយ ៖** អតីតកាលមិនមែនគ្រាន់តែជាខ្លឹមសារនៃការបោះឆ្នោតនោះទេ ។ អតីតកាលគឺជាខ្លឹមសាររបស់ជាតិ ដែលជារឿយ ៗ គ្រប់គណបក្សនយោបាយទាំងអស់យកធ្វើជាបញ្ហានយោបាយ ។ ទន្ទឹមពេលនេះ ក៏ជាការសំខាន់សម្រាប់ប្រជាជនកម្ពុជាក្នុងការចងចាំរឿងរ៉ាវពីអតីតកាល ហើយរក្សាពាក្យសម្បថក្នុងការអប់រំមនុស្សជំនាន់ក្រោយអំពីរឿងហេតុ និងមូលហេតុនូវអ្វីដែលបានកើតឡើង យើងក៏មិនត្រូវឲ្យអតីតកាលត្រួសត្រាយផ្លូវសម្រាប់បច្ចុប្បន្នភាពឡើយ ។ អ្នករួចរស់មានជីវិតបានឆ្លងកាត់របបប្រល័យពូជសាសន៍រួចទៅហើយ ។ ហេតុនេះ វាមិនមែនជារឿងត្រឹមត្រូវសោះដែលត្រូវរំឭកពីអំពើប្រល័យពូជសាសន៍ម្តងហើយម្តងទៀតដើម្បីធ្វើឲ្យទស្សនវិស័យណាមួយត្រឹមត្រូវ ឬធ្វើឲ្យការបង្កាប់បញ្ឆោនយោបាយឲ្យមានលក្ខណៈស្របច្បាប់នោះ ។ វាក៏មិនត្រឹមត្រូវដែរក្នុងការដែលសន្មតថា មនុស្សតែម្នាក់ គណបក្សតែមួយ រដ្ឋាភិបាលតែមួយ ឬក្រុមតែមួយអាចជួយប្រទេសមួយបាននោះ ។ ប្រទេសជាច្រើនលើលោកនេះត្រូវបានស្រោចស្រង់តាមការលះបង់តាមរយៈក្តីសង្ឃឹម និងតាមរយៈភាពមិនចេះទ្រុឌទ្រោមនៃកត្តាជាច្រើន ហើយមនុស្សគ្រប់រូបគួរតែទទួលស្គាល់នូវភាពគ្រោះថ្នាក់ ប្រសិនបើខ្លួនកំណត់ថា គណបក្សតែមួយ រដ្ឋាភិបាលតែមួយ ឬក្រុមតែមួយ គឺជាមូលដ្ឋានស្នូលក្នុងការបង្កើតភាពថ្កើងថ្កាន និងសន្តិភាពក្នុងប្រទេសក្រោយជម្លោះ ។ ប្រជាជនកម្ពុជាគឺជាប្រជាជនស្លូតត្រង់ដែលសាំទៅនឹងការគោរព ការបូជា ការដឹងគុណដល់អ្នកដែលជួយខ្លួន ។ សម្រាប់ហេតុផលតែឯកឯងនេះ យើងគួរតែលះបង់កម្លាំងកាយដើម្បីគាំទ្រគោលនយោបាយ ជាជាងគាំទ្រមនុស្ស និងគាំទ្រដំណើរការរបស់ស្ថាប័នណាមួយ ជាជាងគាំទ្រគណបក្សនយោបាយ ពីព្រោះគោលនយោបាយ និងដំណើរការដែលធានាអនាគតរបស់សង្គម ។ មេដឹកនាំមិនអាចដឹកនាំជារៀងរហូតនោះឡើយ ។ គណបក្សនយោបាយទាំងអស់នៅតែបណ្តុះគ្រាប់ពូជមនោគមវិជ្ជា "អាត្មានិយម" ។



លោក ឆាំង យុ ពេលឡើងធ្វើបទបង្ហាញនៅប្រទេសភូមាកាលពីចុងខែកក្កដាកន្លងទៅ

ការស្វែងរកការពិតមិនគួរធ្វើឲ្យទៅជារឿងនយោបាយ ហើយជនរងគ្រោះសមតែមានការរួបរួមគ្នា ។ នេះគឺជាហេតុផលដែលខ្ញុំគាំទ្រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ពីព្រោះវាជាវិធីសាស្ត្រមួយដ៏សំខាន់បំផុត ក្នុងចំណោមវិធីសាស្ត្រផ្សេងក្នុងការបង្រួបបង្រួមជនរងគ្រោះ ។

**សំណួរ ៖** តើជាធម្មតា អ្នកនយោបាយមាននិន្នាការនិយាយសំដៅទៅរកអតីតកាល ឬក៏មិនមែនទេ? តើនេះអាចក្លាយជាឱកាសមួយដើម្បីដោះស្រាយជាមួយនឹងអតីតកាល ឬជាឱកាសដើម្បីរៀនសូត្រដោះស្រាយជាមួយនឹងបទពិសោធឈឺចាប់?

**ចម្លើយ ៖** ជាធម្មតាអ្នកនយោបាយនិយាយសំដៅទៅរកអតីតកាល ប្រសិនបើមិនដោយផ្ទាល់ក៏ដោយ ក៏យ៉ាងហោចណាស់តាមរយៈការស្នើជាយោបល់ ។ ពិតប្រាកដណាស់ នយោបាយនិងប្រវត្តិសាស្ត្រមានទំនាក់ទំនងជាមួយនឹងគ្នាទៅវិញទៅមក ពីព្រោះការនិយាយអំពីបញ្ហាមួយចៀសមិនផុតពីការបកស្រាយបញ្ហាមួយទៀតឡើយ ។ ប៉ុន្តែការនិយាយសំដៅទៅរកអតីតកាលមិនមែនត្រូវតែសង្កត់ធ្ងន់លើបក្ខពួកនិយម ឬការបែកបាក់ឡើយ ។ យើងអាចប្រើអតីតកាលដើម្បីបង្រួបបង្រួមមនុស្ស និងជំរុញដល់ដំណើរការដែលអាចធ្វើឲ្យទស្សនវិស័យវែងឆ្ងាយចេញជារូបរាងឡើង ។ ប្រវត្តិសាស្ត្រត្រូវតែជាចំណុចចាប់ផ្តើមដែលត្រូវយកមកនិយាយសម្រាប់ការកសាងសង្គមដែលងើបចេញពីជម្លោះ ហើយវាជាការចាំបាច់ដែលអ្នកនយោបាយហៅអតីតកាលថាជាផ្នែកមួយនៃទស្សនវិស័យរបស់ខ្លួន ។ ពិតប្រាកដណាស់ សង្គមមួយស៊ើរតែមិនអាចដោះស្រាយបញ្ហានាពេលបច្ចុប្បន្នបានទេ ប្រសិនបើសង្គមនោះមិនអាច សូម្បីតែអនុញ្ញាតឲ្យមានការពិភាក្សាដោយស្មោះត្រង់មួយលើបញ្ហាអតីតកាលផងនោះ ។ ប៉ុន្តែ អតីតកាលគឺជាផ្នែកតែមួយគត់នៃយុត្តិធម៌អន្តរកាល ហើយប្រទេសជាតិមិនត្រូវមើលឃើញខ្លួនឯងថាជាជនរងគ្រោះជារៀងរហូតនោះទេ ។

ពិតប្រាកដណាស់ ការប៉ះពាល់ផ្លូវចិត្ត គឺជាស្រមោលនៃសង្គមដែលទើបងើបចេញពីជម្លោះ ។ វាបានធ្វើឲ្យសង្គមដែលងើបចេញពីជម្លោះមើលឃើញពិភពលោកតែពណ៌ខ្មៅ និងស ។ វាជារឿងធម្មតាដែលប្រទេសទាំងនោះជួបប្រទះនូវកំហឹងភាពអស់សង្ឃឹម ការសងសឹក និងការនៅដាច់ឆ្ងាយពីគេឯង ។ ដោយសារហេតុផលនេះ យើងអាចនិយាយបានថា បញ្ហាមួយក្នុងចំណោមបញ្ហាលំបាកបំផុតរបស់ប្រទេសដែលទើបតែងើបចេញពីជម្លោះគឺបញ្ហាតុល្យភាព ។ វាជាការលំបាកណាស់សម្រាប់ជនរងគ្រោះដែលមើលឃើញអតីតកាលជាការប៉ះទង្គិចផ្លូវចិត្ត នៅពេលដែលជនរងគ្រោះទាំងនោះបានឃើញអ្នកជាទីស្រលាញ់របស់ខ្លួនត្រូវបានសម្លាប់ ។ ចំណែកជនដៃដល់វិញមានភាពអាម៉ាស់ ហើយក្នុងករណីខ្លះមានទស្សនៈខុសឆ្គងព្រោះតែជនដៃដល់ទាំងនោះគិតថាខ្លួនមិនត្រូវបានចាត់ទុកថាជាមនុស្សជាតិ ។

ប្រការនេះហើយដែលជាការសំខាន់ណាស់ក្នុងការបង្កើតដំណើរការទាំងឡាយ ។ ការជជែកពិភាក្សា ការអប់រំ និងទិដ្ឋភាពដែលធ្លាប់កើតឡើង ដែលជាផែនការសម្រាប់អនាគត ត្រូវតែធ្វើឲ្យមានតុល្យភាពរវាងការជំរុញការយល់ដឹងរបស់យើងទៅនឹងការយល់ឃើញថាពិភពលោកមានពណ៌ខ្មៅ ឬពណ៌ស ។

**សំណួរ ៖** ក្នុងប្រទេសកម្ពុជានាពេលសព្វថ្ងៃ តើមនុស្សដែលដើរតួនាទីនៅក្នុងរបបខ្មែរក្រហមនៅតែក្តោបក្តាប់អំណាចផ្នែកសេដ្ឋកិច្ច និងនយោបាយឬ? ប្រសិនបើមានមែន តើលោកនិងប្រជាជនដទៃមានអារម្មណ៍បែបណា? ខ្ញុំសួរសំណួរបែបនេះដោយសារបញ្ហាបែបនេះបានកើតឡើងនៅក្នុងប្រទេសអូទ្រីស និងប្រទេសអាល្លឺម៉ង់បន្ទាប់ពីសង្គ្រាមលោកលើកទី២ ។ ចៅក្រមវេជ្ជបណ្ឌិត អ្នកវិទ្យាសាស្ត្រ និងអ្នកនយោបាយមួយចំនួនអាចបិទបាំងអតីតកាលរបស់ខ្លួនបាន ហើយរដ្ឋាភិបាលថ្មីត្រូវការអ្នកទាំងនោះដដែលដោយសារតែរដ្ឋាភិបាលថ្មីត្រូវការអ្នកជំនាញ ។

**ចម្លើយ ៖** ប្រទេសកម្ពុជា មិនខុសអ្វីពីប្រទេសផ្សេងទៀតដែលងើបចេញពីជម្លោះឡើយ ។ ក្នុងន័យនេះ មានអតីតខ្មែរក្រហមនៅក្នុងគ្រប់សរសៃឈាមសង្គមទាំងអស់ ចាប់តាំងពីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល រហូតដល់ស្ថាប័នសាសនា និងប្រជាជនសាមញ្ញនៅតាមមូលដ្ឋាន ។ ប្រជាជនកម្ពុជាស្គាល់យ៉ាងច្បាស់អំពីបញ្ហានេះ ហើយដោយសារហេតុផលនេះដែលជាការសំខាន់ក្នុងការបង្កើតដំណើរការស្វែងរកយុត្តិធម៌ ។ តាមរយៈការនាំយកយុត្តិធម៌ជូនជនរងគ្រោះ សាលាក្តីខ្មែរក្រហមនឹងជួយបញ្ចប់នូវប្រវត្តិសាស្ត្រដ៏គួរឲ្យភ័យខ្លាចនេះ ហើយអនុញ្ញាតឲ្យសង្គមធ្វើដំណើរទៅមុខ ។

**សំណួរ** ៖ ដំណើរការស្វែងរកការពិតដោយឯករាជ្យរបស់លោកឈរក្រោមពាក្យស្លោក "ការចងចាំនិងយុត្តិធម៌" ។ មនុស្សជាច្រើនមានបំណងលុបបំបាត់ចោលបទពិសោធឈឺចាប់របស់ខ្លួន ។ តើមានអ្វីមួយដែលអាចត្រូវបានហៅថាជាសិល្បៈនៃការលើកលែងទេ? តើអ្នកយល់ឃើញយ៉ាងដូចម្តេចចំពោះបញ្ហានេះ?

**ចម្លើយ** ៖ គួរតែប្រើពាក្យវិទ្យាសាស្ត្រនៃការលើកលែងវិញទើបត្រូវជាងពីព្រោះវាមិនមានសិល្បៈសម្រាប់ដំណើរការនេះទេ ។ ស្របពេលដែលស្នាមរបួសនោះ អាចជាស្នាមរបួសផ្លូវចិត្ត ស្នាមរបួសទាំងនោះមិនមានទំនាក់ទំនងទៅនឹងការរករោគវិនិច្ឆ័យនិងព្យាបាលតាមផ្លូវវិទ្យាសាស្ត្រឡើយ ។ ការស្វែងរកការពិតរបស់ខ្ញុំផ្អែកលើពាក្យស្លោកការចងចាំ និងយុត្តិធម៌ដែលជាទស្សនៈសម្អាងលើដំណើរការព្យាបាលស្នាមរបួស ។ ការចងចាំសំដៅទៅលើការអប់រំ ហើយយុត្តិធម៌សំដៅទៅរកការស្រាវជ្រាវ ។ ការចងចាំមិនមែននៅទ្រឹងតែមួយកន្លែងទេ តែវាត្រូវតែឆ្លុះបញ្ចាំងអំពីដំណើរការឋិតថេរនៃការបង្រៀនអំពីអ្វីដែលយើងដឹងអំពីប្រវត្តិសាស្ត្រដល់មនុស្សជំនាន់ក្រោយ ដូច្នេះហើយប្រវត្តិសាស្ត្រមិនអាចត្រូវបានបំភ្លេចឡើយ ។ ការអប់រំក្លាយជាដំណើរការនៃការធានាថា អ្នកដែលបានស្លាប់មិនបានស្លាប់ដោយឥតតម្លៃនោះឡើយ ហើយអ្នកដែលរស់រានមានជីវិតត្រូវបានផ្តល់កិត្តិយស និងគោរព ។ យុត្តិធម៌មិនអាចសម្រេចបានដោយគ្មានការស្រាវជ្រាវឡើយ ដូច្នេះហើយ នេះគឺជាហេតុផលដែលទស្សនៈនេះផ្អែកលើកិច្ចខិតខំប្រឹងប្រែងមិនឈប់ឈរក្នុងការពង្រីកការយល់ដឹងរបស់យើងអំពីរឿងហេតុដែលបានកើតឡើងនិងមូលហេតុដែលបទឧក្រិដ្ឋនោះកើតឡើង ។ បន្ទាប់ពីសេចក្តីសម្រេចផ្លូវច្បាប់ត្រូវផ្តល់ឲ្យយុត្តិធម៌អាចសម្រេចបានតាមរយៈការស្រាវជ្រាវប្រវត្តិសាស្ត្រមិនឈប់ឈរ ដែលធ្វើឲ្យមនុស្សយល់ដឹងអំពីអំពើអមនុស្សធម៌ហើយផ្តល់តម្លៃដល់អ្នកដែលរងគ្រោះ ។

**សំណួរ** ៖ នៅប្រទេសអូទ្រីស សូម្បីតែអស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីសង្គ្រាមលោកលើកទី២ហើយក៏ដោយ អំពើឃោរឃៅរបស់ជនណាហ្ស៊ីនៅតែជាការព្រួយបារម្ភ ។ មនុស្សជាច្រើនស្គាល់អំពីអតីតកាលរបស់ខ្លួន ។ តើលោកធ្លាប់លឺឈ្មោះសៃមិន វីសេនថល ដែលជាស្ថាបនិកនិងនាយកនៃមជ្ឈមណ្ឌលឯកសារឧក្រិដ្ឋកម្មណាហ្ស៊ីរបស់ប្រទេសអូទ្រីសទេ?

**ចម្លើយ** ៖ ទាល់តែឆ្នាំ១៩៩៨ហើយទើបខ្ញុំបានឮឈ្មោះសៃមិន វីសេនថល ។ ខ្ញុំត្រូវបានណែនាំឲ្យស្គាល់ស្នាដៃសំណេរនិងបទពិសោធរបស់គាត់តាមរយៈអគ្គរាជទូតហូល្លង់ប្រចាំនៅទីក្រុងបាងកក លោកស្រី ឡាទីស្យា វ៉ាន់ឌេន អាស៊ូម ។ ភ្លាមៗបន្ទាប់ពីនោះមក ខ្ញុំបានអានជីវប្រវត្តិនិងការងាររបស់គាត់ ។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងទៅនឹងការរស់នៅរបស់យើងនៅពេលដែល យើងទាំងពីរនាក់មានលក្ខណៈស្របគ្នាទៅនឹងជីវប្រវត្តិ យើងបានកើតចេញពីពិភពលោកពីរផ្សេងគ្នា ។ សៃមិន វីសេនថល បានទទួលរងការឈឺចាប់ក្នុងរបបណាហ្ស៊ី ក្នុងនាមជាយុវជនម្នាក់ ហើយខ្ញុំគ្រាន់តែជាក្មេងម្នាក់ដែលមានអាយុ១៣ឆ្នាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**សំណួរ** ៖ សៃមិន វីសេនថល គឺជាជនរងគ្រោះដូចជាលោក ។ គាត់បានរស់រានមានជីវិតពីភ័យខ្លាចក្នុងរបបណាហ្ស៊ីនិងជំរំលត់ដំ ហើយបន្ទាប់ពីសង្គ្រាម គាត់បានជួយនាំយកជនល្មើសជាច្រើនចូលគុក ។ បាវចនារបស់គាត់គឺយុត្តិធម៌និងមិនស្អប់ ។ តើលោកធ្លាប់ឮអំពីបាវចនានេះទេ ហើយតើបាវចនាអាចយកទៅប្រើប្រាស់នៅប្រទេសកម្ពុជាបានឬទេ?

**ចម្លើយ** ៖ បាទពិតប្រាកដណាស់ យុត្តិធម៌គឺជាទិដ្ឋភាពយ៉ាងសំខាន់ ហើយការស្អប់ខ្ពើមគឺតែងតែមិនមែនជាវិធីសាស្ត្រដ៏ត្រឹមត្រូវឡើយ ។

**សំណួរ** ៖ តើប្រព័ន្ធរបស់ខ្មែរក្រហម និងប្រព័ន្ធរបស់ណាហ្ស៊ីអាចប្រៀបធៀបគ្នាបានដែរឬទេ?

**ចម្លើយ** ៖ ប្រព័ន្ធទាំងពីរនោះមិនអាចធ្វើការប្រៀបធៀបគ្នាបានទេ ។ យើងមិនគួរប្រៀបធៀបពេលវេលាប្រវត្តិសាស្ត្ររបប ឬការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរទេពីព្រោះដំណើរការនៃការប្រៀបធៀបមានការចាត់ថ្នាក់ដូចគ្នា ដែលផ្អែកលើការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ វាមិនអាចធ្វើទៅរួចក្នុងការប្រៀបធៀបការឈឺចាប់របស់មនុស្សម្នាក់ទៅនឹងការឈឺចាប់របស់មនុស្សដទៃ ហើយក្នុងកម្រិតថ្នាក់ជាតិ ការឈឺចាប់របស់មនុស្សមានកម្រិតដូចគ្នា ។

***សំណួរ*** ៖ *លោកគឺជាសហអ្នកនិពន្ធនាយកសៀវភៅ “ស្លាកស្នាមអាថ៌កំបាំងរបស់កម្ពុជា” ។ តើមនុស្សគួរតែត្រូវបានជំរុញឲ្យលាតត្រដាងស្លាកស្នាមរបស់ខ្លួន ទាំងស្លាកស្នាមរាងកាយ និងស្លាកស្នាមផ្លូវចិត្តរបស់ខ្លួនទេ? តើប្រការនេះជួនកាលអាចក្លាយជាទណ្ឌកម្មលើកទី២ឬទេ? ខ្ញុំចង់រៀនសូត្របន្ថែមអំពីទស្សនៈស្រប និងទស្សនៈប្រឆាំងនៃទស្សនៈ “ស្លាកស្នាមអាថ៌កំបាំង” ។*

***ចម្លើយ*** ៖ *យើងមិនដែលបង្ខំឲ្យបុគ្គលលាតត្រដាងរឿងរ៉ាវផ្ទាល់ខ្លួនទេ ។ តម្រូវការចាំបាច់ក្នុងសង្គមដែលងើបចេញពីជម្លោះគឺត្រូវបង្កើតឱកាសដល់បុគ្គលទាំងឡាយដើម្បីឲ្យគាត់អាចចូលរួមក្នុងដំណើរការផ្សេងគ្នាក្នុងការព្យាបាលស្នាមរបួស ប៉ុន្តែចុងក្រោយ បុគ្គលនោះអាចរើសជម្រើសណាមួយដោយខ្លួនឯង និងត្រូវមើលថាតើត្រូវប្រឈមនឹងស្លាកស្នាមអតីតកាលរបស់ខ្លួនដោយរបៀបណា និងនៅពេលណា ។ មនុស្សជាច្រើនត្រូវបានជំរុញឲ្យចូលរួមក្នុងគម្រោងនានារបស់យើងពីព្រោះអ្នកទាំងនោះយល់ឃើញថា គាត់មានភាពជិតស្និទ្ធជាងមុនក្នុងការនិយាយចេញពីបទពិសោធរបស់ខ្លួន ។ ប៉ុន្តែ ក៏មានអ្នកផ្សេងទៀតដែរដែលគ្រាន់តែចង់ស្តាប់ដោយស្ងប់ស្ងាត់តែប៉ុណ្ណោះ រួចយកទៅគិតពិចារណា ។ មនុស្សមួយចំនួនចង់ទៅអង្គុយជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីមើលឃើញការជំនុំជម្រះជនជាប់ចោទ ប៉ុន្តែអ្នកខ្លះទៀតបានធូរចិត្តគ្រាន់តែដឹងថា អ្នកជាទីស្រឡាញ់របស់គាត់បានស្លាប់ដោយរបៀបណានិងនៅកន្លែងណា ។ ការព្យាបាលស្នាមរបួសអាចធ្វើឡើងដោយរបៀបជាច្រើន ។ អ្វីដែលសំខាន់គឺថា យើងមិនត្រូវជំរុញមនុស្សឲ្យប្រកាន់យកជម្រើសណាមួយទេ តែយើងត្រូវតែទុកឱកាសឲ្យគាត់ធ្វើការជ្រើសរើសដោយខ្លួនឯង ។ ការជំរុញឲ្យមនុស្សផ្តោះទៅរកដំណើរការណាមួយ ឬសកម្មភាពមួយ មិនត្រឹមតែមិនសមស្របប៉ុណ្ណោះទេ ថែមទាំងប្រព្រឹត្តអំពើអមនុស្សធម៌ទៀតផងពីព្រោះទង្វើបែបនោះបង្កប់អត្ថន័យ “ភាពជាចៅហ្វាយនាយ” ។ ខ្ញុំតែងនិយាយថា ខ្សែភាពយន្តមិនអាចថតអំពើប្រល័យពូជសាសន៍បានឡើយ ។ សៀវភៅមិនអាចរៀបរាប់ពីអំពើប្រល័យពូជសាសន៍ ហើយគ្មានដំណើរការតែឯងនៃការព្យាបាលស្នាមរបួស ការបង្រួបបង្រួម ការអប់រំអាចដោះស្រាយការប៉ះទង្គិចផ្លូវចិត្តរបស់មនុស្សបានឡើយ ។ យើងនឹងយល់ខុស ប្រសិនបើយើងគិតថា យើងអាចប្រែក្លាយបទពិសោធនៃអំពើប្រល័យពូជសាសន៍ឲ្យទៅជាកម្រិតមធ្យម ឬដំណើរព្យាបាលស្នាមរបួសឲ្យទៅជាមធ្យោបាយ ឬសកម្មភាពតែឯងមួយក្នុងការដោះស្រាយ ។ ក្នុងន័យនេះ មនុស្សដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត មិនចាំបាច់ឲ្យគេប្រាប់ថាវិធីសាស្ត្រមួយណាជាវិធីសាស្ត្រល្អបំផុតនោះទេ ។ កិច្ចការរបស់យើងតែងអនុវត្តតាមគោលការណ៍សីលធម៌នេះ ។*

***សំណួរ*** ៖ *តើប្រជាជនកម្ពុជាដោះស្រាយជាមួយនឹងការផ្សះផ្សា និងការលើកលែងដោយរបៀបណា? នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងដែលងើបចេញពីច្បាប់ប្រកាន់ពូជសាសន៍ចលនានេះធ្វើឡើងតាមរយៈជំនឿសាសនាគ្រឹស្ត ។*

***ចម្លើយ*** ៖ *ប្រជាជនកម្ពុជាអាចនាំរកការផ្សះផ្សារនិងការលើកលែងទោសតាមមធ្យោបាយផ្សេងពីសង្គមដទៃទៀត ។ ជនដៃដល់បានប្រើវិធីសាស្ត្រនៃការគោរពសណ្តានចិត្ត និងអំពើសប្បុរសនានាដើម្បីជាមធ្យោបាយមួយដើម្បីចង់ឲ្យមានការលើកលែងពីសំណាក់ជនរងគ្រោះ ។ ខ្ញុំមានឧទាហរណ៍មួយជាក់ស្តែងគឺថាអតីតកម្មាភិបាលខ្មែរក្រហមដែលអ្នកភូមិដឹងថាជាជនដៃដល់តែងតែដងទឹកឲ្យជនរងគ្រោះបង្ហាញនូវសន្តានចិត្តស្មោះត្រង់តែជនដៃដល់រូបនោះមិនដែលសុំធ្វើការសុំទោសដល់ជនរងគ្រោះដោយផ្ទាល់ទេ ។ ចំពោះជនបរទេស តវិយាបទនៃសន្តានចិត្តបង្កប់បែបនេះស្ទើរតែមិនអាចកត់សម្គាល់បាន ប៉ុន្តែរវាងជនរងគ្រោះនិងជនដៃដល់វិញ នេះគឺជាគំរូនៃការសុំទោស ហើយការទទួលយករបស់ជនរងគ្រោះ បង្ហាញពីការលើកលែងទោស ។*

*សាសនាគឺជាផ្នែកមួយ ដែលជាទូទៅត្រូវបានគិតថាអាចបង្កើតឲ្យមានការសម្រេចបាននូវការផ្សះផ្សានិងការលើកលែងទោស ប៉ុន្តែក៏ជាការសំខាន់ដែរ ដែលយើងត្រូវទទួលស្គាល់ទិដ្ឋភាពផ្សេងទៀត ក្រៅពីបញ្ហាសាសនានេះ ។ ចន្លោះពីឆ្នាំ១៩៧៩ ដល់១៩៨៤ មានការសងសឹកទៅលើកម្មាភិបាលខ្មែរក្រហមដែលនៅមានវត្តមានក្នុងប្រទេសកម្ពុជា ហើយនៅពេលដែលទង្វើបែបនេះមិនងាយរសាយ យើងកត់សម្គាល់ថា ការស្អប់ខ្ពើមជនដៃដល់មិនបានបាត់បង់ឡើយ ។ បច្ចុប្បន្ន ជនរងគ្រោះកំពុងរស់នៅជាមួយនឹងជនដៃដល់ក្នុងភូមិឃុំនានា ។ នៅភូមិឃុំជាច្រើនដែលជន*

វង្សគ្រោះដឹងអំពីអ្នកដែលសម្លាប់ អ្នកជាទីស្រឡាញ់របស់ខ្លួន ដូច្នេះហើយ តើអ្វីទៅដែលរារាំងជនរងគ្រោះពីការប្រព្រឹត្តទង្វើដដែលលើជនដៃដល់? ខណៈពេលដែល មនុស្សមួយចំនួនបានអះអាងថាព្រះពុទ្ធសាសនាជាអ្នកប្រៀនប្រដៅមនុស្សមិនឲ្យប្រព្រឹត្តដូច្នេះ ខ្ញុំជឿថានេះគឺគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះ ។ ការរីកចម្រើនស្ថានភាពសេដ្ឋកិច្ចរបស់មនុស្សនិងអត្ថប្រយោជន៍ផ្សេងទៀតដល់សហគមន៍ដែលមានសន្តិភាពលើកទឹកចិត្តដ៏ខ្លាំងក្លាដល់ជនរងគ្រោះឲ្យលើកលែងជនដៃដល់ ។ ក្រៅពីនេះ វាជាការលំបាកនៅពេលដែលមនុស្សកំពុងរកស៊ីចិញ្ចឹមគ្រួសារនៅពេលដែលខ្លួនកំពុងតែជម្រុះចោលនូវការស្អប់ខ្ពើម ហើយពេលនោះដែរមើលឃើញ និងបានជជែកជាមួយនឹងកូនឬចៅរបស់ជនដៃដល់បំណងនៃការសងសឹកក៏ធ្លាក់ចុះដែរ ។ សរុបមក សាសនាគឺជាទិដ្ឋភាពដ៏សំខាន់ចំពោះប្រទេសកម្ពុជា និងសង្គមទាំងឡាយ ប៉ុន្តែភាពថ្កើងថ្កាននៃសេដ្ឋកិច្ច ស្ថេរភាពសហគមន៍ ការស្រឡាញ់គ្រួសារ និងការសង្ឃឹមសម្រាប់អនាគតបម្រើដល់មុខងារយ៉ាងសំខាន់ដល់ដំណើរការនៃការលើកលែង ។

***សំណួរ*** ៖ តើសាសនានៅប្រទេសកម្ពុជាគឺជាខ្លឹមសារសម្រាប់ដោះស្រាយអតីតកាលជាប្រវត្តិសាស្រ្តដើម្បីជួយប្រជាជនឬ? សាសនាតែងតែត្រូវបានគាបសង្កត់ក្រោមរបបកុម្មុយនីស្ត ។

***ចម្លើយ*** ៖ មនុស្សព្យាយាមប្រើសាសនាដើម្បីព្យាបាលការប៉ះទង្គិចផ្លូវចិត្ត ពីព្រោះនេះជារបៀបរស់នៅរបស់ប្រជាជន ហើយវាមានតម្លៃយ៉ាងសំខាន់ជាច្រើនសម្រាប់ចង្អុលបង្ហាញអំពីដំណោះស្រាយជម្លោះ ។ ទោះបីជាយ៉ាងណាក៏ដោយ សាសនាមិនមែនជាខ្លឹមសារសំខាន់ក្នុងប្រទេសកម្ពុជាឡើយ ។ ការអភិវឌ្ឍគឺសំខាន់ជាងនេះទៅទៀត ។ ចាប់តាំងពីឆ្នាំ១៩៧៩ វត្តអារាមច្រើនជាងបួនពាន់វិហារឥស្លាមជាងបីរយ ព្រមទាំងវិហារសាសនាគ្រិស្តមួយចំនួនទៀតត្រូវបានសាងសង់ឡើង ប៉ុន្តែប្រជាជននៅតែមានបញ្ហា ។

***សំណួរ*** ៖ តើលោកយល់ឃើញយ៉ាងណាចំពោះការសងសឹក? ខ្ញុំអាចស្រមើស្រមៃថាការ លើកលែងគឺមិនមែនជាការងាយស្រួលឡើយ ។ ប្រសិនបើអ្នកជិតខាងរបស់ខ្ញុំធ្វើទារុណកម្មឬសម្លាប់សមាជិកម្នាក់ក្នុងចំណោមសមាជិកគ្រួសាររបស់ខ្ញុំ វាជាការលំបាកក្នុងការមិនគិតអំពីការសងសឹក ។ ខ្ញុំគិតថា លោកដឹងពីករណីនេះច្រើន ។

***ចម្លើយ*** ៖ ចន្លោះពីឆ្នាំ១៩៧៩ដល់១៩៨៤ មានសកម្មភាពសងសឹកជាច្រើនពីសំណាក់ជនរងគ្រោះមកលើខ្មែរក្រហម ។ ជនរងគ្រោះបានកំណត់អត្តសញ្ញាណខ្មែរក្រហមទាំងអស់ថាជាជនអាក្រក់ ដូច្នេះហើយអំពើហិង្សាព្រមទាំងទង្វើប៉ុនប៉ងផ្សេងៗត្រូវបានប្រព្រឹត្តឡើងពេញប្រទេសកម្ពុជា ។ កម្មាភិបាលខ្មែរក្រហមជាច្រើននាក់បានរត់គេចទៅប្រទេសថៃ ឬប្រទេសដទៃទៀត ហើយត្រឡប់មកវិញ ជាកម្លាំងនយោបាយមួយដែលមានចំណេះដឹងថ្មី ប៉ុន្តែមានផ្នត់គំនិតនៅតែដដែល ។ ប៉ុន្តែពេលវេលាស្ដែងឲ្យឃើញពីវដ្តនៃអំពើហិង្សា ។ ជនរងគ្រោះមានគំនិត ទស្សនៈ ចង់សងសឹកដល់អ្នកដែលបានសម្លាប់សាច់ញាតិរបស់ខ្លួន ។ នៅពេលដែលជនរងគ្រោះ និងជនដៃដល់រស់នៅក្នុងជីវិតបែបសាមញ្ញ ហើយមានបន្ទុកនៅក្នុងគ្រួសាររៀងៗខ្លួន បំណងនៃការសងសឹងទៅនឹងខ្មែរក្រហមក៏បានសាបរលាបដែរ ។ ប៉ុន្តែ ទោះបីជាជនរងគ្រោះនិងជនដៃដល់ចាប់ផ្ដើមជីវិតថ្មីរៀងៗខ្លួន កង្វះខាតនៃការផ្សះផ្សានិងភាពស្និទ្ធស្នាលគ្នា បង្កឲ្យមានបញ្ហានាពេលបច្ចុប្បន្ន ដោយជួបប្រទះនូវបញ្ហាមួយចំនួនដូចជា ជំងឺបាក់ស្បាត អារម្មណ៍មួម៉ៅដែលកើតចេញពីការប៉ះទង្គិចផ្លូវចិត្ត ព្រមទាំងការស្អប់ខ្ពើម កំហឹងនិងការអស់ជំនឿទៅលើមនុស្សនៅជុំវិញខ្លួន ។ នេះគឺជាហេតុផលដែលប្រជាជនកម្ពុជាកំពុងតែមានបញ្ហារហូតដល់សព្វថ្ងៃនេះ ។ ថ្វីត្បិតតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានបញ្ហាច្រើនយ៉ាងណាក៏ដោយ ក៏ប្រជាជនកម្ពុជាប្រហែលជា៨០ភាគរយនៅតែគាំទ្រដំណើរការស្វែងរកយុត្តិធម៌ពីសាលាក្ដីនេះ ។

***សំណួរ*** ៖ លោករស់រានមានជីវិតពីស្ថានភាពបែបនេះ ដែលសម្រាប់យើងខ្ញុំស្ទើរតែគិតថាមិនអាចនឹងរស់បានទាល់តែសោះ ។ តើលោកអាចគ្រប់គ្រងអារម្មណ៍សងសឹកដូចម្ដេច?

***ចម្លើយ*** ៖ ក្នុងឆ្នាំ២០០៧ ខ្ញុំបានសរសេរអត្ថបទបោះពុម្ពផ្សាយមួយមានចំណងជើងថា "ចោរប្រវត្តិសាស្រ្ត" ដែលក្នុងអត្ថបទនោះ ខ្ញុំបានពិពណ៌នាអំពីការជួបប្រទះជាមួយនឹងចោរវ័យក្មេងម្នាក់ដែលបានប៉ុនប៉ងចូលក្នុងផ្ទះរបស់ខ្ញុំ ។ ចោរនោះគឺជាក្មេងប្រុសម្នាក់ ដែលមានអាយុយ៉ាងច្រើនត្រឹម១៨ឆ្នាំ ។ ខ្ញុំដេញតាមចោរនោះ រហូតចាប់គាត់បាន ។ នៅពេលដែលគាត់ប៉ុនប៉ង

លោតចុះពីរានហាលខាងលើផ្ទះរបស់ខ្ញុំ ខ្ញុំចាប់ដៃគាត់ជាប់ ។ ភ្លាមនោះ ខ្ញុំក៏បាននឹកឃើញដល់អតីតកាលរបស់ខ្ញុំ ។ ខ្ញុំនឹកឃើញ ដល់សម័យ ប៉ុល ពត នៅពេលដែលខ្ញុំជាក្មេងទីក្រុងត្រូវបាន បង្ខំឲ្យទៅរស់នៅតាមជនបទ ដូចគ្នាទៅនឹងអ្នកទីក្រុងរាប់លាននាក់ ផ្សេងទៀត ។ កាលនោះ ខ្ញុំមិនមានជំនាញក្នុងការចិញ្ចឹមជីវិត ច្រើនទេ ប៉ុន្តែភាពអត់ឃ្លានធ្វើឲ្យខ្ញុំអាចរៀនពីរបៀបធ្វើឲ្យរស់ បានយ៉ាងលឿនដូចជា ខ្ញុំបង្រៀនខ្លួនឯងពីរបៀបហែលទឹក ដូច្នេះ ខ្ញុំអាចជ្រមុជទឹកដើម្បីទៅកាច់អំពៅដែលដុះក្នុងវាលស្រែលិចទឹក បាន ។ ហើយខ្ញុំរៀនពីរបៀបលួចអាហារ របៀបសម្លាប់ និង ហូបពស់ និងកណ្តុរ និងរបៀបស្វែងរកស្លឹកឈើដែលអាចហូបបាន នៅក្នុងព្រៃ ។ នៅពេលដែលខ្ញុំចាប់បានដៃរបស់គាត់ ចោរតូចម្នាក់ នោះបានធ្វើឲ្យខ្ញុំនឹកឃើញនូវការឈឺចាប់ដែលខ្ញុំបានទទួលរង ក្រោមរបបខ្មែរក្រហម ហើយធ្វើឲ្យខ្ញុំគិតអំពីមូលហេតុដែលនាំឲ្យ ចោរនោះចូលលួចរបស់របរក្នុងផ្ទះរបស់ខ្ញុំ ។ ប្រហែលជាគាត់ មានការអត់ឃ្លាន ។ ពេលដែលខ្ញុំ សម្លឹងមើលមុខចោរនោះ ខ្ញុំ នឹកឃើញពីភាពអត់ឃ្លានរបស់ខ្ញុំ ។

វាជារឿងអាចយល់បានដែលមនុស្សមានអារម្មណ៍ខឹង សម្បារចំពោះអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ប៉ុន្តែ ការប្រឈមមុខជាមួយអតីតជនដៃដល់ (ដូចជាចោរក្មេងម្នាក់ នោះ) អ្នកមិនអាចជម្រះខ្លួនឯងពីអំពើភាពជាមនុស្សបានឡើយ ។

**សំណួរ** : ខ្ញុំសុំត្រឡប់ទៅរកករណីរបស់លោក សែមិន វីសេនថល វិញ ។ ជួនកាល គាត់ត្រូវបានចោទនូវអ្វីដែលគាត់អាច រស់រានមានជីវិតបាន ជាពិសេសពីសំណាក់មនុស្សដែលស្អប់ការ ស្វែងរកការពិតរបស់គាត់ ។ អ្នកខ្លះនិយាយថា មានតែអ្នកនោះ សហការជាមួយជនដៃដល់ទេដែលអាចមានឱកាសរស់រានមាន ជីវិតពីជំរុំឃុំឃាំងបាន ។ តើធ្លាប់មាននរណាលើកពីបញ្ហានេះ ប្រឆាំងនឹងលោកឬទេ? ខ្ញុំអាចស្រមើស្រមៃឃើញថាតើការ ចោទប្រកាន់បែបនេះពិតជាឈឺចាប់ណាស់ ។

**ចម្លើយ** : មិនដែលមាននរណាមកចោទប្រកាន់ខ្ញុំទេ ប្រហែលជាពីព្រោះមកពីខ្ញុំគឺជាក្មេងក្នុងរបបខ្មែរក្រហមដែលមាន អាយុប្រហែល១៣ឆ្នាំ ។ សព្វថ្ងៃ អ្នកខ្លះមិនយល់ស្របជាមួយនឹង អ្វីដែលខ្ញុំកំពុងធ្វើទេ ប៉ុន្តែខ្ញុំនៅតែប្រកាន់យកអ្វីដែលខ្ញុំបានធ្វើ និង កំពុងធ្វើព្រោះខ្ញុំចង់ឲ្យមនុស្សគ្រប់គ្នាស្វែងរកការពិត និងអត្ថន័យ ក្នុងប្រវត្តិសាស្ត្រនេះដោយដោយខ្លួនឯង ។ ដំណើរការស្វែងរក ការបងចាំ និងយុត្តិធម៌ គឺជាដំណើរការជាតិមួយដែលជារឿងផ្ទាល់ ខ្លួនរបស់មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា ។

**សំណួរ** : តើយុវជនកម្ពុជាជំនាន់ក្រោយនាពេលសព្វថ្ងៃ សិក្សាអំពីប្រវត្តិសាស្ត្ររបស់ខ្លួនដោយរបៀបណា? តើមជ្ឈមណ្ឌល ឯកសាររបស់លោកមានលក្ខណៈសកម្មយ៉ាងណាក្នុងការងារអប់រំ?

**ចម្លើយ** : នាពេលបច្ចុប្បន្ននេះ យុវជនកម្ពុជាជំនាន់ក្រោយ សិក្សាអំពីប្រវត្តិសាស្ត្រនៅផ្ទះ និងតាមរយៈគ្រូរបស់ខ្លួន ។ ទន្ទឹម ពេលដែលប្រទេសកម្ពុជាបានអភិវឌ្ឍវិស័យអប់រំសាធារណៈគួរឲ្យ កត់សម្គាល់ ការអប់រំនៅតាមផ្ទះនៅតែជាប្រភពដ៏សំខាន់សម្រាប់ ព័ត៌មានអំពីអតីតកាលដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួម យ៉ាងសកម្មជាមួយនឹងស្ថាប័នទាំងនេះ តាមរយៈកម្មវិធីអប់រំអំពើ ប្រល័យពូជសាសន៍ដែលបានធ្វើដៃគូជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡាដើម្បីគាំទ្រកម្មវិធីសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យទូទាំងប្រទេស ។ ក្រៅពីការអប់រំតាមសាលា មជ្ឈមណ្ឌលឯកសារកម្ពុជា សកម្មក្នុងការលើកស្ទួយការអប់រំអំពើ ប្រល័យពូជសាសន៍តាមរយៈវេទិកាអប់រំសាធារណៈ ការបោះ ពុម្ពព្រឹត្តិប័ត្រ ទស្សនាវដ្ដី និងការផ្សព្វផ្សាយតាមវិទ្យុ ។ តាមរយៈ បណ្ដាញសារព័ត៌មាន មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធានាថា ការអប់រំអំពើប្រល័យពូជសាសន៍ នឹងត្រូវបានបង្រៀននៅតាម គ្រប់ផ្ទះ សាលារៀន និងសហគមន៍ ។

**សំណួរ** : ខ្ញុំសូមអរគុណ លោកមានអ្វីចង់បន្ថែមលើពាក្យ ពេចន៍ដែលលោកចង់និយាយអំពីខ្លួនលោកនិងការងាររបស់លោកទេ ។

**ចម្លើយ** : សាច់រឿងរបស់ខ្ញុំមិនសំខាន់នោះឡើយ ។ ម្ដាយ របស់ខ្ញុំនិងខ្ញុំមានសំណាងដែលបានរស់រានមានជីវិតពីរបប ខ្មែរក្រហម ។ សព្វថ្ងៃ យើងមានអាហារឆ្ងាញ់ជាងមុនសម្រាប់ហូប និងមានជីវិតប្រសើរជាងមុន ហើយខ្ញុំយល់ឃើញដោយផ្ទាល់ថា ការជួបជាមួយនឹងអ្នករស់រានមានជីវិតគឺជារឿងមានន័យណាស់ ដែលភាគច្រើននៃអ្នកទាំងនោះនៅតែរងទុក្ខនូវភាពក្រីក្រ បញ្ហា សុខភាពផ្លូវចិត្ត និងការចុះទន់ខ្សោយកម្លាំង ។ ការងាររបស់ខ្ញុំ គឺដើម្បីតំណាងឲ្យអ្នកទាំងអស់នោះ មិនមែនជារឿងផ្ទាល់ខ្លួនខ្ញុំទេ ។

# ទណ្ឌិត ផ្លែល្ពៅ



រូបគំនូរដោយអ្នកនិពន្ធ ឆាយ ស៊ីផាត្រ

**(តពីលេខមុន)**

នេះជាផ្នុះនៃជីវិតរបស់ខ្ញុំមិនដូចជាគណិតវិទ្យា ភាសាបារាំងនោះទេ តែខ្ញុំត្រូវរៀនសូត្រពីអ្នកស្រុកទាំងនោះដើម្បីសង់វាដោយមិនប្រើដែកគោលនោះឡើយ ។ អស្ចារ្យណាស់ រយៈពេលពីរថ្ងៃយើងបានកូនខ្ទមមួយសម្រាប់ដប់ប្រាំមួយដាក់ជ្រកនៅ ។ វាមិនគត់នឹងទឹកភ្លៀងប៉ុន្មានទេ ព្រោះខ្ញុំមិនមានពិសោធក្នុងការប្រកដំបូល ឯបងស្រីៗរបស់ខ្ញុំក៏គ្មានជំនាញក្នុងការដេរស្លឹកខ្ទង់ដែរ ។ ពេលវេលាធ្វើការបានមកដល់ហើយ ។ នៅទីនោះ រគាំងចាប់បន្ទឺសំឡេងនៅម៉ោងប្រាំព្រឹក ពេលដែលរគាំងសហករណ៍យើងចាប់បន្ទឺឡើងព្រមគ្នាជាមួយនឹងរគាំងសហករណ៍ជិតខាងបន្ទឺឡើងដែរ ។ នៅក្បែរនេះ ខាងលិចមានសហករណ៍តានប់ថ្មី ខាងកើតមានសហករណ៍តាំងឃ្នង និងឆ្ងាយពីនេះខាងលិចឈៀងខាងត្បូងគឺសហករណ៍ស្រែរបង ។ ការវាយលើកទីមួយនេះគឺដាស់យើងឲ្យក្រោកឡើងត្រៀមខ្លួនចេញទៅធ្វើការ ។ រគាំងវាយជាលើកទីពីរនៅម៉ោងប្រាំមួយ យើងត្រូវដើរសំដៅកន្លែងធ្វើការ ។ រគាំងវាយលើកទីបីនៅម៉ោងប្រាំពីរព្រឹកជាម៉ោងដែលយើងត្រូវធ្វើការផ្សារតាមមុខសញ្ញាផ្សេងៗ ។ ធម្មតារគាំងទាំងនេះច្រើនធ្វើអំពីដែកកំណាល់រទេះភ្លើង ឬកន្លែងខ្លះជាថាសកង់ឡាន វាព្យួរគួរឲ្យរន្ធត់

និងសង្កេតខ្លាំងណាស់ ។

រគាំងនេះគឺជាថាសរថយន្តជីអ៊ឹមសេ ហើយត្រូវបានចងព្យួរដោយប្រវាក់ទាក់នឹងមែកឈើក្បែរស្នាក់ការសហករណ៍កោះកណ្តាល ។ វាឮខ្លាំងណាស់អាចបានចម្ងាយដល់តាំងព្រេចស្រែរបងនិងតានប់ថ្មីប្រហែលប្រាំគីឡូម៉ែត្រ ។ អ្នកវាយរគាំងភាគច្រើនជាឈ្លប ឬនីរសារភូមិដែលមានអាយុប្រហែល១៣-១៧ឆ្នាំ អ្នកទាំងនោះជាកម្លាំងដ៏រឹងមាំរបស់អង្គការមានជំហរដាច់ខាតចំពោះមាគ៌ាបដិវត្តន៍ ។ ក្នុងរយៈពេលនេះ ខ្ញុំក៏ត្រូវចូលព្រៃរកកាប់សម្បកឈើយកមកដំនឹងខ្នងពូថៅហើយយកទៅត្រាំក្នុងទឹក ហើយយកខោអាវទាំងអស់មកជ្រលក់រួចហាលថ្ងៃឲ្យស្ងួត ។

ពេលដែលខោអាវជ្រលក់សម្បកឈើនោះស្ងួតហើយ ទើបយើងដើរសំដៅទឹកត្រពាំងណាដែលមានភក់ពណ៌ខ្មៅ យើងយកខោអាវនោះទៅជាន់ក្នុងភក់នោះ វានឹងឡើងពណ៌ខ្មៅក្រឹបខោអាវយើងមានពណ៌ខ្មៅមែន តែវាមិនមានភាពសង្ហាដូចខោអាវរបស់សមមិត្តទាំងនោះទេ ។ ខ្ញុំបានរក្សាទុកខោអាវល្អៗខ្លះសម្រាប់ទុកជាអនុស្សាវរីយ៍ កាលនៅជានិស្សិតសាកលវិទ្យាល័យគឺជ្រលក់ល្មមតែប្រើប្រាស់ពេលធ្វើការតែប៉ុណ្ណោះ ។

រគាំងវាយពីរលើក ហើយខ្ញុំត្រូវសមមិត្តមកហៅដល់មុខផ្ទះឲ្យចេញទៅជួបជុំគ្នានៅសហករណ៍ ។ ខ្ញុំជម្រាបម្តាយដែលសម្រាន្តនៅលើរនាបឫស្សីក្បាលកើយការុង ឯបងស្រី ប៊ុនណយ និងបងថ្លៃ ដានី និង ស៊ីថា ក៏ត្រូវចេញទៅដែរ ។ កូនតូចៗរបស់គាត់ដែលឈឺត្រូវនៅផ្ទះ ។ នៅសហករណ៍មិត្តសឿនមិត្តឡាន និង សំ កំពុងរង់ចាំយើងនៅទីនោះជាស្រេច ។ មិត្តសឿន បានបើកអង្គប្រជុំដោយអង្គុយផ្ទាល់ដីដូចធម្មតា ។ សមមិត្តសឿន លើកនេះដាច់ៗមុតៗដូចអាវុធថា «ខ្ញុំសូមជម្រាបពុកម៉ែបងប្អូនថា បដិវត្តន៍មិននៅស្ងៀមទេ គឺប្រៀបដូចជាទឹកធ្លាក់ពីលើកំពូលភ្នំ គ្មានកម្លាំងប្រតិកិរិយាណារារាំងបានឡើយ ។ ពុកម៉ែដឹងឬទេថាអង្គការបានធ្វើរគាំងនោះគឺជាសញ្ញាគោះជាប្រចាំដើម្បីរំឭកពីគោលជំហរដាច់ខាត ។ អង្គការភ្លឺស្វាងខ្លាំងណាស់ គឺភ្លឺស្វាងជាងព្រះអាទិត្យ គឺរុងរឿង ជានិច្ច គ្មានអ្វីប្រៀបស្មើបានឡើយ» ។

«ចំណែកពុកម៉ែបងប្អូនគឺដូចជាចន្ទុះមួយដែលត្រូវតែដុតៗ ហើយត្រូវតែឆ្កឹះ បើមិនឆ្កឹះវាពិតជាពុំភ្លឺឡើយ ហេតុដូច្នេះ ពុកម៉ែបងប្អូនត្រូវចាំថា បើឮសូររគាំងហើយត្រូវតែក្រោកឈរឡើងហាក់ដូចជាអង្គការកំពុងតែស្ថិតនៅនឹងមុខ ហើយត្រូវហាត់ពត់លត់ដំ និងឆ្កឹះជានិច្ចដូចជាចន្ទុះនេះដូច្នេះដែរ» ។

## ១៣) និន្នាការសង្គមចាស់

កម្មាភិបាលទាំងអស់ដែលធ្វើការនៅសហករណ៍នេះសុទ្ធតែជ្រើសរើសយ៉ាងហ្មត់ចត់ណាស់គឺសុទ្ធតែជាកសិករក្រីក្រ ពុំមានការរៀនសូត្រចេះដឹងឬក៏ពុំចេះអក្សរតែម្តង ក៏ប៉ុន្តែ ជាអ្នកសកម្មក្នុងការប្រយុទ្ធតស៊ូ ធ្វើការពុំចេះហត់នឿយ ពុំត្អូញត្អែរ ពុំតវ៉ាចំពោះបញ្ជារបស់អង្គការ ។ ក្នុងសម័យតស៊ូរំដោះប្រជាជាតិប្រជាធិបតេយ្យ អង្គការបដិវត្តន៍បានប្រមូលកម្លាំងគ្រប់ស្រទាប់វណ្ណៈដើម្បីផ្តួលរំលំរបបមូលធននិយម សក្តិភូមិផ្តាច់ការ ក៏ប៉ុន្តែអង្គការបានជម្រុះចោលម្តងមួយៗនូវអតីតមន្ត្រីនៃសង្គមចាស់ដោយបានបញ្ជូលម្តងមួយៗនូវអតីតកម្មាភិបាលវ័យក្មេងវ័យកណ្តាលដែល មិនមានការចេះដឹង មិនមានការអប់រំនៅក្នុងរបបសក្តិភូមិដែលចាត់ទុកថាជាពួកជនដែលមិនជាប់និន្នាការសង្គមចាស់ ។ អ្នកទាំងនោះមានគ្រូបង្រៀន មេឃុំ ជំទប់ ស្មៀន ប៉ូលិសទាហាន មេព្រៃ ។ អ្នកជាប់និន្នាការសង្គមចាស់ត្រូវបានរាប់បញ្ចូលទាំងឪពុកម្តាយ ជីដូន ជីតា នៃអ្នកទាំងនោះទៀតផង ។

ខ្ញុំសង្កេតឃើញថា មិត្តសឿន ចេះអក្សរតិចតួចហើយ គាត់ជាកូនកសិករក្រីក្រ ក៏ប៉ុន្តែ គាត់ជាមនុស្សដែលមានគោលជំហរដាច់ខាត ហើយស្មោះត្រង់បំផុតចំពោះអង្គការបដិវត្តន៍ ។ ចំពោះសមមិត្តដទៃដូចជា មិត្តសំ និង សោ ជាកសិករក្រដែលគ្មានដីធ្លីស៊ីឈ្នួលគេយកកម្រៃចិញ្ចឹមជីវិត ។ អ្នកទាំងនោះពុំបានរៀនសូត្រឡើយ ។ អង្គការបានពន្យល់ថា មូលហេតុដែលធ្វើឲ្យយើងក្រដូច្នេះគឺដោយសារតែវណ្ណៈសក្តិភូមិប្រតិកិរិយាដូចជារាជវង្សានុវង្ស មន្ត្រីព្រមទាំងអ្នកមូលធននិយម ពាណិជ្ជករ ជាវណ្ណៈជិះជាន់ បានសង្កត់សង្កិតយើងរាប់ពាន់ឆ្នាំមកហើយ ។ អាស្រ័យដូចនេះ អ្នកទាំងនោះត្រូវតែក្រោកឈរឡើងប្រឆាំងនឹងរបបជិះជាន់ទាំងនោះដោយប្រែក្លាយកំហឹងវណ្ណៈឲ្យឆេះសន្ធោសន្ធៅ វាយរំលំរបប ផ្តាច់ការ ជិះជាន់កសាងសង្គមថ្មីដែលប្រកបដោយសិទ្ធិសេរីភាព ប្រជាធិបតេយ្យ និងស្មើភាព ។ ឥឡូវនេះបដិវត្តន៍វណ្ណៈអធនបានឈ្នះហើយ ប្រជាជនគឺជាម្ចាស់វាសនាប្រទេសជាតិ ពួកសក្តិភូមិត្រូវតែកម្ទេច គឺប្រជា

កសិករក្រីក្រទាំងនោះហើយជាអ្នកដឹកនាំវាសនាប្រទេសជាតិ អ្នកមិនចេះអក្សរក៏អាចធ្វើអ្នកដឹកនាំបានដែរ ឲ្យតែមានជំហរបដិវត្តន៍ស្មោះត្រង់ចំពោះអង្គការដើម្បីបុព្វហេតុវណ្ណៈអធន និងធ្វើការដោយមិនខ្លាចនឿយហត់ ។

កម្មាភិបាលទាំងនោះ ត្រូវឆ្លងកាត់ការពិសោធរបស់អង្គការច្រើនណាស់ ដូចជា ការប្រយុទ្ធនៅសមរភូមិទល់នឹងរដ្ឋការ លន់ នល់ ការធន់ទ្រាំនឹងការអត់ឃ្លាន និងជំងឺគ្រុនចាញ់ គ្មានថ្នាំសង្កូវ ហើយពេលវេលាក៏គេអត់ធ្មត់ និងសរសើរការដឹកនាំរបស់អង្គការដ៏មហាអស្ចារ្យភ្លឺស្វាង មហាលោតផ្លោះ ។

## ១៨) ជនមូលដ្ឋានចាស់ ឬ ជន១៧មេសា

អង្គការហៅយើងថា១៧គឺសំដៅលើអ្នកដែលរស់នៅក្រោមរបប លន់ នល់ ដែលត្រូវបានជម្លៀសចេញនៅថ្ងៃ១៧ មេសា ១៩៧៥ ចំណែកអ្នកដែលរស់នៅក្នុងតំបន់តស៊ូ ត្រូវទទួលស្គាល់ថាជាជនមូលដ្ឋានចាស់ ជនទាំងពីរប្រភេទនេះនយោបាយខុសគ្នា ។ ចំពោះរូបខ្ញុំ គឺជាកម្លាំងទីមួយនៃជន១៧ មេសា ជាកម្លាំងនៅជួរមុខប្រឈមនឹងការងារធ្ងន់ៗ និងលំបាក ឯមេក្រុមរបស់យើងគឺជាជនមូលដ្ឋានចាស់មាននាទីដឹកនាំនិងការងារត្រួតពិនិត្យគោលជំហររបស់យើងមានរាងធាត់ក្រអាញ មានឈ្មោះថា មិត្តអ៊ិន ។ មិត្តអ៊ិន មានអាយុ២៥ឆ្នាំ ជាមនុស្សរួសរាយ ទឹកមុខញញឹមជានិច្ច ការងាររបស់យើងគឺកាសរំលើងគល់ឈើដើម្បីធ្វើស្រែ ។

មិត្ត អ៊ិន មានកម្លាំងដូចក្របី កាប់ដីផងច្រៀងចម្រៀងបដិវត្តន៍ផង មើលទៅដូចជាពុំចេះហត់ទាល់តែសោះ ។ គាត់ពោលសរសើរអង្គការពុំដាច់ពីមាត់ គាត់ថាអង្គការជាកំពូលអ្នកដឹកនាំដ៏មហាភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ ។ គាត់បានបង្ហាញខ្ញុំអំពីរបៀបកាសរំលីងគល់ឈើយ៉ាងណា កុំឲ្យបាក់ដងចប ។ បើយើងធ្វើបាក់ដងចប នោះអង្គការនឹងចាត់ទុកយើងជាខ្មាំង ។ មិត្តអ៊ិន បានប្រាប់យើងថា គាត់ពុំចេះអក្សរទេ ព្រោះឪពុកម្ដាយគាត់ក្រពេក ។ គាត់បានចូលបម្រើកងទ័ពតាំងពីរដ្ឋប្រហារទម្លាក់សម្ដេចនរោត្តមសីហនុមកម្ល៉េះ ក៏ប៉ុន្តែឥឡូវគាត់ត្រូវបានរំសាយដោយសារគាត់មានឪពុកមាម្នាក់ធ្វើជាទាហានរដ្ឋការ នល់ នល់នៅបន្ទាយមាស ។ មិត្តអ៊ិន ពន្យល់យើងថា«ត្រូវខំធ្វើការហើយកុំនិយាយអ្វីឲ្យប៉ះពាល់ដល់អង្គការឲ្យសោះ» ។ ក្រុមយើងមានគ្នាដប់ប្រាំនាក់ក្នុងនោះមានអតីតនិស្សិតពីរនាក់ អតីតនិស្សិតសាស្ត្រាចារ្យមកពីភ្នំពេញម្នាក់ កូនពាណិជ្ជករពីរនាក់ ឯអ្នកដទៃជាអ្នកស្រែធម្មតា ។ មិត្តអ៊ិន តែងតែចំអន់ខ្ញុំថា អាចឹក មិនធ្វើអ្វីសោះ តើអាចរស់នៅម្ដេចបានទៅ? យើងកាប់រំលំដើមឈើធំៗរួចហើយដឹកទាំងគល់តូចៗ ត្រូវកាប់ពង្រាងហើយដុតចោល អ្នកខ្លះទៀតកាប់រំលាយដីបូកទាំងតូចទាំងធំ ពង្រាបដីឲ្យក្លាយជាស្រែ មិត្តអ៊ិន ពន្យល់យើងទៀតថា សតិអារម្មណ៍របស់មនុស្សយើងប្រៀបដូចជាកាំបិតមួយ បើចង់កាប់អ្វីមួយឲ្យដាច់ យើងត្រូវតែសំលៀងវា ។ យើងត្រូវសំលៀងសតិអារម្មណ៍ឲ្យមុតស្រួចជានិច្ច ពីព្រោះយើងត្រូវកាប់ឆ្ការប្រឆាំងនឹងសតិអារម្មណ៍ពីសង្គមចាស់ ហើយលត់ដំខ្លួនដើម្បីឲ្យដូចជាប្រជាជនមូលដ្ឋានចាស់ គាត់បានបន្ថែមថា អង្គការបដិវត្តន៍បានតស៊ូលំបាកខ្លាំងណាស់ទម្រាំបានជោគជ័យដូចថ្ងៃនេះ គឺត្រូវតស៊ូតាំងពីបាតដៃទទេ អង្គការបដិវត្តន៍ជាអង្គការដ៏វាងវៃ មហាភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ ។ ក្នុងចំណោមយើងជាយុវជនដែលធ្វើការជាមួយគ្នា ខ្ញុំបានស្គាល់មិត្តជិតស្និទ្ធម្នាក់ឈ្មោះ យឿន ជាអនិ្ទតដែលទើបនឹងសឹក ជាកូនកសិករក្រ វណ្ណៈថ្នាក់ក្រោម ។ គាត់ចេះធ្វើសព្វកិច្ចការដូចជា កាប់គាស់ដីទាំងនោះ ។ ខ្ញុំធ្វើការបណ្ដើរនឹកគិតដល់សុខភាពរបស់ម្ដាយខ្ញុំបណ្ដើរព្រមទាំងៗក្ដួយដែលនៅចាំឪពុកម្ដាយរបស់ខ្លួនពេលត្រឡប់មកដល់ផ្ទះវិញ ។

ពេលបាយថ្ងៃត្រង់ក៏ឈានមកដល់រគាំងសហករណ៍បានបន្លឺឡើង មិត្តអ៊ិន លើកដៃដាក់ជាសញ្ញាសម្រាកការងារ ។ យើងផ្អែកចប ប៉ែល និងទុកដាក់បង្គី កាំបិត ដើម្បីបរិភោគអាហារថ្ងៃត្រង់ ។ ក្នុងចិត្តខ្ញុំរំពឹងទុកថា នឹងបានទទួលបាយសម្លយ៉ាងសមរម្យ ក៏ប៉ុន្តែខ្ញុំខកចិត្តយ៉ាងខ្លាំងនៅពេលដែលចុងភៅបានហុចមកយើងនូវបបរមួយចានចំណុះមួយវែក ដោយគ្មានត្រីសាច់អ្វីទាំងអស់ទាល់តែសោះ ។ ចុងភៅជាអ្នកមូលដ្ឋានចាស់ វាល់បបរឲ្យយើងតែមួយវែកទាំងបន្លែស្ងោរបង់អំបិលក្នុងមួយចានធំ ត្រូវទទួលទានរួមគ្នាប្រាំនាក់ ។ បបរនោះមានគ្រាប់អង្ករបន្តិចន្តួចវាវ ។ មិត្តអ៊ិន បរិភោគដូចយើងដែរ គឺមួយចានម្នាក់ប៉ុណ្ណោះ ខ្ញុំសង្កេតឃើញថា មិត្តអ៊ិនមានទឹកមុខរីករាយធម្មតា គាត់បានពន្យល់ប្រាប់យើងថា ក្នុងសម័យសង្គ្រាមប្រាំឆ្នាំ មានពេលខ្លះគាត់ដាច់បាយរហូតដល់ប្រាំថ្ងៃក៏មានដែរក៏ប៉ុន្តែដើម្បីបុព្វហេតុវណ្ណៈអធន គាត់ប្រឹងតស៊ូដើម្បីបណ្ដេញ

ចក្រ ពត្តិអាមេរិក និង លន់ នល់, សិរិមតៈ, អ៊ិន តាំ, ចេង ហេង ។ កាលណោះ ខ្ញុំជឿថា ភាពញញឹមរបស់មិត្តអ៊ិន គឺជាការពិត ក៏ប៉ុន្តែ ក្រោយមកទើបខ្ញុំដឹងថា មិត្តអ៊ិន ញញឹមតែខាងក្រៅប៉ុណ្ណោះ ព្រោះគាត់ក៏មានបញ្ហាផ្ទាល់ខ្លួនដែរ ។ មិត្តអ៊ិន ជាអតីតយុទ្ធជនជាប់និន្នាការសេរីដោយសារតែឪពុកមាគាត់ជាទាហាន លន់ នល់ បើសិន គាត់ពុំបញ្ចេញរីករាយទេនោះ វាសនារបស់គាត់ក៏ស្ថិតក្នុងភាពមិនប្រាកដប្រជាដែរ ។

ហូបបបរបណ្តើរ អារម្មណ៍របស់ខ្ញុំបានហោះហើរទៅកាន់ពិភពនៃការពិចារណាបណ្តើរ ។ ខ្ញុំពិចារណាអំពីឪពុកខ្ញុំដែលជាអតីតនាយទាហានបារាំង ។ ក្នុងជីវិតរបស់គាត់ គាត់រស់នៅតែក្នុងជីវភាពហ៊ឺហា ពេលព្រឹកគាត់ជួបជុំមិត្តភក្តិនៅហាងគុយទាវ ជជែកវែកញែកពីរឿងនយោបាយ ។ ឪពុកខ្ញុំជាអ្នកគាំទ្រដ៏សកម្មចំពោះសម្តេចឪនរោត្តម សីហនុ គាត់តែងតែចោទសេនាប្រមុខ លន់ នល់ ថា ក្បត់ជាតិ គាត់ប្រឆាំងនឹងក្មួយៗ ព្រមទាំងកូនប្រសារដែលសុទ្ធតែជាទាហាន លន់ នល់ ។ គាត់តែងតែពាក់អាវយឺតម៉ាកដែលផលិតនៅប្រទេសបារាំង ពេលធ្វើដំណើរបន្តិចបន្តួច គាត់ជិះកូនម៉ូតូបារាំង ។ ឥឡូវនេះហាងគុយទាវរបស់ឪពុកខ្ញុំ ក្លាយជាព្រៃស្រោង តុកាហ្វេ របស់គាត់ គឺគល់ព្រេច អាវរបស់គាត់ជាក្រមារហែក ។

ក្នុងវ័យជិតចិតសិបឆ្នាំរបស់គាត់ គាត់ដើរតត្រុកក្នុងព្រៃស្បាត ស្វែងរកផ្សិត ពពេល និងផ្លែឈើយកមកឲ្យកូនចៅហូប ។ ខ្ញុំចង់តែស្រែកសួរទេវតាថា តើសិទ្ធិសេរីភាពនៅឯណា សម្តេចឪទ្រង់គង់នៅឯណា? ហេតុអ្វីប្រែប្រួលអស់យ៉ាងនេះ ខ្ញុំចង់ស្រែកទ្រហោយំស្រណោះដល់ឪពុកខ្ញុំ ឯណាទៅសេចក្តីថ្លៃថ្នូររបស់អតីតទាហានដែលធ្លាប់ប្រយុទ្ធនៅសមរភូមិ ឯណាទៅសន្តិភាពសេរីភាព ។

ខ្ញុំមិនច្បាស់ទេអំពីនយោបាយ អំពីការដឹកនាំ ឬប្រហែលជាចំណេះដឹងរបស់ខ្ញុំមានតិចតួចពេក ។ ខ្ញុំសិក្សាអំពីពាណិជ្ជសាស្ត្រសេដ្ឋកិច្ចនៅមហាវិទ្យាល័យ ហើយក្នុងវ័យរបស់ខ្ញុំកាលណោះ ខ្ញុំមានចំណាប់អារម្មណ៍តិចតួចណាស់អំពីនយោបាយ ឯឪពុកខ្ញុំមានការចេះដឹងច្រើន ព្រមទាំងបទពិសោធក្នុងជីវិតរបស់គាត់ ។ កាលគាត់នៅក្មេង គាត់ធ្លាប់បានមកដល់ទីនេះ គាត់បានស្គាល់អ្នកស្រុកនេះច្រើនណាស់ ក៏ប៉ុន្តែ ពេលនេះអ្នកស្រុកទាំងនេះបានបែរមុខចេញ ហើយធ្វើជាពុំស្គាល់គ្នា ព្រោះរយៈពេលប្រាំឆ្នាំនៃសង្គ្រាម អ្នកទាំងនោះ និងឪពុកខ្ញុំបានរស់នៅពិភពផ្សេងគ្នា ។

ខ្ញុំក៏បានគិតទៅដល់ម្តាយខ្ញុំដែលជាស្ត្រីម្នាក់សុភាពទន់ភ្លន់ មានអារម្មណ៍រីករាយនិងញញឹមជានិច្ច ។ គាត់ជាពុទ្ធសាសនិកដ៏ខ្ជាប់ខ្ជួន ។ រាល់ថ្ងៃសីលគាត់តែងតែទៅវត្តសុំសីល ។ ម្តាយខ្ញុំតែងតែបន់ស្រន់ដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមជួយឲ្យសម្តេចឪព្រះបិតាឯករាជ្យជាតិទ្រង់ឆាប់យាងត្រឡប់មកមាតុប្រទេសវិញ ។ គាត់មិនដែលធ្វើបាបសូម្បីតែសត្វតូចតាចក៏ពុំដែលបៀតបៀនទោះបីជាសត្វស្រមោចមួយក៏ដោយ ។ ពេលនោះតើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទៅទីណា សម្តេចឪទ្រង់គង់នៅទីណា? សូម្បីតែពេលដែលត្រូវខ្មែរក្រហមបណ្តេញជាប់មាត់ ពុទ្ធំ ធម្មំ សង្ឃំ ហើយពេលនេះគាត់កំពុងតែមានជំងឺ ក៏គាត់ទន្ទេញជាប់រកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ម្តាយខ្ញុំមិនព្រម ហូបត្រី សាច់ កូនកង្កែប ឬកំពិស ដែលកូនៗរកបានតាមវាលស្រែនោះឡើយ ម៉្លោះហើយសុខភាពរបស់គាត់កាន់តែដុនដាបទៅៗ ខ្ញុំស្តុងអារម្មណ៍មួយភាំងដោយបបរក្នុងចានមានបរិមាណតិចតួចហួសពេកពុំដឹងថា អស់ពីពេលណាដង ក៏ភ្ញាក់ដោយសំឡេងរគាំងសហករណ៍នៅវេលាម៉ោងមួយ ។ យើងសម្រុកការងារបន្តទៀត នៅទីនោះគេប្រើពាក្យប្លែកៗដែលខ្ញុំពុំធ្លាប់បានឮ ។ សម្រុកបានន័យថា ធ្វើការឲ្យបានញាប់ដៃជើងកុំខ្ជិលហត់ដូចជា ទាហានដែលកំពុងសម្រុកវាយបន្ទាយខ្មាំង ។ យើងចាប់កាំបិត ខ្វេវ ចប ប៉ែល ពូថៅ ធ្វើការកាប់គាស់យ៉ាងពេញទំហឹង ។ គ្មាននរណាហ៊ានសម្រាកទេ ព្រោះខ្លាចគង់ប្រវត្តិសាស្ត្រវិលជាន់ ។

### ១៥) កសាង កម្ទេច លត់ដំ

ពុំមែនជាការងាយស្រួលឡើយ បើសិនជាយើងបរិភោគបបរមួយចានដែលគ្មានសាច់ និងបន្លែស្ទើរតិចតួច ហើយធ្វើការធ្ងន់ដប់ពីរម៉ោងនោះ ក៏ប៉ុន្តែ មិត្តអ៊ិន នៅតែសើចសប្បាយ និងច្រៀងចម្រៀងបដិវត្តន៍ ប្រហែលជានៅផ្ទះគាត់នៅមានអាហារបម្រុងផ្សេងទៀតដាក់ជាពុំខាន ចំណែកយើងទទួលតែអាហារបន្តិចបន្តួចតែប៉ុណ្ណោះ ។ មិត្ត អ៊ិន មានមោទនភាពណាស់ជាជនបដិវត្តន៍អស្ចារ្យរបស់អង្គការ ។ ក្នុងជីវិតជិតបួនឆ្នាំនៃរបបនោះ ខ្ញុំបានឮពាក្យដដែលជាច្រើនពាន់ដងពីអង្គការដ៏មហាអស្ចារ្យ ។ រសៀលថ្ងៃដដែលនោះ គល់ឈើទាំងឡាយដែលយើងបានគាស់រំលើងហើយវាហាក់មានទម្ងន់កាន់តែធ្ងន់ឡើង ដោយសារតែយើងបានបរិភោគអាហារតិច

តូចពេក ។ មិត្តអ៊ន ពុំចេះអាន និងសរសេរទេ ពីព្រោះគាត់បានចូលរួមចំណែកតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិកកាលសម័យសង្គមរាស្ត្រនិយម ឪពុករបស់គាត់ធ្វើជាកម្មកររោងចក្រអារឈើនៅស្តុកអាចម៍រមាស ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ មិត្តអ៊ន បាននិយាយប្រាប់យើងថា ថៅកែឈើនោះឈ្មោះថា ថៅកែសុង ហើយប្រពន្ធរបស់ថៅកែនោះឈ្មោះ ចែគី ។ គ្រាន់តែឮឈ្មោះថៅកែ សុង និង ចែគី នោះខ្ញុំស្គាល់អស់ហើយ ព្រោះនោះជាឈ្មោះ ម្តាយមីងខ្ញុំ និងស្វាមីរបស់គាត់ ។ មិត្ត អ៊ន បន្តថា ចែគី ជាថៅកែស្រី ជាមនុស្សចិត្តល្អណាស់ ក៏ប៉ុន្តែថៅកែ សុង ជាមនុស្សអាក្រក់ណាស់ដែរ កាលពីមុនសង្គ្រាមថៅកែ សុង បានចាប់រំលោភឈ្នួលស្រីបម្រើផ្ទះបាយជាច្រើននាក់ ហើយក៏បានសងជំងឺចិត្តជាប្រាក់បន្តិចបន្តួច ។

មិត្តអ៊ន បន្តទៀតថា ក្រោយថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ឪពុករបស់គាត់ដែលក្តាប់កម្មករ បានចេញមុខធានាគ្រួសាររបស់ចែគី ក៏ប៉ុន្តែកំហឹងវណ្ណៈ ពុំអាចលុបជ្រះបានទេ ។ គ្រួសាររបស់ចែគី ត្រូវបានអង្គការកម្ទេចនៅជើងភ្នំអន្ត ខាងលិចផ្សាររមាស តាំងពីថ្ងៃជម្លៀសមកម្ល៉េះ ។ ពាក្យថា "កម្ទេច" នេះត្រូវបានប្រើជំនួសពាក្យថាសម្លាប់ចំពោះអ្នកណាដែលត្រូវអង្គការយល់ថាប្រឆាំងបដិវត្តន៍ ។ គ្រួសារ ចែគី ដែលមានកូន និងចៅរបស់គាត់រួមទាំង២៦ នាក់ ត្រូវបានកម្ទេច ។ ចៅស្រីក្រមុំៗ និងជំទង់ត្រូវបានរំលោភមុន និងកម្ទេច ឯទារកតូចៗត្រូវបោកនឹងគល់ឈើ ចំណែកមនុស្សចាស់ត្រូវវាយនឹងដំបង ត្បូងចប និងអារក ។ អ្នកទាំងអស់គ្នាត្រូវបានកប់ក្នុងរណ្តៅតែមួយ ។

មិត្តអ៊ន ក៏បានពន្យល់យើងទៀតថា ចំពោះអ្នកដែលខ្ជិលគឺប្រឆាំងនឹងបដិវត្តន៍ហើយ ។ ដូច្នេះយើងត្រូវលត់ដំខ្លួនឲ្យដូចជាលត់ដែកថែបឲ្យរឹងដូច្នោះដែរ ចំពោះកាំបិតឬពូថៅយើងត្រូវលត់ដំវាឲ្យរឹងដើម្បីឲ្យមុត ចំណែកឯជនបដិវត្តន៍ក៏ត្រូវលត់ដំគោលជំហរដើម្បីឲ្យមុតស្រួចចំពោះមុខអង្គការ ។ ចំពោះអ្នកដែលមានគោលជំហរមិនមុតស្រួចកសាងខ្លួន ។ "កសាងខ្លួន" មានន័យថា ព្យាយាមបំភ្លេចរបស់របបចាស់ចាប់យករបបថ្មី ជាជនបដិវត្តន៍គំរូបំបាត់កម្មសិទ្ធិ ហើយបើពុំដូច្នេះទេ អង្គការនឹងហៅយើងយកទៅកសាងដាក់ជាពុំខាន ។ ក្នុងមួយថ្ងៃនេះ ខ្ញុំរៀនសូត្រអំពីបដិវត្តន៍បានច្រើនមែនទែន ។

## ១៦) ផ្ទះបាយសមូហភាព

ខ្ញុំទៅធ្វើការគាស់ដីស្រែបានជាច្រើនថ្ងៃ ។ ការងារកាន់តែធ្ងន់ ឯរបបអាហារកាន់តែតិច ។ ពេលសម្រាក យើងឆ្លៀតចាប់កូនកង្កែប កណ្តូប ដង្កូវខ្ទួង យកមកដុតបរិភោគ ថ្ងៃមួយយើងតែងហូបនៅកន្លែងធ្វើការដូចសព្វដង ។ ពេលរគាំងវាយនៅម៉ោងដប់មួយកន្លះ មិត្ត អ៊នក៏បានប្រាប់យើងឲ្យទៅបរិភោគបាយឯផ្ទះបាយសមូហភាព ពេលនេះប្រជាជនលែងមានសិទ្ធិហូបបាយឯកជន គឺហូបសមូហភាព ចានបាយត្រូវបានតម្រៀបលើតុរួចជាស្រេច ។ មួយស្តុកមានចានបាយបួន និងចានសម្លមួយ ។ ចុងភៅសុទ្ធតែជាអ្នកមូលដ្ឋានចាស់ ។ របបដែលទទួលបានគឺមានបបរមួយវែកនិងចានសម្លសម្រាប់បួននាក់អស់ហើយ គ្មានអ្វីថែមទេ ម្តងគឺជាការស្រេច ។ យើងរង់ចាំស្នូរជួងទើបចាប់ផ្តើមបរិភោគ ។ នៅទីនោះ អង្គការហាមដាច់ខាតប្រើពាក្យថា ស៊ី ឬ ញ៉ាំត្រូវប្រើពាក្យ "ហូប" ទាំងអស់គ្នា ។ យើងហូបយ៉ាងស្ងៀមស្ងាត់ព្រោះស្ថិតនៅក្រោមការត្រួតពិនិត្យពីកម្មាភិបាល ។ គ្រប់គ្នាត្រូវមកហូបនៅទីនេះ ។ ខ្ញុំអង្គុយចុះហើយកាន់ស្លាបព្រាសម្លឹងមើលបបរនៅនឹងចានដែលរាវហើយថ្លាដូចទឹកភ្លៀង ខ្ញុំគិតថាបបរបដិវត្តន៍នេះវាថោកទាបជាងម្ហូបរបស់ឆ្កែទៅទៀត រីឯសម្លក្នុងចាននោះវិញគឺជាបន្លែចម្រុះ មានល្ពៅ គល់ចេក ដំឡូងជ្វា ស្ងោរលាយគ្នា ។ បើសម្លឹងឲ្យយូរបន្តិចយើងឃើញមានកំពឹសតូចៗ តែទោះយ៉ាងណា វាមានលក្ខណៈតិចតួចបំផុតសម្រាប់អ្នកធ្វើការដប់ពីរម៉ោងក្នុងមួយថ្ងៃ ។ ចំណែកបបរវិញ បើខ្ញុំហុតតែមួយគ្រូកគឺអស់ពីចានតែម្តង ។

## ១៧) ភ្នំពេញត្រូវបានជម្លៀស

ពេលព្រលប់ប្រហែលម៉ោងប្រាំពីរ ទើបខ្ញុំមកដល់ផ្ទះ យើងគ្មានចង្កៀង ចន្លុះសម្រាប់បំភ្លឺទេ នៅក្រោមផ្ទះមានភ្នក់ភ្លើងសម្រាប់បំភ្លឺ និងបណ្តេញមូស ។ ម្តាយខ្ញុំសម្រាន្តនៅលើរនាបជិតជុប ។ គាត់មានទឹកមុខស្លេកស្លាំងដោយជំងឺគ្រុនចាញ់ ។ ខ្ញុំភ្ញាក់ព្រើត ដោយនៅចុងជើងរបស់គាត់ឃើញបងប្រុសរបស់ខ្ញុំ ប្រពន្ធ និងកូនបីនាក់របស់គាត់ ខ្ញុំមានបងប្អូនប្រាំបួននាក់ហើយជាកូនទីប្រាំបី ។ ចំណែកគាត់មានឈ្មោះ ប៊ុនថាន់ គឺជាសាស្ត្រាចារ្យបង្ហាត់រូបវិទ្យា និងគីមី នៅវិទ្យាល័យព្រះយុគន្ធរ ដែលក្នុងសម័យ លន់ នល់ បានប្តូរឈ្មោះវិទ្យាល័យ១៨ មីនា ។ ភរិយារបស់គាត់ឈ្មោះ ស៊ីណេ កូនស្រី

*ច្បងអាយុប្រាំបីឆ្នាំឈ្មោះ ដូលី កូនប្រុសបន្ទាប់ ដូឡែត, ពៅ ហៅ អាកាណុល និងកូនស្រីពៅឈ្មោះ លីន ដា អាយុបីឆ្នាំ ។ បងប្រុសខ្ញុំចេះផ្នែកអក្សរសាស្ត្រ វប្បធម៌ផង ។ គាត់ចូលចិត្តអានកាសែត និងតាមដានស្ថានការណ៍ប្រទេសជាតិ ។ កាលជំនាន់សម្តេចឪ បងប្រុសខ្ញុំធ្លាប់បានចូលរួមក្នុងចលនាប្រឆាំង សីហនុ ជាយុវជនម៉ាក្សលេនីននិយម គាត់ចេះដឹងពីទ្រឹស្តីសង្គមនិយមច្រើន គាត់ប្រឆាំងវណ្ណៈសក្តិភូមិ អំពើពុករលួយ និងការសង្កត់សង្កិន ។ ប៊ុនថាន់ បានរៀបរាប់ដំណើររឿងដែលគាត់បានមកដល់ទីនេះ ។*

*ថ្ងៃ១៧មេសា វេលាម៉ោង៩ព្រឹក យោធាមានឯកសណ្ឋានពណ៌ខ្មៅបានប្រកាសតាមមេក្រូថាឲ្យយើងទៅកាន់អាកាសយានដ្ឋានពោធិ៍ចិនតុង ដើម្បីទទួលសម្តេច សីហនុ ។ ពេលនេះ ប៊ុនថាន់ បានបើករថយន្តរបស់គាត់ដឹកភរិយាព្រមទាំងកូនទាំងបីនាក់ តាមមហាវិថីសហភាពសូវៀតឆ្ពោះទៅទិសខាងលិច ។ បងប្រុស ប៊ុនថាន់ បានបន្តទៀតថា យើងបានចាកចេញពីផ្ទះដោយគ្មានបាយមកជាមួយទេ ក្នុងឡានមានតែរបស់បន្តិចបន្តួចដូចជានំបីស្ទី និងទឹកក្រូច ព្រោះគិតថាឲ្យតែមានលុយក៏អាចទិញអ្វីនៅទីណាក៏បានដែរ មិននឹកស្មានថាមិនចាយលុយដូច្នេះសោះ ។*

*ពេលដែលបើកឡានដល់ផ្សារទឹកថ្លា បងប្រុសដឹងខ្លួនពុំអាចថយក្រោយបានទេ ព្រោះមនុស្សម្នានៅតាមផ្លូវសហភាពសូវៀតកាន់តែច្រើនឡើងៗ និងធ្វើដំណើរទៅមុខក៏ជួបការលំបាក ។ ប៊ុនថាន់ក៏ចេះតែបើកឡានទៅមុខយឺតៗ ម៉ូតូ ឡាន ប្រជ្រៀតគ្នាយ៉ាងណែនណាន់តាន់តាប់មកដល់ព្រលានយន្តហោះពោធិ៍ចិនតុងក៏ពុំឃើញមាននរណាប្រាប់ថាឲ្យឈប់ចាំទទួលសម្តេចឪ គាត់ក៏ចេះតែរុលទៅមុខបន្តិចៗ ដើម្បីរកផ្លូវត្រឡប់ក្រោយវិញក៏ប៉ុន្តែពេលនោះក៏ឮសូរកាំភ្លើងបាញ់ទៅលើផ្លូវៗ ពេលនោះស្រាប់តែមានឡានហ្ស៊ីបមួយបានបើកមកដល់ ។*

*សមមិត្តម្នាក់បានបញ្ឈរកាំភ្លើងអាកា៤៧ ហើយបាញ់ទៅលើមេឃផ្ទួនៗ ហើយស្រែកបញ្ជា តាមមេក្រូ បងប្អូនពុកម៉ែ មាមីងទាំងឡាយសូមប្រញាប់ធ្វើដំណើរទៅមុខឲ្យលឿន ពួកចក្រពត្តិអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ កុំបកក្រោយចូលទីក្រុងឲ្យសោះ មិនបាច់យកអ្វីទៅតាមខ្លួនទេ អង្គការបដិវត្តន៍មាននៅគ្រប់ទីកន្លែង បងប្អូនពុកម៉ែ នឹងមិនខ្វះអ្វីទេ លឿនឡើងប្រញាប់ឡើង ។ បងប្រុសបានបើករថយន្តដឹកភរិយា និងកូនទាំងបីរហូតដល់ផ្សារថ្នល់ទទឹង គាត់ចង់បត់ឡានមកក្រោយ តែនៅត្រង់ផ្លូវបំបែកនោះយោធាខ្មែរក្រហមបានធ្វើសញ្ញាដៃឲ្យបត់ស្តាំ ។*

*យោធាខ្មែរក្រហមម្នាក់បានតម្រង់កាំភ្លើងមកឡានរបស់បងប្រុសខ្ញុំឲ្យបញ្ឈប់ឡានហើយនិយាយថា នែមិត្ត! បដិវត្តន៍គឺដើម្បីភាពស្មើគ្នាដូច្នេះគ្មាននរណាម្នាក់មានសិទ្ធិបើកឡានទេ សូមមិត្តទុកឡាននៅទីនោះចុះ អង្គការនឹងថែរក្សាឡាននេះទុកជាសម្បត្តិសមូហភាពរហូតដល់មិត្តកសាងខ្លួនរួចចាំមកយកវិញចុះ ។*

*គ្រួសារគាត់ដើរតាំងពីផ្លូវបំបែកផ្សារថ្នល់ទទឹង តាមបណ្តោយផ្លូវរថភ្លើងដោយមិនធ្លាប់ជួបការលំបាកបែបនេះ កូនៗស្រែកយំដោយសារកម្តៅថ្ងៃ ស្រេកទឹក និងឃ្លាន ។ បងប្រុសខ្ញុំ និងភរិយាបានលើកដៃសុំទានអ្នកដំណើរដូចគ្នាដើម្បីបានបាយបន្តិចបន្តួចផ្តល់ឲ្យកូន ទីបំផុតប្រពន្ធគាត់បានយកខ្សែកពេជ្រមួយខ្សែដូរបានអង្ករ៥គីឡូ និងឆ្នាំងបាយមួយ ។ ខ្សែកនោះ បើលក់សម័យនេះអាចទិញបានអង្ករ១០តោន ។ បងប្រុសខ្ញុំបានសួរនាំអ្នកស្រុកដើម្បីរកផ្លូវទៅកាន់ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងក្នុងបំណងស្វែងរកឪពុកម្តាយ ។ គ្រួសារគាត់ធ្វើដំណើរដោយថ្មើរជើងជាងមួយអាទិត្យ ទើបមកដល់ស្ថានីយ៍រថភ្លើងស្តុកអាចម៍រមាស ក៏បានទទួលដំណឹងពីយើងទាំងអស់គ្នាថានៅទីនេះ ។ ខ្ញុំស្តាប់បងប្រុសដំណាលពីដំណើររបស់គាត់ដ៏លំបាករហូតមកដល់ទីនេះ ។ ខ្ញុំបានយកបបរដែលទទួលពីសហករណ៍ជូនទៅម្តាយខ្ញុំ តែគាត់ប្រាប់ថាឲ្យទៅបងប្រុស ហើយគាត់ក៏បានហុចចានបបរនោះទៅកូនរបស់គាត់គឺ ដូឡែត, អាកាណុល ឬអាក្នុល គឺក្មួយប្រុសនេះហើយដែលជាមូលហេតុដែលនាំឲ្យខ្ញុំសរសេរសៀវភៅនេះឡើង ។ រឿងបានកើតឡើងជិត៣៧ឆ្នាំហើយជារឿងដែលខ្ញុំចាំជាប់ក្នុងចិត្តគ្មានថ្ងៃបំភ្លេចបាន ។ អាក្នុលជាកូនប្រុសទោលក្នុងគ្រួសារ ជាក្មេងទំយើហើយស៊ីច្រើន វាទទួលបបរពីដៃឪពុកហើយហុតតែម្តងក៏អស់បបរពីចានរលីង ។*

## ១៨) យើងខ្ញុំកុមារស្រឡាញ់អង្គការឥតមានព្រំដែន

*ព្រឹកបន្ទាប់សំឡេងរគាំងបន្ទឺឡើងដូចសព្វដង ។ ម្តាយខ្ញុំក្អកយ៉ាងខ្លាំង ។ បងប្រុស និងប្រពន្ធគាត់ភ្ញាក់ពីដំណេកព្រោះគាត់ត្រូវទៅចុះឈ្មោះនៅសហករណ៍ ចំណែកខ្ញុំត្រូវរៀបចំចបនិងបង្គីដើម្បីចេញទៅធ្វើការ ។ ពេលនោះខ្ញុំបានឮសំឡេងរបស់មិត្ត សំ ដែលជា*

សមាជិកកម្មាភិបាល ។

សូមពុកម៉ែទាំងអស់បញ្ជូនកូនដែលមានអាយុពី៦ឆ្នាំដល់ ១៨ឆ្នាំទៅកាន់ជំរំកុមារឈានមុខ ចំណែកកម្លាំងទីមួយត្រូវទៅសហករណ៍ឥឡូវនេះដើម្បីទទួលការចាត់តាំងពីអង្គការ ។

ខ្ញុំមិនទាន់យល់ច្បាស់ថា តើនរណាខ្លះជាកម្លាំងទីមួយនៅឡើយទេតែពេលនោះមិត្ត សំ ញញឹមយ៉ាងចម្លែកហើយចង្អុលមកកាន់ខ្ញុំគឺរូបបងឯងហ្នឹងហើយ ព្រមទាំងមិត្ត ណយ មិត្ត ស៊ីថា ផានី ត្រូវទៅសហករណ៍ឥឡូវនេះ ។

នៅទីធ្លាមុខសហករណ៍យើងឃើញមិត្ត សឿន ឈររង់ចាំរួចជាស្រេច ។ នៅក្បែរមិត្ត សឿន ក៏មានកម្មាភិបាលជាច្រើនរូបទៀត ។ យើងជាជន១៧មេសាឬ ប្រជាជនថ្មី មានប្រហែលជាកៅសិបនាក់បានអង្គុយចុះនៅពីមុខ មិត្ត សឿន ព្រមទាំងកម្មាភិបាលដទៃទៀត ។ មិត្ត សឿន បានបើកអង្គប្រជុំ ជាបឋមខ្ញុំសូមបើកអង្គប្រជុំ ។ មុននឹងបើកអង្គប្រជុំខ្ញុំសូមខ្ទេសនាមមានរូបខ្ញុំផ្ទាល់កម្មាភិបាល និងពុកម៉ែ បងប្អូនប្រជុំថ្ងៃនេះ គឺដើម្បីពង្រឹងគោលជំហរបដិវត្តន៍អនុវត្តការងារដែលអង្គការថ្នាក់លើបានប្រគល់ឲ្យ ។ សូមពុកម៉ែ បងប្អូន បញ្ចេញពលកម្មពុំខ្លាចនឿយហត់ ដើម្បីបុព្វហេតុវណ្ណៈអធន វិធានការបង្កបង្កើនផលឲ្យបានមួយហិចតាបីតោន ។ ទន្ទឹមនឹងនេះ សូមបងប្អូនជម្រុះឲ្យអស់នូវកម្មសិទ្ធិផ្ទាល់ខ្លួន កុំរវើរវាយកុំរម្លឹកពីសង្គមចាស់ ពេលនេះចលនាបដិវត្តន៍កំពុងតែធ្វើដំណើរទៅមុខ អ្នកដែលទម្រន់ដេកផ្សំដួល រមួលផ្សំគ្រេចនឹងត្រូវចាត់ទុកជាខ្មាំងសតិអារម្មណ៍ ដូច្នេះត្រូវខំកសាងខ្លួន ។ បើយើងកសាងខ្លួនមិនបានទេ ប្រយ័ត្នកង់ប្រវត្តិសាស្ត្រវិលជាន់ព្រោះប្រវត្តិសាស្ត្រពុំរង់ចាំយើងឡើយ ។ ខ្ញុំត្រូវបានបញ្ចូលរួចជាស្រេចហើយក្នុងកម្លាំងទីមួយ ប៉ុន្តែលើកនេះ យើងត្រូវបានបន្ថែមដល់២៥នាក់ ចំណែកបងប្រុសខ្ញុំ ប៊ុនថាន់ពុំត្រូវបានចាត់ចូលក្នុងកម្លាំងណាមួយទេ ។

បងស្រីខ្ញុំ ប៊ុនណយ ព្រមទាំងបងស្រីពីរនាក់ ផានី និង ស៊ីថា ត្រូវចាត់ទុកជាកម្លាំងទី២ ។ ឪពុកម្តាយខ្ញុំត្រូវបានចាត់ទុកជាកម្លាំងទីបី ។ កម្លាំងទី៤គឺជាក្មេងដែលមានអាយុលើសពី៦ឆ្នាំ ដល់១៨ឆ្នាំ ដូច្នេះកូនៗរបស់បងខ្ញុំប្រាំមួយនាក់ត្រូវបានអង្គការញែកចេញពីឪពុកម្តាយឲ្យចូលក្នុងជួរកុមារ មានក្មេងទាំងអស់ប្រហែលជាងសាមសិបនាក់ ត្រូវបំបែកចេញពីឪពុកម្តាយ ។ ពេលនោះមិត្ត សឿន បានណែនាំ យើងឲ្យស្គាល់យុវជនម្នាក់មានអាយុប្រហែល ២០ឆ្នាំ សប្បុរខ្មៅ មាឌមាំដូចមនុស្សប្រុស កាត់សក់ខ្លីដល់ត្រចៀក ។ ឯកសណ្ឋានពណ៌ ខ្មៅក្រិប ពាក់ស្បែកជើងកង់ឡានដែលស្តែងចេញនូវជំហរបដិវត្តន៍ ដ៏មុតស្រួច ។ គាត់បង់កក្រមាពណ៌ក្រហមស្រស់បញ្ចេញខ្សែភ្នែកដ៏មុឹងម៉ាត់ ។ មិត្ត សឿន ខ្ទេសនាមសមមិត្តថ្មីនេះគឺមិត្ត រ៉េត ។ គាត់ ទទួលខុសត្រូវនៅមណ្ឌលកុមារបដិវត្តន៍ឈានមុខ ។ ពីថ្ងៃនេះតទៅ ប្អូនកុមារា កុមារីនឹងក្លាយទៅជាកុមារបដិវត្តន៍ គឺជាកូនបង្កើតរបស់ អង្គការរស់នៅហូបចុក បាយទឹករបស់អង្គការ ធ្វើពលិកម្មឲ្យអង្គការ ស្មោះត្រង់នឹងអង្គការប្តូរជីវិតដើម្បីអង្គការ ដើម្បីបុព្វហេតុវណ្ណៈ ។ ត្រូវឈប់គិតអំពីឪពុកម្តាយដែលរស់នៅសមរភូមិក្រោយ ត្រូវសម្លឹងទៅរកអនាគតសមរភូមិ ។ មិត្ត រ៉េត គឺជាបងគ្រូរបស់ប្អូនៗ គឺជាជនបដិវត្តន៍ និងលត់ដំប្អូនឲ្យក្លាយទៅជាជនបដិវត្តន៍ ពុំមែនដូចជាគ្រូបង្រៀនក្នុងសង្គមចាស់ដែលបង្រៀនតែពីការជិះជាន់វណ្ណៈផ្តាច់ការ ។ កុមារបដិវត្តន៍មិនចាំបាច់ចេះអក្សរនោះទេ ចប កាំបិត ក៏អាចក្លាយទៅជាប៊ិច ខ្មៅដៃ វាលស្រែក៏នឹងក្លាយជាសៀវភៅរបស់ប្អូនៗ ឯម្ជប់ឈើទាំងឡាយក៏អាចជាសាលារៀនរបស់ប្អូនដែរ ។

មិត្ត សឿន សង្កត់ពាក្យកាន់តែធ្ងន់ដោយចង្អុលទៅកាន់កុមារាកុមារីនោះ ពីថ្ងៃនេះតទៅប្អូនៗ នឹងលែងបានរស់នៅជាមួយឪពុកម្តាយទៀតហើយ ព្រោះថាឪពុកម្តាយរបស់ប្អូនៗក៏មានការងារនិងភារកិច្ចដើម្បីធ្វើជូនអង្គការដែរ នៅក្នុងជួរបដិវត្តន៍ ទីណាក៏ជាផ្ទះនរណាក៏ជាឪពុកម្តាយបងប្អូនរបស់យើងដែរ សូមប្អូនចាប់ចេញដំណើរទៅជាមួយ មិត្ត រ៉េត ទៅកាន់ជំរំកុមារឈានមុខឥឡូវនេះ ។ ក្នុងចំណោមក្មួយខ្ញុំទាំងប្អូននាក់ អាក្នុល វាតូចជាងគេ ។ វាអាយុប្រាំមួយឆ្នាំ គឺគ្រប់អាយុនឹងក្លាយជាកុមារបដិវត្តន៍ឈានមុខ ។ ក្មេងៗភាគច្រើន ស្រែកយំដោយសារតែពុំធ្លាប់បែកពីឪពុកម្តាយ ។ អាក្នុលយំយ៉ាង ខ្លាំងហើយក្រាញននាលពុំព្រមដើរទៅមុខ ។ អាក្នុលជាក្មេងមានៈ ជាកូនរបស់សាស្ត្រាចារ្យម្នាក់ដែលក្នុងគ្រួសារពុំធ្លាប់ជួបការ លំបាក ជាក្មេងទំយើ ហើយក្នុងអាយុ៦ឆ្នាំ វាពុំយល់អ្វីសោះដែលហៅថាកុមារបដិវត្តន៍ឈានមុខ ។ ពេលនោះមិត្ត រ៉េត ដែលជាកូនគ្រូបង្រៀនបានស្ទុះចេញមកចាប់ដៃអាក្នុល ហើយវាយយ៉ាងខ្លាំង ។ ព្រឹត្តិការណ៍នេះពុំអាចលុបបាត់ពីអារម្មណ៍របស់ខ្ញុំទេ ទោះជាង

៣៧ឆ្នាំ ហើយក៏ដោយ ។ មិត្ត រ៉េត វាយលើក្មួយរបស់ខ្ញុំដូចប៉ូលិសវាយចោរ ហើយសមមិត្តម្នាក់បានស្ទុះទៅជួយអាក្មួល ហើយទាត់ធាក់វាជាច្រើន ដើម្បីរួចអូសដៃទៅជាមួយក្មេងដទៃទៀត រីឯដូលី ជាបងអាក្មុល និង ជាក្មួយស្រីខ្ញុំក៏បានលើកដៃសំពះ មិត្ត រ៉េត និងសមមិត្តនោះ ។ ខ្ញុំពុំបានស្គាល់ទេ ក៏ប៉ុន្តែខ្ញុំសន្និដ្ឋានដូលី បានអង្វរកុំឲ្យវាយប្អូនប្រុសរបស់នាង ។ ក្បួនដំណើររបស់ក្មេងៗបានរសាត់ឆ្ងាយពីខ្សែភ្នែកយើង ឪពុកម្ដាយដែលខំតស៊ូតាមមើលដំណើររបស់កូននោះ បានលើកដៃជាសញ្ញាថាលាហើយស្រមោលរបស់កូន ក៏កប់បាត់ទៅកាន់ជំរុំកុមារបដិវត្តន៍ឈានមុខ ។ ពេលនោះ សំឡេងមេក្រូនៅសហករណ៍ក៏បានចាក់បទចម្រៀងយើងខ្ញុំកុមារស្រឡាញ់អង្គការឥតមានព្រំដែន ដោយសារតែអង្គការយើងខ្ញុំរស់រានជីវិតថ្កើងថ្កានរុងរឿងអស្ចារ្យ ។

## ១៩) អនុប្រជាជន

ពេលដែលកូនៗបានចាកចេញផុតទៅ បងថ្លៃស្រីខ្ញុំ ស៊ីណេ ព្រមទាំងបងស្រីបង្កើត ប៊ុនណយ បងប្រុស ប៊ុនថាន់ ព្រមទាំងអ្នកដទៃក៏សម្រក់ទឹកភ្នែកអាឡោះអាល័យកូន ។ ស៊ីណេ លើកដៃជាសញ្ញាបាយៗតាមបែបអាមេរិកកាំង គឺជាការឈឺចាប់បំផុត ប៉ុន្តែទាំងអស់គ្នាបានភ្ញាក់ស្មារតីឡើងវិញនៅពេលដែលសំឡេងរបស់ សឿន ។

ចូរអ្នកទាំងអស់គ្នាកុំយំសោកឲ្យសោះ អ្នកទាំងនោះពុំមែនទៅស្លាប់ឯណា គឺទៅស្វែងរកជីវិតល្អសម្រាប់ប្រទេសជាតិ អ្នកទាំងនោះនឹងក្លាយទៅជាជនបដិវត្តន៍ជាគ្រឹះរឹងមាំរបស់អង្គការ និងប្រជាជន គាត់ក៏បែរមករក ស៊ីណេ ដែលកំពុងតែជូតទឹកភ្នែក កុមារទាំងអស់ប្រៀបដូចជាទំពាំងស្នងឫស្សី ត្រូវតែក្លាហាន រឹងមាំដូចដែកថែប ដែលបានលត់ដំយ៉ាងល្អ ហើយធំដឹងក្ដីឡើងក្នុងស្មារតីបដិវត្តន៍ មិនដូចជាអ្នកពាល់គ្នាដែលជោគជាំទៅដោយសតិអារម្មណ៍សង្គមចាស់នោះទេ ។

មិត្ត សឿន ធ្វើសញ្ញាបាយៗ ហើយចង្អុលបង្ហាញមុខ ស៊ីណេ នេះជាកាយវិការប្រតិកិរិយា សក្ដិភូមិ ចក្រពត្តិនិយមដែលសង្គមចាស់និងរបប លន់ នល់ បន្សល់ទុកមកក្នុងសង្គមបដិវត្តន៍ និងមិនអនុញ្ញាតឲ្យធ្វើដូច្នេះទៀតទេ បដិវត្តន៍គឺមានភាពស្មើគ្នាគ្មានការសំពះជម្រាបសួរ ឬធ្វើដៃបែបចក្រពត្តិជាដាច់ខាត ។ មិត្ត សឿន បានពន្យល់ទៀតថា យើងត្រូវតែបរិសុទ្ធ ហើយស្មើសាច់ដូច ជាគ្រាប់អង្ករក្នុងកញ្ចើមួយ ។ អង្គការនឹងរែងរហូតដល់គ្រាប់អង្ករមើលទៅស្មើសាច់ រីឯអង្កាម ក្រួស ផ្កាស្មៅ និងចុងអង្ករនឹងត្រូវរើសចេញយកទៅដាក់កន្លែងផ្សេងឬកម្ទេចចោល ។ មិត្ត សឿន បានរំសាយអង្គប្រជុំ ហើយប្រាប់ឲ្យយើងទៅកាន់កន្លែងធ្វើការរៀងខ្លួន ។ លើកនេះខ្ញុំពុំបានទៅធ្វើការនៅកន្លែងចាស់ទៀតទេ ដោយចាត់ឲ្យមកធ្វើជាមួយក្រុមយុវជនមួយក្រុមផ្សេងទៀត ។ មេក្រុមរបស់យើងគឺមិត្តផល ដែលមានវ័យចំណាស់ប្រហែល២៨ឆ្នាំ ។ ចំណែកឯបងស្រីប៊ុនណយ បងថ្លៃស្រីទាំងអស់គឺ ស៊ីណេ ដានី និង ស៊ីថា បានធ្វើការនៅកងស្រីៗដូចកម្លាំងទ័ពដូចជាម្ដាយខ្ញុំត្រូវមើលក្មេង ឯពុករបស់ខ្ញុំត្រូវឃ្វាលគោក្របី ។ ចំពោះបងប្រុសខ្ញុំ ប៊ុនថាន់ ព្រមទាំងអ្នកដទៃទៀត ត្រូវរង់ចាំការចាត់តាំងរបស់អង្គការនាពេលបន្តិចទៀត ។

នាល្ងាចថ្ងៃដដែល ពេលបរិភោគអាហាររួចខ្ញុំក៏បានត្រឡប់មកផ្ទះដូចសព្វដង ។ សុខភាពរបស់ម្ដាយខ្ញុំកាន់តែទ្រុឌទ្រោមណាស់ទៅហើយ ។ ពេលត្រឡប់ពីឃ្វាលគោវិញ ពុកខ្ញុំបានផ្សិតក្រោក ខ្លះយកមកឲ្យខ្ញុំស្ងោរបង់អំបិល ព្រមជាមួយនោះ បងស្រី និងបងថ្លៃដែលមកពីស្រែមកលាងហើយចាក់ចូលជាមួយគ្នាស្ងោរក្នុងឆ្នាំងតែមួយ ។ ក្នុងឆ្នាំងដីធំនេះមានកូនត្រីកំពឹស ក្ដាម ខ្យង ព្រលិត ត្រកួន ស្ងោរលាយគ្នា ។ វាគ្មានរសជាតិអ្វីទេ ព្រោះវាគ្មានគ្រឿងគ្រាអ្វីទាំងអស់ យើងនាំគ្នាបរិភោគយ៉ាងស្ងៀមស្ងាត់បន្ថែមលើបបរមួយចានដែលយើងបានទទួលនៅផ្ទះបាយសមូហភាព ។ ទោះយ៉ាងនេះក្ដី ក៏យើងពុំបានបរិភោគឆ្អែតដែរ ព្រោះយើងមានគ្នាច្រើនដូច្នេះញ៉ាំបានតែមួយកូនចានម្នាក់ប៉ុណ្ណោះ ។ ព្រលប់ហើយ ទើបឃើញបងប្រុស ប៊ុនថាន់ ត្រឡប់មកដល់ដោយទឹកមុខស្រពាប់ស្រពោន និងហត់នឿយ ។ បងប្រុសបានប្រាប់យើងទាំងអស់គ្នាថា យើងខ្ញុំជាអតីតអ្នករដ្ឋការដែលត្រូវបានចាត់ទុកជាអនុប្រជាជន ។ ខ្ញុំភ្ញាក់ផ្អើលនឹងពាក្យនេះជាខ្លាំង គឺជាពាក្យថ្មីដែលសូម្បីនៅមហាវិទ្យាល័យក៏ខ្ញុំពុំដែលបានឮដែរ ។ សាស្ត្រាចារ្យ គ្រូបង្រៀន វេជ្ជបណ្ឌិត អ្នកឯកទេសនានាដែលធ្លាប់បម្រើឲ្យរដ្ឋការ លន់ នល់ ទាំងអស់ត្រូវស្ថិតនៅក្នុងជំពូកអនុប្រជាជនទាំងអស់ ។ ប៊ុនថាន់ សម្លឹងទៅប្រពន្ធដែលកំពុងឱបជាប់កូនស្រីពៅឈ្មោះ លីនដា នៅនឹងដៃ ។ ស្អែកនេះ អង្គការនឹងបញ្ជូនខ្ញុំព្រមទាំងអ្នកដទៃឲ្យទៅរៀនសូត្រមុននឹងប្រគល់កិច្ចការថ្មីឲ្យធ្វើ ។ **(នៅមានត) ឆាយ ស៊ុំឆាត្រ**

# តើខ្ញុំនៅមានសេសសល់សាច់ញាតិឬទេ?



សុខ ថៃ (ស្តាំ) ថតជាមួយនឹងមិត្តភក្តិនៅដើមទសវត្សរ៍៨០

សុខ ថៃ អាយុ៤៣ឆ្នាំ ជាប្រធានផ្នែកទីផ្សារនៅក្រុមហ៊ុនមួយនៅទីក្រុងភ្នំពេញ ។ នៅចន្លោះម៉ោងធ្វើការ ឬពេលទំនេរពីការងារ ថៃ តែងតែឈៀងចូលមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីអានទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅផ្សេងៗទៀតដែលតម្កល់នៅសាលអានសាធារណៈ ។ តាមរយៈការអាននេះ បានធ្វើឲ្យ ថៃ នឹកឃើញឡើងវិញពីការបែកបាក់របស់ក្រុមគ្រួសារគាត់នៅក្នុងរបបខ្មែរក្រហម ដោយរៀបរាប់ថា ៖

ខ្ញុំកើតក្នុងគ្រួសារដែលមានជីវភាពធូរធារមួយនៅជិតផ្សារថ្មី ក្នុងទីក្រុងភ្នំពេញ ។ មុនខ្មែរក្រហមឡើងកាន់អំណាច ក្រុមគ្រួសារខ្ញុំរស់នៅយ៉ាងមានសុភមង្គល ។ យើងមានឡាន មានអាហារឆ្ងាញ់ៗ មានប៉ាម៉ាក់ផ្តល់ភាពកក់ក្តៅ និងមានសម្ភារល្អៗដែលធ្វើឲ្យខ្ញុំនិងក្រុមគ្រួសារស្គាល់តែភាពសប្បាយរីករាយ ។ ជាអកុសល នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អ្វីៗទាំងអស់បានចាប់ផ្តើមផ្លាស់ប្តូរនៅពេលខ្មែរក្រហមបានចូលមកកាន់កាប់ទីក្រុងភ្នំពេញ និងធ្វើការជម្លៀសប្រជាជនទាំងអស់ចេញពីផ្ទះដោយយកលេសថា អាមេរិកនឹងមកទម្លាក់គ្រាប់បែក ។ ខ្មែរក្រហមបានប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញរយៈពេលបីថ្ងៃ ដូច្នេះហើយក្រុមគ្រួសារខ្ញុំមិនបានយករបស់អ្វីតាមខ្លួនច្រើនទេ យើងយកតែសម្ភារប្រើប្រាស់ស្រាលៗមួយចំនួន រួចធ្វើដំណើរទៅខេត្តកំពត ព្រោះម្តាយខ្ញុំមានបងប្អូនរស់នៅទីនោះ ។ ប្រហែលជា១៥ថ្ងៃក្រោយមក យើងបានដើរទៅដល់ភូមិមួយនៅជិតវត្តស្រះចក ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត ។ ខ្ញុំនិងក្រុមគ្រួសារក៏បានឈប់សម្រាកជាមួយបងប្អូននៅទីនោះរយៈពេលមួយខែ តែដោយសារពុំមានអាហារបរិភោគគ្រប់គ្រាន់ និងខ្វះថ្នាំព្យាបាល ប្អូនប្រុសរបស់ខ្ញុំក៏បានស្លាប់នៅទីនោះដោយសារជំងឺរាក ។

ក្រោយមក គ្រួសារខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅភូមិសត្វពង ឃុំបានៀវ ស្រុកឈូក ខេត្តកំពត ។ ពេលទៅដល់ទីនោះដំបូង ខ្មែរក្រហមបានអនុញ្ញាតឲ្យយើងរស់នៅជួបជុំគ្រួសារដូចអ្នកមូលដ្ឋានដទៃទៀតដែរ ។ ប៉ុន្តែប្អូនខែក្រោយមក ខ្មែរក្រហមចាប់ផ្តើមបែងចែកប្រជាជនជាបីកង គឺ កងកុមារ កងចល័តយុវជន និងកងចាស់ៗ ។ ពេលនោះហើយជាពេលដែលខ្ញុំទើបមានអាយុប្រាំឆ្នាំត្រូវរស់នៅបែកពីប៉ាម៉ាក់ ព្រោះប៉ាម៉ាក់ខ្ញុំត្រូវខ្មែរក្រហមជម្លៀសឲ្យទៅធ្វើការនៅកងចល័តក្នុងភូមិផ្សេងទៀត ។ ខ្ញុំត្រូវរស់ដោយពឹងលើខ្លួនឯងទាំងមិនទាន់ដឹងក្តី ។

នៅទីនោះ ខ្មែរក្រហមអនុញ្ញាតឲ្យប្រជាជនឈប់សម្រាកចំនួនមួយថ្ងៃរៀងរាល់ដប់ថ្ងៃម្តង ដែលជាឱកាសឲ្យប្រជាជនអាចជួបជុំក្រុមគ្រួសារបាន ។ នៅពេលនោះ ដោយសារខ្ញុំក្មេងជាងគេនៅក្នុងកង ទើបកម្មាភិបាលខ្មែរក្រហមមិនសូវជាយកចិត្តទុកដាក់

ប្រើការវាយតប់ន្តឹងខ្លាំងលើខ្ញុំប៉ុន្មានទេ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែខិតខំធ្វើការងារសម្រាប់កង ដូចជា រើសអាចម៍គោ និងកាប់ដើមទន្រ្ទាន ខែត្រជាដើម ដើម្បីឲ្យប្រធានកងស្រលាញ់ទុកចិត្ត ។

នៅខណៈនោះ ខ្ញុំក៏មានអារម្មណ៍នឹកដល់ប៉ាម៉ាក់ខ្លាំងដែរ និងតែងតែធ្វើឲ្យខ្ញុំមិនសប្បាយចិត្ត ។ ហេតុដូច្នេះហើយ នៅពេលដែលក្មេងៗដទៃទៀត កំពុងដេកនៅពាក់កណ្តាលអាធ្រាត ខ្ញុំលួចរត់ទៅដេកជាមួយម៉ាក់ខ្ញុំនៅក្នុងកងចល័តដែលមានចម្ងាយប្រហែលពីរគីឡូម៉ែត្រពីកន្លែងខ្ញុំ ។ ខ្ញុំមិនចង់ឲ្យភ្លឺទេ ព្រោះខ្ញុំមានអារម្មណ៍កក់ក្តៅណាស់ដែលបាននៅជិតម៉ាក់ ប៉ុន្តែខ្ញុំត្រូវបង្ខំចិត្តរត់ឲ្យដល់កងកុមារវិញមុនពេលថ្ងៃរះ ។

ខ្ញុំតែងតែរត់ជួបម៉ាក់ខ្ញុំរបៀបនេះបីបួនដងក្នុងមួយសប្តាហ៍ ។ ថ្ងៃមួយ ពេលដែលខ្ញុំរត់ទៅដល់ផ្ទះឈើដែលប៉ាម៉ាក់ខ្ញុំស្នាក់នៅដូចសព្វដង ស្រាប់តែមានស្ត្រីចំណាស់ម្នាក់បានខ្សឹបប្រាប់ខ្ញុំថា អង្គការបានផ្លាស់ប៉ាម៉ាក់ខ្ញុំឲ្យទៅធ្វើការនៅទំនប់រំលេចដែលមានចម្ងាយប្រហែលដប់គីឡូម៉ែត្រពីទីនោះហើយ ។ ខ្ញុំបានត្រឹមតែសម្រក់ទឹកភ្នែក រួចរត់ត្រឡប់ទៅកងកុមារវិញទាំងក្តីអស់សង្ឃឹម ។ ខ្ញុំតែងតែទន្ទឹងរង់ចាំផ្លូវ ប៉ាម៉ាក់ទាំងថ្ងៃទាំងយប់ និងតែងតែលួចរត់ទៅមើលនៅឯកងចល័តដែលគាត់ធ្លាប់រស់នៅ ។ ប៉ុន្តែ ខ្ញុំមិនដែលទទួលបានដំណឹងអ្វីពីគាត់ទេ ។

ថ្ងៃមួយ មានកម្មាភិបាលខ្មែរក្រហមមួយក្រុមយករទេះគោមកដឹកខ្ញុំ និងក្មេងៗមួយចំនួនទៀតដែលនៅក្នុងកងដោយប្រាប់ថា អង្គការឲ្យនាំយើងទៅជួបឪពុកម្តាយ ។ យើងសប្បាយចិត្តយ៉ាងខ្លាំងពេលដែលឮដូច្នោះ រួចក៏នាំគ្នារត់ឡើងរទេះគោទៅជាមួយកម្មាភិបាលទាំងនោះ ។ យើងធ្វើដំណើរតាមរទេះគោអស់រយៈពេលប្រហែលប្រាំម៉ោង ទើបទៅដល់កន្លែងមួយដែលព័ទ្ធជុំវិញដោយភ្នំមួយ និងមានឈ្មោះថា ចម្ការស័ក្តិបួន ។ ខ្មែរក្រហមបានឲ្យយើងដើរតាមច្រកចូលទៅកាន់ផ្ទះឈើមួយខ្នង ។ ខណៈពេលដែលខ្ញុំឈានជើងចូលបរិវេណនោះភ្លាម ខ្ញុំចាប់ផ្តើមមានអារម្មណ៍ថាប្រហែលជាកន្លែងឃុំឃាំងហើយ ព្រោះមានក្លិនស្អុយចេញពីកន្លែងនោះ ។

ខ្ញុំឃើញអ្នកទោសជាច្រើនកំពុងតែជាប់ខ្នោះ និងរស់នៅលាយឡំជាមួយភក់ជ្រាំ ។ អ្នកទោសទាំងនោះមានសភាពស្គមស្គាំង



សុខ ថៃ (ឆ្វេង) រៀបរាប់ពីរឿងរ៉ាវក្រុមគ្រួសាររបស់គាត់ប្រាប់ លន់ ដាលីន នៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងខែកក្កដា ឆ្នាំ២០១៣

មើលទៅស្ទើរតែមិនស្គាល់ថាជានរណាផង ។ អ្នកទោសទាំងនោះមើលទៅដូចខ្មោចអឺចឹង ។

ខ្មែរក្រហមបានយកខ្ញុំទៅឃុំក្នុងបន្ទប់ងងឹតមួយជាមួយអ្នកទោសក្មេងៗ៥០នាក់ទៀត ដោយមិនបានប្រាប់ពីទោសកំហុស ឬមូលហេតុដែលចាប់យកខ្ញុំមកឃុំទេ ។ ខ្ញុំនិងអ្នកទោសក្មេងៗ៥០នាក់ ទៀតមិនត្រូវបានដាក់ខ្នោះ ឬវាយធ្វើបាបទេ ។ នៅទីនោះយើងទទួលបានតែបបររាវៗចំនួនពីរពេលក្នុងមួយថ្ងៃ និងត្រូវធ្វើការស្ទើរគ្មានពេលសម្រាក ។ ខ្មែរក្រហមបានបញ្ជូនខ្ញុំ និងអ្នកទោសក្មេងៗទាំងអស់ឲ្យទៅធ្វើការនៅកន្លែងមួយដែលមានចម្ងាយប្រហែលមួយគីឡូម៉ែត្រពីគុក និងដើម្បីជៀសវាងកុំឲ្យអ្នកទោសរត់គេចខ្លួន ខ្មែរក្រហមតែងតែបញ្ជូនយើងទៅដាក់គុកវិញមុនថ្ងៃលិច ។

ការងារសម្រាប់អ្នកទោសក្មេងៗនៅគុកចម្ការស័ក្តិបួន មិនមានអ្វីខុសប្លែកពីការងារនៅក្នុងកងកុមារនោះទេ ។ ខ្មែរក្រហមបានឲ្យខ្ញុំដើរកាប់ដើមទន្រ្ទានខែត្រ និងប្រមូលលាមកសត្វធ្វើជីស្ទើរតែពុំមានពេលសម្រាក ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ខ្ញុំតែងតែខិតខំធ្វើការងារ និងខំញញឹមផ្គាប់ចិត្តអង្គការជានិច្ចដើម្បីរក្សាជីវិត ។

ជារឿយៗ កម្មាភិបាលខ្មែរក្រហមតែងតែមកបន្ទប់ឃុំឃាំង និងបានសួរអ្នកដែលនៅក្នុងបន្ទប់ជាមួយខ្ញុំ អំពីប្រវត្តិរូប និងតួនាទីរបស់ឪពុកម្តាយក្នុងជំនាន់លន់នល់ ។ ឃើញដូច្នេះខ្ញុំមានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំង ហើយខ្ញុំក៏មិនដឹងថាពេលណានឹងដល់វេនខ្ញុំដែរ ។ ខ្ញុំតែងតែលួចយំដោយមិនឲ្យអ្នកដែលនៅជាមួយគ្នា ឬកម្មាភិបាលខ្មែរក្រហមឮទេព្រោះខ្លាចយកទៅសម្លាប់ចោល ។ ខ្ញុំមានអារម្មណ៍ឯកោ និងអស់សង្ឃឹម ។

មានយប់មួយនៅដើមឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមម្នាក់ បានដើរទៅក្នុងបន្ទប់ឃុំឃាំង រួចសួររកឈ្មោះខ្ញុំ ។ ពេលនោះខ្ញុំក៏បានលើកដៃឡើងទាំងអារម្មណ៍ភ័យខ្លាច ព្រោះមិនដឹងថានឹងមានរឿងអ្វីកើតឡើងចំពោះខ្ញុំទេ ។ កម្មាភិបាលខ្មែរក្រហមបានសួរខ្ញុំថា «តើឪពុកម្តាយឯងពីមុនធ្វើការងារស្អី» ។ សំណាងល្អខ្ញុំបានកុហកថា ប៉ាម៉ាក់ខ្ញុំធ្វើស្រែ ទើបរួចផុតពីការសម្លាប់ ។ ខណៈនោះ កម្មាភិបាលម្នាក់នោះក៏សួរសំណួរដដែលទៅក្មេងមួយចំនួនផ្សេងទៀត ហើយអ្នកខ្លះដែលឆ្លើយថា ឪពុកធ្លាប់ធ្វើទ័ព ធ្វើគ្រូបង្រៀន ធ្វើពេទ្យ ត្រូវកម្មាភិបាលខ្មែរក្រហមនាំចេញទៅទាំងអស់ដោយប្រាប់ថានាំទៅជួបឪពុកម្តាយវិញ ។ ខ្ញុំធ្លាប់ឮចាស់ៗនៅសហករណ៍សត្វពងនិយាយគ្នាថា ប្រសិនបើកម្មាភិបាលយកនរណាម្នាក់ទៅ ហើយប្រាប់ថាយកទៅរៀនសូត្រ ឬជួបសាច់ញាតិនោះ អ្នកនោះនឹងត្រូវគេយកទៅសម្លាប់ហើយ ។ ប៉ុន្តែ ខ្ញុំមិនដែលហ៊ាននិយាយពាក្យនេះប្រាប់អ្នកផ្សេងទេ ។

ក្រោយមកទៀត ខ្មែរក្រហមបានផ្លាស់មនុស្សមកសួរខ្ញុំនូវសំណួរដដែលនោះចំនួនបីថ្ងៃជាប់ៗគ្នា ប៉ុន្តែខ្ញុំនៅតែឆ្លើយចម្លើយដដែល ។ ប្រហែលមួយសប្តាហ៍ក្រោយមក មានកម្មាភិបាលខ្មែរក្រហមមួយក្រុម បានមកយកខ្ញុំចេញពីបន្ទប់ឃុំឃាំងដោយប្រាប់ខ្ញុំថា អង្គការនឹងបញ្ជូនឲ្យទៅធ្វើការនៅសហករណ៍បឹងនិមលដែលមានចម្ងាយប្រហែលពីរគីឡូម៉ែត្រពីមន្ទីរសន្តិសុខចម្ការស័ក្តិបួន ។ នៅពេលដែលខ្ញុំទៅដល់សហករណ៍នោះ ខ្មែរក្រហមបានឲ្យខ្ញុំទៅស្នាក់នៅផ្ទះឈើមួយខ្នងនៅក្នុងភូមិ ។ រយៈពេលពីរថ្ងៃក្រោយមក ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅធ្វើការក្នុងកងកុមារជាមួយក្មេងៗផ្សេងទៀតនៅក្នុងភូមិ ។

ការងារនៅទីនោះ មិនមានអ្វីប្លែកពីការងារនៅសហករណ៍សត្វពង និងគុកចម្ការស័ក្តិបួនទេ ។ ប៉ុន្តែខ្ញុំអាចហូបឆ្អែត ព្រោះមេភូមិនៅទីនោះមានចិត្តអាណិតស្រឡាញ់ខ្ញុំព្រោះដឹងថាខ្ញុំមិនមានសាច់ញាតិនិងបងប្អូនដូចក្មេងឯទៀត ។ ខ្ញុំបន្តធ្វើការនៅសហករណ៍បឹងនិមលរហូតដល់ឆ្នាំ១៩៧៩ ។

ក្រោយវៀតណាមចូល ខ្ញុំបានព្យាយាមស្វែងរកប៉ាម៉ាក់របស់ខ្ញុំ តែខ្ញុំមិនដែលទទួលដំណឹងពីគាត់ទេ ។ ខ្ញុំមិនមានសង្ឃឹមថាប៉ាម៉ាក់ ខ្ញុំអាចមានជីវិតទេ ព្រោះគាត់គឺជាប្រជាជនថ្មីដែលជាមុខសញ្ញាសម្លាប់របស់ខ្មែរក្រហម ។ ប៉ុន្តែរហូតមកដល់ពេលនេះ ខ្ញុំនៅតែចង់ដឹងថាតើគាត់ស្លាប់នៅកន្លែងណា? តើគាត់ស្លាប់ដោយរបៀបណា? តើខ្ញុំនៅមានសេសសល់សាច់ញាតិឬទេ? ។

ចុងក្រោយខ្ញុំសំណូមពរឲ្យតុលាការជួយរកយុត្តិធម៌សម្រាប់ក្រុមគ្រួសារខ្ញុំ ក៏ដូចជាជនរងគ្រោះផ្សេងទៀតដែលទទួលរងការឈឺចាប់ដោយរបបនោះ ។ ទន្ទឹមនឹងនេះ ខ្ញុំក៏បានរំសាយការឈឺចាប់របស់ខ្ញុំតាមរយៈការអានរឿងរ៉ាវរបស់ជនរងគ្រោះដែរ ។

**លន់ ជាលីន**

# ម្តាយខ្ញុំនៅក្នុងរបបខ្មែរក្រហម

ម្តាយរបស់ខ្ញុំបាទមានឈ្មោះ ហេង មុំ អាយុ៥៦ឆ្នាំ រស់នៅខណ្ឌ៧មករា ក្រុងភ្នំពេញ ។ គាត់មានស្រុកកំណើតស្ថិតនៅផ្លូវលេខ២ សង្កាត់ស្វាយពោ ទីរួមខេត្តបាត់ដំបង ។ គាត់ជាជនរងគ្រោះម្នាក់ដែលបានឆ្លងកាត់របបខ្មែរក្រហម ។

ម្តាយបានប្រាប់ខ្ញុំថា គាត់បានជួបរឿងដ៏គួរឲ្យតក់ស្លុតជាច្រើន ដែលក្នុងមួយឆាកជីវិតរបស់គាត់មិនដែលជួបប្រទះ ការកាប់សម្លាប់ប្រជាជនស្លូតត្រង់ មន្ត្រីរាជការ និង បញ្ញវន្តទេ ។ គាត់បន្តថា នៅមុនរបបខ្មែរក្រហមដឹកនាំប្រទេស ម្តាយរបស់ខ្ញុំរស់នៅម្តុំពេទ្យរុស្ស៊ី (បច្ចុប្បន្នផ្លូវលេខ២៧១) ដែលមានសមាជិកក្នុងក្រុមគ្រួសារចំនួនប្រាំមួយនាក់ (យាយតា ឪពុកម្តាយ ប្អូនប្រុស និង ម្តាយរបស់ខ្ញុំដែលត្រូវជាបងស្រីក្នុងគ្រួសារ) ។ គ្រួសារម្តាយខ្ញុំប្រកបរបរលក់បាយ កាហ្វេគុយទាវ និងគ្រឿងបរិក្ខារពេទ្យគ្រប់មុខ ។ នៅខណៈនោះដែរ ម្តាយខ្ញុំរៀននៅថ្នាក់ទី៧ នៅសាលាបឋមសិក្សាតាព្រហ្ម នៅស្ទឹងមានជ័យ ។

នៅថ្ងៃទី១៧ មេសា ១៩៧៥ យោធាដែលខ្មែរក្រហមបានមកប្រាប់ក្រុម គ្រួសារម្តាយខ្ញុំឲ្យជម្លៀសចេញពីផ្ទះក្នុងអំឡុងពេលបីថ្ងៃ ដោយនិយាយកុហកថា «ចក្រពត្តិអាមេរិកនឹងទម្លាក់គ្រាប់បែកក្នុងទីក្រុងភ្នំពេញ» ។ ដោយមានការគំរាមកំហែងពីសំណាក់យោធាទាំងនោះ ក្រុមគ្រួសារម្តាយខ្ញុំក៏សម្រេចចិត្តចេញដំណើរដោយថ្មើរជើងតាមផ្លូវជាតិលេខ១ រួមជាមួយរទេះសម្រាប់ដឹកទឹក និងឡានមួយសម្រាប់ដឹកអីវ៉ាន់ ប៉ុន្តែពេលនោះគាត់មិនអាចជិះបានទេ គឺត្រូវរុញ និងអូស ។

ម្តាយខ្ញុំបានចាកចេញទាំងអារម្មណ៍ក្តុកក្តួលចិត្ត ហើយនៅតាមដងផ្លូវមានទិដ្ឋភាពគួរឲ្យសោកសង្រេងជាច្រើន ដូចជា ជនចាស់ជរាត្រូវបានកូនចៅទុកចោលនៅមុខផ្ទះ និងនៅតាមដងផ្លូវដោយមូលហេតុ ក្រុមគ្រួសារអ្នកទាំងនោះគ្មានលទ្ធភាព និងមធ្យោបាយដឹកជញ្ជូន ។ ម្យ៉ាងទៀត យោធាខ្មែរក្រហមអះអាងថានឹងយកចាស់ៗទៅថែរក្សាដើម្បីដោយកុំឲ្យក្រុមគ្រួសារមានការបារម្ភ ។ ចំណែកក្មេងៗបានវង្វេងឪពុកម្តាយ និងបានស្រែកយំនៅពាសពេញតាមដងផ្លូវ ព្រមទាំងសាកសពទាហានរដ្ឋាភិបាលជាច្រើនស្លាប់គរនៅតាមដងផ្លូវ ។

គ្រួសារម្តាយខ្ញុំបានបន្តដំណើរទៅមុខ ដោយដំបូងបានទៅស្នាក់នៅក្នុងវត្តក្តីតាកុយ រយៈពេលមួយសប្តាហ៍ ។ ក្រោយមកយោធាខ្មែរក្រហមមកដេញឲ្យក្រុមគ្រួសារគាត់បន្តទៅមុខបន្តទៀត ដោយប្រាប់ថា «បើស្រុកកំណើតនៅទីណា ត្រឡប់ទៅទីនោះវិញទៅ» ។ ម្តាយខ្ញុំអស់សង្ឃឹមជាខ្លាំង ព្រោះមិនសង្ឃឹមថានឹងបានត្រឡប់ចូលក្រុងភ្នំពេញវិញទេ ។ ចំណែកយាយតាទួតរបស់ខ្ញុំចាស់ជរាពិបាកក្នុងការធ្វើដំណើរ ដូច្នេះម្តាយខ្ញុំត្រូវជួយលើកគាត់ដាក់លើរទេះ រួមជាមួយស្បៀងបន្តិចបន្តួចប៉ុណ្ណោះ ។ មកដល់ព្រែកឯង ជីតាទួតរបស់ខ្ញុំបានស្លាប់ដោយសារខ្វះអាហារ និងថ្នាំសង្កូវ ធ្វើឲ្យក្រុមគ្រួសារគាត់មានការអាឡោះអាល័យជាខ្លាំង ។

ពេលខណៈនោះ យោធាខ្មែរក្រហមបានតម្រូវឲ្យក្រុមគ្រួសារទាំងអស់យករបស់របរប្រើប្រាស់រែកតាមខ្លួន ដោយមិនអនុញ្ញាតឲ្យដាក់លើឡាន ឬរទេះរុញដូចមុនទេ ។ ទោះជាមានការហាមឃាត់ក៏ដោយ ប៉ុន្តែដោយគ្រានោះយាយរបស់ខ្ញុំមិនអាចដើរបាន ម្តាយរបស់ខ្ញុំក៏យកចិញ្ចៀនមាសប្រាំជីទៅដូរយកស៊ីក្លូមួយសម្រាប់ដឹកយាយរបស់ខ្ញុំ ។ ក្រុមគ្រួសារម្តាយខ្ញុំធ្វើដំណើរក្នុងមួយថ្ងៃបានប្រមាណប្រាំគីឡូម៉ែត្រប៉ុណ្ណោះដោយសារតែមានប្រជាជនច្រើន ។

ការធ្វើដំណើរចាប់ផ្តើមចេញពីម៉ោង៤ទៀបភ្លឺ ដោយមានកងយោធាឈរចាំបញ្ជា និងសម្លុតឲ្យប្រជាជនធ្វើដំណើរទៅមុខរហូតដល់ម៉ោង៩យប់ទើបឈប់ ។ ស្របពេលនោះ យាយទួតរបស់ខ្ញុំក៏ចាប់ផ្តើមមានជំងឺធ្ងន់ លុះធ្វើដំណើរទៅដល់ជ្រោយដងគីឡូម៉ែត្រលេខ៤២ គាត់ក៏បានស្លាប់នៅទីនោះទៀត ។ គ្រួសារម្តាយខ្ញុំបានយកគាត់ទៅបញ្ចុះនៅទីកន្លែងមួយដែលមានចម្ងាយពីផ្លូវជាតិប្រហែល៥០ម៉ែត្រ ។

ក្រោយយាយទួតរបស់ខ្ញុំស្លាប់ទៅ ម្ដាយខ្ញុំក៏បន្តស្នាក់នៅទីនោះ ។ ក្រុមគ្រួសាររបស់ម្ដាយខ្ញុំ ពុំមានស្បៀងទេ ដូច្នេះ គាត់ត្រូវដើចម្ងាយប្រាំពីរគីឡូម៉ែត្រទៅបើកអង្ករដោយបើកបាន តែមួយកំប៉ុងប៉ុណ្ណោះ ។ ដោយមិនអាចបន្តនៅទីនោះបាន ម្ដាយខ្ញុំបានសម្រេចចិត្តចាកចេញទៅស្រុកកំណើតខាងជីតាខ្ញុំនៅភូមិស្រែចែង ឃុំភ្នំតូច ខេត្តកំពង់ស្ពឺ ដោយចំណាយពេលធ្វើដំណើររយៈពេល៣០ថ្ងៃទើបទៅដល់ទីនោះ ។ គ្រួសារម្ដាយខ្ញុំនៅសល់សមាជិកបួនរូប ហើយត្រូវទៅរស់នៅជាសហករណ៍ ។ គាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើស្រែនៅពេលថ្ងៃ ហើយពេលយប់ត្រូវលើកភ្លឺស្រែ និងជីកប្រឡាយ ។ ចំណែករបស់របរត្រូវប្រមូលដាក់រួម និងហូបរួម ។

រយៈពេលបីខែក្រោយមក អង្គការខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារម្ដាយខ្ញុំឲ្យទៅខេត្តពោធិ៍សាត់ ដោយមានរថយន្តធំៗរង់ចាំជាស្រេច ដោយចេញដំណើរវេលាម៉ោង៦ល្ងាច ។ ម្ដាយខ្ញុំធ្វើដំណើររយៈពេលពីរថ្ងៃ ហើយនៅម៉ោង១២យប់ទើបរថយន្តដឹកក្រុមគ្រួសាររបស់គាត់បានទៅដល់ផ្លូវគ្រួសក្រហម ដោយនៅទីនោះមានបដាមួយសរសេរថា រាបឹងស្នោ ។ នៅទីនោះ មានរទេះគោមករង់ចាំក្រុមគ្រួសារម្ដាយខ្ញុំ ដើម្បីដឹកបន្តទៅដាក់តាមភូមិដែលអង្គការបានកំណត់រួចជាស្រេច ។ អង្គការបានដឹកគ្រួសារម្ដាយខ្ញុំទៅដាក់នៅភូមិព្រៃរោង ឃុំតាលោ ខេត្តពោធិ៍សាត់ ។ គ្រួសារគាត់ត្រូវអង្គការឲ្យរស់នៅក្នុងខ្ទម ដែលគ្មានទឹកស្អាតសម្រាប់ផឹក និងគ្មានបង្គន់ទេ ។

នៅទីនោះ ជីតាខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យចូលព្រៃដឹកខស ម្ដាយខ្ញុំក្រងស្បូវ ចំណែកប្អូនប្រុសរបស់គាត់ត្រូវបានអង្គការបញ្ជូនឲ្យទៅកងកុមារ ។

ក្រោយមក ម្ដាយខ្ញុំត្រូវបានចាត់តាំងឲ្យទៅកងចល័តនារី ពេលនោះហើយជាពេលដែលបានបែកពីគ្រួសារ ។ ម្ដាយខ្ញុំធ្វើការមួយថ្ងៃ១២ម៉ោង តាមបញ្ជារបស់ប្រធានកង ដូចជា ជីកប្រឡាយ ១៧មេសា ភ្ជាប់ពីស្ទឹងមោងទៅស្ទឹងពោធិ៍សាត់ ដោយទទួលបានបបរមួយវែកលាយជាមួយកន្ទក់ក្នុងមួយពេល ។ នៅទីនោះ អង្គការមិនឲ្យឈប់សម្រាកទេ ធ្វើឲ្យអ្នកបាក់កម្លាំងមួយចំនួនត្រូវស្លាប់ជាបន្តបន្ទាប់ ។

នៅពេលដឹកដល់វាលបឹងស្កាប វាលស្រែ១០០ យោធាក៏បានមកគ្រប់គ្រងម្ដងដោយកំណត់ឲ្យម្ដាយខ្ញុំងើបម៉ោង៤ រែកដីរហូតដល់ម៉ោង៩យប់ទើបឲ្យឈប់សម្រាក ។ នៅក្នុងកំឡុងពេលធ្វើការ អង្គការមិនឲ្យប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ បងប្អូនទេ ហើយបើនរណាល្មើសនឹងបញ្ជានោះនឹងត្រូវសម្លាប់ដើម្បីជាគំរូសម្រាប់អ្នកក្រោយ ដោយភាគច្រើនចោទថា "ខុសសីលធម៌" ។ ក្នុងមួយសប្ដាហ៍ ខ្មែរក្រហមអនុញ្ញាតិ ។ ម្ដាយខ្ញុំងូតទឹកម្ដងដោយត្រូវដើរពីរោងស្នាក់នៅទៅកន្លែងងូតទឹកចម្ងាយ១៥គីឡូម៉ែត្រ ចំណែកទឹកសម្រាប់ផឹក ពេលព្រឹកអង្គការចែកឲ្យមួយកាមែល និងល្ងាចមួយកាមែលទៀតដោយសារខ្វះទឹក ព្រោះតំបន់នោះជាតំបន់ដាច់ស្រយាល លូល្ហេវ គ្មានបឹងបួទេ ។

នៅពេលបញ្ចប់វគ្គ អ្នកដែលមានជីវិតរស់រានមានមកភូមិវិញ មានតែប្រាំមួយនាក់ក្នុងចំណោមកងចល័តនារី៣៣នាក់ ដែលភាគច្រើនស្លាប់ដោយការបាក់កម្លាំង និងជំងឺរាក ។

ពេលត្រឡប់មកភូមិវិញ ម្ដាយខ្ញុំបានធ្លាក់ខ្លួនឈឺជាខ្លាំង ដោយសារគាត់ធ្វើការហួសកម្លាំង គ្មានអាហារបរិភោគគ្រប់គ្រាន់ ។ ដោយឃើញម្ដាយខ្ញុំឈឺដូច្នេះ ជីតាខ្ញុំក៏យកនាឡិកាទៅដូរជាមួយប្រជាជនមូលដ្ឋានបានអង្ករមួយកំប៉ុង ។ ប៉ុន្តែចៃដន្យ កងឈ្លបបានចូលមកដល់ឃើញកំពុងដាំបបរ ក៏ចោទជីតាថា ក្បត់សមូហភាព និងបានយកគាត់ទៅសម្លាប់នៅវេលាម៉ោង៩យប់នៅ ។ ម្ដាយខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ព្រោះអង្ករតែមួយកំប៉ុង ត្រូវប្ដូរជាមួយជីវិតជីតា ។

បន្ទាប់ពីខ្មែរក្រហមយកឪពុកទៅសម្លាប់ ពីរថ្ងៃក្រោយមក ប្រធានកងចល័តនារីបានមកប្រាប់ម្ដាយខ្ញុំថា ប្អូនប្រុសរបស់គាត់ដែលនៅកងកុមារនោះត្រូវអង្គការបានបញ្ជូនមកពេទ្យភូមិហើយ ។ ពេលឮដំណឹងនេះម្ដាយខ្ញុំក៏បានទៅមើលប្អូនប្រុសគាត់ ដែលមានសភាពក្អកធ្លាក់ឈាម ហើយពេលនោះប្អូនគាត់ក៏បានប្រាប់គាត់ថា បានលួចរត់ចេញពីកងកុមារ ពេលឮថាឪពុកត្រូវអង្គការយកទៅសម្លាប់ ។ ប៉ុន្តែ ពេលមកដល់ពាក់កណ្ដាលផ្លូវ អង្គការចាប់ក៏ចាប់ រួចយកទៅចងផ្អោបនឹងដើមត្នោត ដោយវាយធ្វើទារុណកម្មដើម្បីសួរចម្លើយពីមូលហេតុនៃការលួចរត់នោះ ។ ឈ្លបខ្មែរក្រហមវាយគាត់រហូតបាក់ធាងត្នោតអស់បី រួចទើបបញ្ជូនគាត់ឲ្យទៅធ្វើ

ការនៅក្នុងកងកុមារវិញ ។

ប្អូនប្រុសម្តាយខ្ញុំបានបន្តសម្រាកនៅក្នុងពេទ្យភូមិ ប៉ុន្តែដោយសារអាការជំងឺមិនបានភាពធូរស្រាល គាត់ក៏លួចចេញពីពេទ្យដើរសំដៅមកផ្ទះវិញដែលមានចម្ងាយពីរគីឡូម៉ែត្រ ។ ពេលនោះម្តាយខ្ញុំពុំសំឡេងប្អូនស្រែកហៅពីចម្ងាយ ទើបគាត់ចេញក្រៅតែហួសពេលទៅហើយ ដោយគាត់ឃើញប្អូនស្លាប់យ៉ាងអណោចអធមនៅផ្លូវរទេះចម្ងាយ៣០ម៉ែត្រពីផ្ទះ ។

ក្រោយមកទៀត អង្គការបញ្ជូនម្តាយខ្ញុំឲ្យទៅធ្វើការនៅកងចល័តវិញ ដោយឲ្យទប់ទំនប់នៅដំណាក់ឈើក្រម ។ នៅទីនោះមួយរយៈ គាត់ក៏ទទួលដំណឹងថាយាយខ្ញុំរស់នៅក្នុងភូមិត្រូវបានអង្គការយកទៅសម្លាប់ទៀតដោយចោទថាយួន ។ ម្តាយខ្ញុំបាត់បង់សមាជិកគ្រួសារទាំងអស់ក្នុងមួយរយៈពេលខ្លីប៉ុណ្ណោះ ។ ពេលនោះម្តាយខ្ញុំមិនហ៊ានចូលភូមិទេ ព្រោះគាត់បានទទួលដំណឹងថាអង្គការបានតាមរកគាត់ថា ខ្មាំងមិនស្មោះនឹងអង្គការ ។

ម្តាយខ្ញុំបានរួចរស់ជីវិត ក្រោយមានការរំដោះ ថ្ងៃប្រាំពីរខែមករា ១៩៧៩ ។ គាត់បានចាកចេញពីជើងភ្នំដោយធ្វើរដើងរយៈពេលដប់ថ្ងៃ ទើបទៅដល់ផ្លូវជាតិដោយមានតែរបស់របរមួយអង្រែកធ្វើដំណើរទៅទីរួមខេត្តពោធិ៍សាត់ ។ រយៈពេលពីរខែក្រោយមក ទើបគាត់បានបន្តដំណើរមកទីក្រុងភ្នំពេញ ។ ម្តាយខ្ញុំបានរៀបការនៅឆ្នាំ១៩៨៥ ហើយបច្ចុប្បន្ន គាត់មានកូនពីរនាក់ ។ រឿងដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមនៅតែដិតដាមក្នុងអារម្មណ៍របស់គាត់ ដោយសារការបាត់បង់ឪពុកម្តាយ បងប្អូននិងសាច់ញាតិ ។

គាត់មិនចង់ឲ្យរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនេះ វិលត្រឡប់មកសាជាថ្មីទេ គឺគាត់ចង់រស់នៅក្រោមការអភិវឌ្ឍ សុខសន្តិភាព គ្មានការគំរាមកំហែង គ្មានការភិតភ័យ ។ គាត់ក៏សូមសំណូមពរឲ្យសាលាក្តីខ្មែរក្រហមពន្លឿនដំណើរការកាត់ទោស ដើម្បីឲ្យមេដឹកនាំទាំងអស់ទទួលស្គាល់ការពិត និងសារភាពទោសកំហុសដែលបញ្ជាឲ្យមានការសម្លាប់យាងរង្គាលលើប្រជាជនខ្មែរជាងបីលាននាក់ ព្រោះការកាត់ទោសនេះជាការផ្សះផ្សាផ្លូវចិត្តសម្រាប់ប្រជាជនខ្មែរ ដែលបានបាត់ក្រុមគ្រួសារដ៏អយុត្តិធម៌ក្នុងរបបនោះ ។

**សុខ ទីរៈ**

# ដំណឹងសួររកបង ឪពុកមា និងម្តាយមីង

ខ្ញុំបាទឈ្មោះ សួរ វីណារិន ជាមន្ត្រីរាជការនៅក្រសួងបរិស្ថាន ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៧៨ (មុំវត្តពោធិ៍ចិនតុង) ផ្លូវ២០០១ កែងមហាវិថីសហព័ន្ធរុស្ស៊ី ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

ខ្ញុំបាទសូមប្រកាសរកបងប្រុសឈ្មោះ សួរ វីឡា កើតឆ្នាំ១៩៦៥ (ឆ្នាំថោះ) មានឪពុកឈ្មោះ សួរ គីមចេក ស្លាប់ខែមករា ឆ្នាំ ២០១២ និងម្តាយឈ្មោះ បេ គីម ជីង នៅរស់ ។ ឪពុកម្តាយខ្ញុំបាទមានកូនចំនួនបីនាក់ គឺៈ

១) សួរ វីឡា ភេទប្រុស (បាត់ដំណឹង)

២) សួរ វីណារ៉ា ភេទប្រុស

៣) សួរ វីណារិន ភេទប្រុស

ចំណែកមា–មីងមានឈ្មោះៈ ទី១) បេ គីមយ៉ុង (ស្រី), ទី២) បេ គីមស៊ិន (ស្រី), ទី៣) បេ គីមហួរ (ស្រី), ទី៤) បេ គីមលេច ទី៥) បេ គីមរ័ត្ន (ប្រុស), និង ទី៦) បេ គីមមុំ (ស្រី) ដែលបានបែកគ្នាក្នុងខែមេសា ឆ្នាំ១៩៧៥ ពេលរបប ប៉ុល ពត ជម្លៀសចេញពីទីក្រុងភ្នំពេញ ។

ប្រសិនបើ បងនិងមីង–មា ឬញាតិមិត្តណាបានឮដំណឹងនេះ សូមទាក់ទងមកប្អូនប្រុសឈ្មោះ សួរ វីណារិន តាមរយៈទូរស័ព្ទលេខ ០៩៧ ៨ ៨១១ ១០៧ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ។

***សូមអរគុណ!***

*លិខិតពីមិត្តអ្នកអាន*

# ជូនចំពោះវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

បន្ទាប់ពីបានស្តាប់នូវវគ្គទាំងបួននៃកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងការអត់ឃ្លាន ខ្ញុំពិតជាមានអារម្មណ៍ព្រឺព្រួចនឹងសោកស្តាយយ៉ាងខ្លាំងដែលប្រជាជនខ្មែរប្រមាណជាប្រាំបីសែនទៅមួយលានបីសែននាក់បានស្លាប់ដោយសារការអត់ឃ្លាន ហើយចំនួនប្រជាជនសរុបដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺប្រហែលជាបីលានដែលស្មើនឹង ៤០ ភាគរយនៃចំនួនប្រជាជនសរុបក្នុងប្រទេស ។

អ្វីដែលជាការភ្ញាក់ផ្អើលនិងហួសចិត្តនោះគឺ ភាពអត់ឃ្លានបានធ្វើឲ្យប្រជាជនមួយចំនួនតូចសម្រេចចិត្តសម្លាប់សាច់ញាតិ ឬមិត្តរួមសហករណ៍របស់ខ្លួន ដើម្បីយកសាច់មកបរិភោគ ។

លើសពីនេះទៅទៀត ការអត់ឃ្លាននេះជាមូលហេតុចម្បងដែលបង្កអោយមានការស្លាប់នៃចំនួនប្រជាជនកើនឡើងតាមរយៈកង្វះអនាម័យ និងការសម្លាប់ដោយសារលួចបរិភោគអាហារក្រៅសហករណ៍ ។ ការបង្ខំឲ្យប្រជាជនបរិភោគត្រឹមតែបបរាវមួយវែកក្នុងមួយពេល និងការបង្ខំឲ្យប្រជាកសិករធ្វើការហួសកម្លាំងក៏ជាមូលហេតុមួយផងដែរ ។

សរុបសេចក្តីមក ទាំងអស់នេះជារឿងរ៉ាវប្រវត្តិសាស្ត្រពិតដែលប្រជាជនខ្មែរយើងបានជួបប្រទះ ដូច្នេះហើយក្នុងនាមយើងជាកូនចៅជំនាន់ក្រោយ យើងទាំងអស់គ្នាគួររៀន អាន និងយល់ដឹងឲ្យបានច្រើននូវរឿងរ៉ាវប្រវត្តិសាស្ត្រដ៏ជូរចត់នេះដើម្បីចៀសវាងការកើតឡើងម្តងទៀតនូវអំពើប្រល័យពូជសាសន៍នេះ ម្យ៉ាងវិញទៀត ខ្ញុំសូមសំណូមពរឲ្យតុលាការកាត់ក្តីខ្មែរក្រហមចាត់ទុកការបង្កឲ្យមានភាពអត់ឃ្លាននេះ ចូលជាទោសមួយក្នុងសំណុំរឿង ០០២ ដើម្បីរកយុត្តិធម៌ឲ្យប្រជាជនយើងដែលរងគ្រោះក្នុងរបបឃោរឃៅនោះ ។ **គីម ឡេង**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ដំណឹងស្វែងរកគ្រួសារ



នាងខ្ញុំឈ្មោះ វ៉ង់ ផន ហៅ ង៉ែត ភេទស្រី ពីសង្គមចាស់រស់នៅភូមិបឹងទំពន់ ហៅ ទំនប់ថ្មី ក្រុងភ្នំពេញ ។ បច្ចុប្បន្ន នាងខ្ញុំរស់នៅភូមិទួលក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ។ នាងខ្ញុំបានបែកពីប្តីឈ្មោះ អ៊ិត ផាន់ណា ហៅ យ៉ត ពេលខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំចេញពីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៩ព្រឹក ។ ពេលនោះ នាងខ្ញុំមានកូនស្រីម្នាក់ឈ្មោះ អ៊ិត ចាន់រី ហៅ អាស្រី មានអាយុ៤ឆ្នាំ និងកំពុងមានផ្ទៃពោះ៧ខែ កូនទី២ ទៀត ។

ក្រោយមក ទើបនាងខ្ញុំទទួលដំណឹងថា ប្តីរបស់នាងខ្ញុំដែលបានបែកគ្នាជំនាន់ខ្មែរក្រហមបានមកសួររកនាងខ្ញុំនៅភូមិដែលរស់នៅបច្ចុប្បន្ន ប៉ុន្តែអ្នកជិតខាងបានប្រាប់ថានាងខ្ញុំ និងកូន បងប្អូន ព្រមទាំងឪពុកម្តាយស្លាប់អស់ហើយ ។ នាងខ្ញុំមិនចាំពេលវេលាដែលប្តីនាងខ្ញុំមករកទេ ។

បច្ចុប្បន្នខ្ញុំ និង កូន ព្រមទាំងបងផាន បងផល រស់នៅក្នុងភូមិទួលក្រាំង ។ ប្រសិនបើបងប្អូនណាបានទទួលដំណឹងនេះ សូមទាក់ទងមកនាងខ្ញុំតាមរយៈអាសយដ្ឋានរបស់នាងខ្ញុំដូចខាងលើ ឬទូរស័ព្ទ ០ ១២ ៩៩២ ១៧១ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ។

***សូមអរគុណ!***

# ដំណឹងសួររកបងប្អូន

នាងខ្ញុំឈ្មោះ លាង រស្មី អាយុ៥៨ឆ្នាំ ពីមុនធ្វើការខាងឱសថការី ឥឡូវនៅផ្ទះ មានប្ដីធ្វើការខាងឱសថការី ។ សព្វថ្ងៃ នាងខ្ញុំរស់នៅផ្ទះលេខ561Eo ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ នាងខ្ញុំមានក្មួយស្រីម្នាក់ឈ្មោះ ទឹម វីណែត ធ្វើការនៅមន្ទីរអប់រំ ខេត្តព្រៃវែង និងប្ដីឈ្មោះ ឡេវ ពិរុន សព្វថ្ងៃធ្វើការនៅមន្ទីរសង្គមកិច្ចខេត្តព្រៃវែង ដែលត្រូវជាក្មួយ និងកូនប្រសារលោក លាង លក្ខិណារ ។

យើងខ្ញុំទាំងបួននាក់សូមប្រកាសរកឈ្មោះ លាង លក្ខិណារ ហៅ ម៉ារីន បច្ចុប្បន្នមានអាយុប្រហែល៦៥ឆ្នាំ ដែលត្រូវជាបងប្រុស និងឪពុកដែលបានបាត់ខ្លួននៅក្នុងសម័យខ្មែរក្រហមនៅចុងឆ្នាំ១៩៧៨ ។ មុនឆ្នាំ១៩៦៩ គាត់ជាសាស្ត្រាចារ្យនៅសាលាយុគន្ធរ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ ។ ក្រោយមកទើបយើងដឹងថា ខ្មែរក្រហមចាប់ខ្លួនគាត់ រួចបញ្ជូនទៅឃុំឃាំងនៅឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ អ្នកធ្លាប់ជាប់ឃុំឃាំងជាមួយគាត់បានប្រាប់យើងនៅចុងឆ្នាំ១៩៧៨ថា អង្គការបានដោះលែងគាត់ ប៉ុន្តែយើងមិនដែលទទួលដំណឹងពីគាត់ទេ ។

អាស្រ័យហេតុនេះ ប្រសិនបើបងប្អូនណាបានស្គាល់ឬឮឈ្មោះ លាង លក្ខិណារ សូមទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១២ ២៨៦ ៤៣៧ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**

# ដំណឹងស្វែងរកបងប្រុស

នាងខ្ញុំឈ្មោះ លឹម គៀង អាយុ៤៣ឆ្នាំ មានស្រុកកំណើតនៅទីក្រុងភ្នំពេញ បច្ចុប្បន្នរស់នៅភូមិអំពៅដៀប ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប ។ នាងខ្ញុំមានឪពុកឈ្មោះ លឹម ជាថៃ (ស្លាប់) និងម្តាយឈ្មោះ មុយ ដូវ (ស្លាប់) ហើយមានបងប្អូនបង្កើតចំនួន៦នាក់គឺៈ ១) លឹម ស្រេង ភេទប្រុស (បាត់ខ្លួន) ,២) លឹម ឃឹម ភេទប្រុស (បាត់ខ្លួន) , ៣) នាងខ្ញុំ លឹម គៀង, ៤) លឹម ដេង ភេទប្រុស (ស្លាប់ដោយជំងឺក្នុងសម័យខ្មែរក្រហម) , ៥) លឹម អ៊ុយ ភេទប្រុស (ស្លាប់ដោយជំងឺក្នុងសម័យខ្មែរក្រហម) និង ៦) លឹម ស៊ាក់ ភេទប្រុស (ស្លាប់ដោយជំងឺក្នុងសម័យខ្មែរក្រហម) ។

នាងខ្ញុំសូមប្រកាសរកបងប្រុសទាំងពីរខាងលើឈ្មោះ លឹម ស្រេង និង លឹម ឃឹម ។ យើងទាំងបីនាក់បានបែកគ្នាក្រោយឆ្នាំ១៩៧៩ ពេលធ្វើដំណើរចេញពីស្ពានស្រែង ក្នុងគោលបំណងត្រឡប់មកទីក្រុងភ្នំពេញដែលជាស្រុកកំណើតវិញ ។ លុះដើរមកដល់ស្រុកក្រឡាញ់ ខេត្តសៀមរាប បងប្រុសទាំងពីររបស់ខ្ញុំបានសុំអ្នកបររទេះគោឲ្យខ្ញុំឲ្យជិះជាមួយ ដោយសារតែខ្ញុំពិការជើងទាំងពីរតាំងពីកំណើត ។ ពេលធ្វើដំណើរយើងក៏បែកគ្នា ហើយខ្ញុំក៏ចុះពីរទេះគោចាំផ្លូវគាត់តែមិនឃើញ ។ ក្រោយមកក៏បានជួបនឹងមីងម្នាក់មានចិត្តអាណិតខ្ញុំ ក៏យកខ្ញុំទៅរស់នៅជាមួយនៅភូមិអំពៅដៀប ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប រហូតដល់បច្ចុប្បន្ន ។ ដោយសារតែពេលនោះនាងខ្ញុំមានអាយុត្រឹមតែប្រាំបួនឆ្នាំ ហេតុនេះខ្ញុំមិនបានចាំអាយុបងប្រុសទាំងពីរនោះទេ ។

ប្រសិនបើបងប្អូនណាបានស្គាល់ ឬឮឈ្មោះ លឹម ស្រេង និង លឹម ឃឹម សូមទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទៈ ០៩៧ ៤ ១៣៤ ១៤៥ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ

ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 163, July 2013 ◆ Funded by USA.

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.